# មេរៀនវេយ្យាករណ៍

## *ទាក់ទងនឹងមេរៀនជាវីដេអូ* «Aleph with Beth»

## មាតិការ


មេរៀនទី 1 - នាមនិងគុណនាមបឋម.......... 8
    1.1 សព្វនាមសំនួរ.......... 8
    1.2 Article ជាក់លាក់ (Definite Article).......... 9
    1.3 គុណនាម.......... 10
មេរៀនទី 2 - នាមពហុវចនៈ និងគុណនាមពហុវចនៈ.......... 13
    2.1 מְאֹד ‘ណាស់’.......... 13
    2.2 សព្វនាមចង្អុលពហុវចនៈ («ទាំងនេះ»).......... 13
    2.3 ទម្រង់ពហុវចនៈ.......... 14
    2.4 ពហុវចនៈដែលប្រែប្រួល.......... 14
មេរៀនទី 3 - ឈ្នាប់ និងភេទ.......... 16
    3.1 ឈ្នាប់ -ו.......... 16
    3.2 ព្យញ្ជនៈដែលមានការបញ្ចេញសម្លេង២.......... 17
    3.3 ភេទនិងនាមដែលមានពាក្យតែមានសំដៅទៅលើភេទទាំងពីរ អេពីសេន.......... 18
មេរៀនទី 4 - សព្វនាមប្រធាន.......... 20
    4.1 សព្វនាមប្រធាន.......... 20
    4.2 ប្រយោគដែលគ្មានកិរិយាសព្ទ (“Verbless clauses”).......... 21
មេរៀនទី 5 - ពាក្យគ្រួសារ.......... 23
    5.1 បច្ច័យជាសព្វនាមដែលសម្គាល់កម្មសិទ្ធិ (pronominal suffixes).......... 23


Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

5.2 ទំរង់ផ្សារភ្ជាប់ ... 25
5.3 ព្យញ្ជនៈដែលមានការបញ្ចេញសម្លេងពីរយ៉ាង ... 26
5.4 សញ្ញាម៉ាកាហ្វ (*Maqqef*) ... 27
សេចក្តីពន្យល់បន្ថែម ... 28
មេរៀនទី 6 - ផ្កាក់និង ទីតាំង ... 29
6.1 ផ្កាក់ ... 29
6.2 កិរិយាស័ព្ទបង្គាប់បញ្ជារ שִׂים ... 30
6.3 ពាក្យ אֶת־ សម្គាល់ពីកម្មបទផ្ទាល់ជាក់លាក់ (definite direct objects) ... 30
មេរៀនទី 7 - អក្សរក្រម វគ្គទី 1 ... 32
7.1 ព្យញ្ជនៈមួយចំនួន ... 32
7.2 ស្រៈមួយចំនួន ... 32
7.3 ការសរសេរ Article ជាក់លាក់ ... 32
មេរៀនទី 8 - អវយវៈនៃរាងកាយ ... 34
8.1 ទម្រង់គូ (“dual form”) ... 34
8.2 នាមដែលលេចឡើងតែក្នុងទម្រង់ជាពហុវចនៈ ... 35
8.3 នាមជាទម្រង់ផ្សាភ្ជាប់ ... 35
មេរៀនទី 9 - ល្អនិង អាក្រក់ ... 36
9.1 រំលឹកអំពីបច្ច័យកម្មសិទ្ធ ... 36
9.2 ពាក្យ דָּבָר ... 36
9.3 គុណនាម “ល្អ” និង “អាក្រក់” ... 37
9.4 បុព្វបទសំណួរ ដែលសួរពី "បាទ-ទេ" (“Yes-No questions”) ... 38
9.5 *Hinneh* הִנֵּה ... 38
មេរៀនទី 10 - អក្សរក្រម វគ្គទី 2 ... 39
10.1 ព្យញ្ជនៈមួយចំនួន ... 39
10.2 ស្រៈមួយចំនួន ... 39
10.3 សញ្ញាម៉ាកាហ្វ (*Maqqef*) - រំលឹកពីមេរៀន 5.4 ... 39
មេរៀនទី 11 - ទម្រង់ផ្សាភ្ជាប់ ... 40
11.1 ទម្រង់ពហុវចនៈសម្រាប់ពាក្យកូនប្រុសនិងកូនស្រី ... 40
11.2 ទម្រង់ផ្សាភ្ជាប់ ... 40
11.3 ល្អឬអាក្រក់នៅក្នុងភ្នែករបស់... 👁️👁️ ... 43
មេរៀនទី 12 - លេខ ១-៥ ... 44
12.1 លេខ ១-៥ ... 44
12.2 កិរិយាសព្វបញ្ជា (Imperative verb) קַח ... 46
12.3 ទាំងអស់ ((כֹּל / כָּל־ ... 46
មេរៀនទី 13 - អក្សរក្រម វគ្គទី 3 ... 47
13.1 ព្យញ្ជនៈមួយចំនួន ... 47
13.2 ស្រៈមួយចំនួន ... 47
13.3 ព្យញ្ជនៈដែលមានសម្លេងពីរ (ព្យញ្ជនៈ *begadkefat*) ... 47
មេរៀនទី 14 - ធម្មជាតិនិងប្រយោគដែលបញ្ជាក់ពីវត្តមាន ... 50

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

14.1 នាមដែលមានទម្រង់ជាពហុវចនៈប៉ុណ្ណោះ....50
14.2 អត្ថន័យធៀបដែលទាក់ទងនឹងពាក្យនៃអវៈយវៈ.... 50
14.3 គុណកិរិយាទាក់ទងនឹងពេលថ្ងៃនិងពេលយប់....50
14.4 នាមដែលមានទម្រង់ជាឯកវចនៈ តែមានន័យជាពហុវចនៈ ("Collective Nouns")....51
14.5 ប្រយោគដែលបញ្ជាក់ពីវត្តមាននៃកម្មវត្ថុ ("Existence clauses").... 52
មេរៀនទី 15 - ភូមិសាស្ត្រនិងប្រធានបទផ្សេងៗទៀត....54
15.1 ច្រើន.... 54
15.2 នាមថ្មីពីរទៀត ដែលមានទម្រង់ជាឯកវចនៈ តែមានន័យជាពហុវចនៈ ("Collective Nouns")....54
15.3 ទន្លេនិងទន្លេស្ងួត ("wadi")....55
មេរៀនទី 16 - អក្សរក្រម វគ្គទី 4.... 56
16.1 ព្យញ្ជនៈមួយចំនួន....56
មេរៀនទី 17 - ធ្នាក់ ל (Lamedh) និងកម្មសិទ្ធិ....57
17.1 ការបញ្ជាក់ពីកម្មសិទ្ធ.... 57
17.2 គុណនាមដែលមានតួនាទីជានាម.... 58
សេចក្ដីពន្យល់បន្ថែម.... 58
មេរៀនទី 18 - កុមារនិងពួកចាស់ទុំ....59
18.1 កំណត់ចំណាំពីវគ្គសព្ទ.... 59
មេរៀនទី 19 - អក្សរក្រម វគ្គទី 5.... 60
19.1 ព្យញ្ជនៈមួយចំនួន....60
19.2 *pataħ* សម្លេងខ្លី (reduced *pataħ*).... 60
19.3 Furtive *pataħ*....61
មេរៀនទី 20 - ពាក្យ אֲשֶׁר (*'asher*) & ឃ្លាដែលមានសព្វនាមទំនាក់ទំនងជាចំណង (Relative Clauses).... 63
20.1 ធ្នាក់ផ្សំ.... 63
20.2 បុព្វបទធ្នាក់ដែលនៅជាប់នឹងនាម (inseparable preposition) ពេលប្រើជាមួយនឹង article ជាក់លាក់ (definite article).... 63
20.3 ពេលដែលឈ្នាប់ -וְ (*və-*) ក្លាយជា -וּ (*u-*) (ការរំលឹកមេរៀនទី 3.1)....64
20.4 សព្វនាមទំនាក់ទំនង אֲשֶׁר (*'asher*).... 64
មេរៀនទី 20b - ការសរសេរអក្សរក្រមភាសាហេព្រើរ....66
20b.1 អក្សរក្រមភាសាហេព្រើរ ("Aleph-Bet")....66
មេរៀនទី 21- កិរិយាស័ព្ទ «មក» និង «ទៅ» (qatal ឯកវចនៈ).... 68
21.1 សេចក្ដីណែនាំស្ដីពីកិរិយាស័ព្ទនៃភាសាហេព្រើរ....68
21.2 Aspect.... 69
21.3 កិរិយាស័ព្ទប្រក្រតី និង កិរិយាស័ព្ទមិនប្រក្រតី (Weak & Strong Verbs).... 69
21.4 Binyanim (stems) & Qal....70
មេរៀនទី 22 - "និយាយ" (אָמַר) និងពាក្យបង្គាប់ ("imperatives").... 71
22.1 אָמַר - «គាត់(ប្រុស)បាននិយាយ» ឬ «ទ្រង់មានបន្ទូល»....71
22.2 ពាក្យបង្គាប់ ("imperatives")....71
22.3 ទម្រង់ *vayyiqtol* (vav-consecutive-imperfect)....72
មេរៀនទី 23 - បច្ច័យកម្មសិទ្ធិ ("possessive suffixes")ផ្នែកទី១ & អវយវៈនៃរាងកាយ....74
23.1 បច្ច័យកម្មសិទ្ធិ ("possessive suffixes").... 74

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

មេរៀនទី 24 - បច្ច័យកម្មសិទ្ធផ្នែកទី២ & ពាក្យគ្រួសារ........................................................ 76
24.1 ពាក្យគ្រួសារ........................................................ 76
មេរៀនទី 25 - ការស្ដាប់ & ការស្ដាប់បង្គាប់........................................................ 79
25.1 សម្លេង - קוֹל........................................................ 79
25.2 ការស្ដាប់ & ការស្ដាប់បង្គាប់........................................................ 79
25.3 ព្រះនាមនៃព្រះ........................................................ 80
មេរៀនទី 26 - «គឺជា» & សម្រស់........................................................ 81
26.1 «គឺជា» (To Be) - הָיָה........................................................ 81
26.2 សម្រស់ - יָפֶה និង יָפָה........................................................ 82
មេរៀនទី 27 - ឲ្យ & យក; ប្រាក់ & មាស........................................................ 83
27.1 ឲ្យ (נָתַן) & យក ((לָקַח........................................................ 83
27.2 កិរិយាសព្ទដែលមានទម្រង់ពហុវចនៈ........................................................ 84
មេរៀនទី 28 - អាពាហ៍ពិពាហ៍........................................................ 85
28.1 ពាក្យថ្មី៖ בַּיִת........................................................ 85
28.2 ការរំលឹកឡើងវិញអំពី *Vayyiqtol*........................................................ 85
28.3 ការ «យក» & ការ «ឲ្យ» ប្រពន្ធ........................................................ 86
មេរៀនទី 29 - ធ្នាក់ផ្សេងទៀត........................................................ 87
29.1 ក្រុង - עִיר........................................................ 87
29.2 ការនិយាយ - לֵאמֹר........................................................ 87
29.3 ធ្នាក់ מִן........................................................ 88
29.4 ធ្នាក់ផ្សេងទៀត........................................................ 89
មេរៀនទី 30 - បច្ច័យកម្មសិទ្ធ (“Possessive Suffixes”) ផ្នែកទី៣ - នាមពហុវចនៈភេទប្រុស ដែលមានបច្ច័យ.. 91
មេរៀនទី 31 - លេខ 6-10........................................................ 93
31.1 លេខ 6-10........................................................ 93
មេរៀនទី 32 - ពួកហោរា & កិរិយាសព្ទផ្សេងៗទៀត........................................................ 95
32.1 កិរិយាសព្ទថ្មី........................................................ 95
32.2 דִּבֶּר & Piel Stem........................................................ 95
32.3 רָאָה........................................................ 95
មេរៀនទី 33 - ពាក្យ אֶת־ ជាមួយកម្មបទផ្ទាល់........................................................ 96
33.1 ការរំលឹកអំពីភាពជាក់លាក់ ជាមួយឧទាហរណ៍........................................................ 96
មេរៀនទី 34 - ការពិត ការកុហក ហើយនិងពាក្យបង្គាប់........................................................ 98
34.1 «គាត់មិនមែនជា____ ខ្ញុំមិនមែនជា____ ប៉ុន្តែជា_______!»........................................................ 98
34.2 ការពិត & ការកុហក........................................................ 98
34.3 ទម្រង់ពាក្យបង្គាប់ (imperative verbs)........................................................ 99
មេរៀនទី 35 - ផ្លែឈើ & ធ្នាក់ដែលមានបច្ច័យជាប់ជាមួយ........................................................ 100
35.1 ការភ្ជាប់បច្ច័យជាមួយធ្នាក់........................................................ 100
35.2 מַעֲשֶׂה........................................................ 101
មេរៀនទី 36 - សាច់និងឈាម អាសនានិងការចាក់ប្រេងតាំង........................................................ 102
36.1 វគ្គសព្ទថ្មី........................................................ 102

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

មេរៀនទី 37 - ស្លាប់ & រស់.......103
37.1 בָּנָה - “សង់”.......103
37.2 ស្លាប់ & រស់.......103
37.3 וַיֵּרַע.......103
37.4 יִהְיֶה - «គាត់នឹងក្លាយទៅជា...».......104
មេរៀនទី 38 - សាសន៍អ៊ីស្រាអែលចង់បានស្តេច.......106
មេរៀនទី 39 - កំឡាំង & ប្រាជ្ញា៖ ការប្រៀបធៀប.......109
39.1 វគ្គសព្ទថ្មី.......109
39.2 ការប្រៀបធៀបដោយប្រើពាក្យ מִן.......109
មេរៀនទី 40 - លោកណូអេ & ទូកធំ៖ ប្រភេទនៃរបស់ដែលព្រះបានបង្កើតឡើង.......111
40.1 ប្រភេទនៃរបស់ដែលព្រះបានបង្កើតឡើង.......111
40.2 វគ្គសព្ទថ្មី.......112
មេរៀនទី 41 - כְּ & ភាពស្រដៀងគ្នា.......113
41.1 វគ្គសព្ទថ្មី.......113
41.2 ធ្នាក់ כְּ.......113
41.3 כַּאֲשֶׁר.......114
មេរៀនទី 42 - ពន្លឺ & ភាពងងឹត; ព្រឹក & ល្ងាច.......114
42.1 វគ្គសព្ទថ្មី.......114
មេរៀនទី 43 - ការបង្កើតពិភពលោក.......114
មេរៀនទី 44 - ចេញទៅ & លើកឡើង.......115
44.1 វគ្គសព្ទថ្មី.......115
44.2 ទម្រង់ផ្សេងទៀតនៃឫសពាក្យ רָאָה.......115
44.3 ធ្នាក់ אֵת “ជាមួយ”.......115
44.4 សញ្ញា Sof Pasuq ((׃.......116
មេរៀនទី 45 - កិរិយាសព្ទបន្តបន្ទាប់គ្នា (Verb Sequences)៖ ទម្រង់ Vayyiqtol (ផ្នែកទី១).......117
45.1 ទម្រង់ Vayyiqtol.......117
45.2 Qamets Hatuf.......117
45.3 ការរំលឹក៖ កិរិយាសព្ទខ្សោយ.......117
មេរៀនទី 46 - ចាត់ អ្នកនាំសារ & សព្វនាមជាកម្មបទ.......118
46.1 ការពន្យល់បន្ថែមពីពាក្យ אֵת (បុព្វបទដែលបញ្ជាក់ពីកម្មបទ) និង אֵת (ធ្នាក់).......118
46.2 វគ្គសព្ទថ្មី.......119
មេរៀនទី 47 - ម្ហូបអាហារ & ភេសជ្ជៈ.......120
47.1 វគ្គសព្ទថ្មី.......120
អត្ថបទបន្ថែម ទី១ – ឈ្មោះកណ្ឌគម្ពីរជាភាសាហេព្រើរ.......121
អត្ថបទបន្ថែម ទី២ – ពាក្យវេយ្យាករណ៍និងពាក្យផ្សេងៗ ជាភាសាហេព្រើរ.......122

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 1 - នាមនិងគុណនាមបឋម

## 1.1 សព្វនាមសំនួរ

នៅក្នុង ភាសាហេព្រើរក្នុងសម័យព្រះគម្ពីរ គឺមិនមានសញ្ញាសួរទេ (?)។ អ្នកអាចសម្គាល់នូវសំនួរដោយប្រើសព្វនាមសំនួរ “អ្វី?” “ឯណា?” -ល-។ ក្នុងមេរៀននេះ ប្រយោគទាំងអស់ រួមទាំងសំនួរ វានឹងបញ្ចប់ជាមួយសញ្ញានេះ(:) ហៅថា *sof pasuq*.[1]

| | | | |
|---|---|---|---|
| ឯណា? | *ʾayyeh* אַיֵּה | អ្វី? | *mah* מָה/מַה |

| | | | | |
|---|---|---|---|---|
| តើនេះ(គឺជា)អ្វី? | זֹאת אִשָּׁה׃<br>*zoʾt ʾishshah*<br>នេះ(ជា)ស្ត្រីម្នាក់។ | מַה־זֹּאת׃<br>*mah-zoʾt*<br>នេះស្អី? | זֶה אִישׁ׃<br>*zeh ʾish*<br>នេះ(ជា)បុរសម្នាក់។ | מַה־זֶּה׃<br>*mah-zeh*<br>នេះស្អី? |
| នេះ(គឺជា)… | זֹאת פָּרָה׃<br>*zoʾt parah*<br>នេះ(ជា)មេគោ | מַה־זֹּאת׃<br>*mah-zoʾt*<br>នេះស្អី? | זֶה פַּר׃<br>*zeh par*<br>នេះ(ជា)គោបា | מַה־זֶּה׃<br>*mah-zeh*<br>នេះស្អី? |

[1] នៅក្នុងព្រះគម្ពីរសញ្ញាចាស់ជាភាសាហេព្រើរ សញ្ញា *sof pasuq* វាបញ្ជាក់ពីចំណុចបញ្ចប់នៃខគម្ពីរ ជូនកាលមិនមែនជាចំណុចបញ្ចប់នៃឃ្លាមួយទេ។ ខគម្ពីរមួយអាចនឹងមានច្រើនជាងមួយឃ្លា ប៉ុន្តែសញ្ញា *sof pasuq* ត្រូវបានគេដាក់នៅខាងចុងខ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

## 1.2 **Article ជាក់លាក់** ( **Definite Article** )

Article ជាក់លាក់ (definite article) “the” គឺជាបុព្វបទភ្ជាប់ នៅខាងដើមពាក្យ៖ *ha-* (-הַ or -הָ)។ នៅក្នុងភាសារហេព្រើរ វាមិនមាន article មិនជាក់លាក់ (indefinite article) ដូចជា ‘a’ ឬ ‘an’ ទេ។ ដូច្នេះ នាមមិនជាក់លាក់ នឹងមិនមាន បុព្វបទភ្ជាប់ នៅខាងដើមពាក្យនោះឡើយ ឧ. ប្រៀបធៀប אִישׁ *ʾish* («បុរសម្នាក់») ជាមួយ הָאִישׁ *haʾish* («បុរសម្នាក់ហ្នឹង»)។

ភាសាហេព្រើរប្រើនាមជាក់លាក់

សម្រាប់និយាយសំដៅទៅលើកម្មវត្ថុដ៏ជាក់លាក់ណាមួយ។ ឧ. បើខ្ញុំនិយាយថា “אֲבַקֵּשׁ פַּר” («ខ្ញុំកំពុងស្វែងរកគោមួយ”) មានន័យថា គោណាក៏បាន។ ប៉ុន្តែបើនិយាយថា “אֲבַקֵּשׁ הַפַּר” («ខ្ញុំកំពុងស្វែងរកគោមួយហ្នឹង») មានន័យថា ខ្ញុំរកគោដែលបានបញ្ជាក់នៅខាងដើមយ៉ាងជាក់លាក់។

យើងឃើញឧទាហរណ៍មួយនៅក្នុង ២ សាំយូអែល 12:7។ ជាដំបូងហោរាណាថានបានលើកឡើងថា មានបុរសពីរនាក់ ម្នាក់ជាអ្នកមាន ហើយម្នាក់ទៀតជាអ្នកក្រ។ អ្នកមានបានយកចៀមអ្នកក្រ យកធ្វើម្ហូបឲ្យភ្ញៀវគាត់ញ៉ាំ (12:1-4)។ ក្រោយពីស្តាប់រឿងនេះ ដាវីឌមានចិត្តខឹងនឹងអ្នកមាននោះ (12:5-6)

តែណាថាននិយាយថា “אַתָּה הָאִישׁ” («អ្នកគឺជា ម្នាក់នោះហើយ»)។ ដោយសារណាថានប្រើ article ជាក់លាក់ គាត់សំដៅទៅលើមនុស្សម្នាក់នៅក្នុងរឿង។ ផ្ទុយទៅវិញ បើសិនជាគាត់មិនប្រើ article ជាក់លាក់នៅក្នុងប្រយោគរបស់គាត់ទេ(“אַתָּה אִישׁ”) នោះវាមានន័យជាលក្ខណៈទូទៅ («អ្នកគឺជាបុរសម្នាក់»)។

នៅពេលដែលគុណនាមបំពេញន័យឲ្យនាមដែលមាន article ជាក់លាក់ តំរូវឲ្យដាក់ article ជាក់លាក់ នៅជាមួយនឹងគុណនាមនោះដែរ។ ឧ.הַפַּר הַגָּדוֹל *happar haggadol* (‘the big bull’; អាចមានន័យបែបនេះជាភាសាខ្មែរ «គោបាធំមួយហ្នឹង»)។ ដោយសារនាម פַּר («គោបា») មាន article ជាក់លាក់ ដូច្នេះគុណនាម גָּדוֹל («ធំ») តំរូវឲ្យមាន article ជាក់លាក់ដែរ។ វាជួយយើងក្នុងការផ្គុំគុណនាម ជាមួយនឹងនាម ដែលវាបញ្ជាក់លក្ខណៈក្នុងឃ្លារតែមួយ។

គុណនាមចង្អុល (ឧ. *zeh* **זֶה** ឬ *zoʾt* **זֹאת** មានន័យថា «នេះ») ក៏អញ្ចឹងដែរ។ គុណនាមចង្អុលដែលបញ្ជាក់លក្ខណៈរបស់នាមដែលមាន article ជាក់លាក់ តំរូវឲ្យវាមាន article ជាក់លាក់ ដែរ។ ភាសា ហេព្រើរមានគុណនាមចង្អុលពីរ៖

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| ភាសាអង់គ្លេស | ភាសាខ្មែរ | ភាសាហេព្រើរ |
|---|---|---|
| Article ជាក់លាក់ (definite article) *'the'* | (ភាសាខ្មែរអត់មាន article ទេ) | *ha* -הָ/-הַ[2] |
| a big bull | គោបាធំមួយ | *par gadol* פַּר גָּדוֹל |
| the big bull | (ពិបាកបកប្រែ ប៉ុន្តែស្រដៀងនឹង៖) «គោបាធំមួយហ្នឹង» | הַפַּר הַגָּדוֹל *happar haggadol* |
| this bull | គោបាមួយនេះ | הַפַּר הַזֶּה *happar hazzeh* |

## 1.3 **គុណនាម**

គុណនាមរៀបរាប់ពីលក្ខណ:នៃនាម ហើយវាស្ថិតនៅខាងក្រោយនាម ដែលវាបញ្ជាក់លក្ខណ:ឲ្យ។ នៅក្នុងភាសារហេព្រើរ គុណនាមតែងតែស្របជាមួយនឹងនាម ទាំងភេទ (គឺភេទប្រុស ឬ ភេទស្រី) និងវចន: (ឯកវចន: ឬ ពហុវចន:)។ ដូច្នេះគុណនាមមាន៤ទម្រង់៖ ភេទប្រុសឯកវចន: ភេទស្រីឯកវចន: ភេទប្រុសពហុវចន: ហើយនិង ភេទស្រីពហុវចន:។ នាមភេទប្រុសឯកវចន: វានឹងត្រូវស្របជាមួយគុណនាមភេទប្រុសឯកវចន: ហើយ នាមភេទស្រីឯកវចន:មួយនឹងត្រូវស្របជាមួយគុណនាមភេទស្រីឯកវចន: ដូចជាឧទាហរណ៍ខាងក្រោម៖

| | |
|---|---|
| גְּדוֹלָה    פָּרָה<br>*gədolah*    *parah* | גָּדוֹל    פַּר<br>*gadol*    *par* |

[2] សូមមើលផ្នែក 7.3 ដែលពន្យល់ថាហេតិអ្វីបានជា article ជាក់លាក់ សរសេរជាទម្រង់ខុសគ្នា។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| គុណនាមភេទស្រីឯកវចនៈ<br>នាមភេទស្រីឯកវចនៈ<br><br>មេគោធំមួយ<br><br> | គុណនាមភេទប្រុសឯកវចនៈ<br>នាមភេទប្រុសឯកកវចនៈ<br><br>គោបាធំមួយ<br><br> |
|---|---|

នៅពេលដែលគុណនាម ប្រើជាកន្សោមពាក្យ នោះគុណនាមនិងនាមគឺស្របគ្នា ហើយតំរូវឲ្យមាន article ជាក់លាក់ទាំងពីរ ឬគ្មានទាំងពីរ (ឧ. ខាងក្រោមផ្នែកខាងស្តាំ)។

ប្រសិនបើ គុណនាម ឬ សព្វនាមចង្អុលប្រើជាមួយនាមដែលមាន article ជាក់លាក់
ប៉ុន្តែមិនមាន បុព្វបទ «-הָ»
នោះគុណនាមនោះមិនមែនជាផ្នែកមួយនៃកន្សោមពាក្យនោះទេ
វាបង្កើតបានជាប្រយោគឯករាជ្យ (ឧ. ខាងក្រោមផ្នែកខាងឆ្វេង)។

| | |
|---|---|
| הָאִישׁ גָּדוֹל *haʾish gadol* | הָאִישׁ הַגָּדוֹל… *haʾish haggadol* |
| បុរសនេះធំ | បុរសធំនេះ… |



យើងអាចសម្គាល់បានថា គុណនាមនិងសព្វនាមចង្អុលនៅជួរទី១ ខាងក្រោម វាគឺជាផ្នែកមួយនៃកន្សោមនាម ដោយព្រោះវាត្រូវបានសម្គាល់ដោយបុព្វបទ -הָ។ ផ្ទុយទៅវិញ សព្វនាមចង្អុលនៅជួរទី២ និងគុណនាមនៅជួរទី3 មិនមានបុព្វបទ -הָ ទេ ដូច្នេះវាបង្កើតឲ្យមានប្រយោគឯករាជ្យ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | | | |
|---|---|---|---|---|
| បុរសធំនេះ… | הָאִישׁ הַגָּדוֹל הַזֶּה<br>*haʾish haggadol hazzeh* | ស្ត្រីតូចនេះ… | הָאִשָּׁה הַקְּטַנָּה הַזֹּאת<br>*haʾishshah haqqəṭannah hazzoʾt* | ១ |
| នេះ(ជា)បុរសធំ(ម្នាក់ហ្នឹង)[3] | זֶה הָאִישׁ הַגָּדוֹל׃<br>*zeh haʾish haggadol* | នេះ(ជា)ស្ត្រីតូច(ម្នាក់ហ្នឹង)។ | זֹאת הָאִשָּׁה הַקְּטַנָּה׃<br>*zoʾt haʾishshah haqqəṭannah* | ២ |
| បុរសនេះធំ។ | הָאִישׁ הַזֶּה גָּדוֹל׃<br>*haʾish hazzeh gadol* | ស្ត្រីនេះតូច។ | הָאִשָּׁה הַזֹּאת קְטַנָּה׃<br>*haʾishshah hazzoʾt qəṭannah* | ៣ |

[3] នៅក្នុងការបកប្រែនេះពាក្យ «ម្នាក់ហ្នឹង» សម្គាល់ទៅលើមនុស្សជាក់លាក់ម្នាក់ តែសូមបញ្ជាក់ថា ភាសាខ្មែរអត់មាន article ជាក់លាក់ដូចភាសាហេព្រើរឬអង់គ្លេសទេ ដូច្នេះអាចមានការពិបាកក្នុងបកប្រែបន្តិច។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 2 - នាមពហុវចនៈ និងគុណនាមពហុវចនៈ

## 2.1 מְאֹד ‘ណាស់’

មុខងារមួយនៃពាក្យ *mə'od* מְאֹד គឺដើម្បីពង្រឹងគុណនាមដែលវាបញ្ជាក់ ដូចជាពាក្យ "ណាស់"។

| | |
|---|---|
| ល្អ *ṭov* טוֹב | តូច קָטֹן |
| ល្អណាស់ *ṭov məʾod* טוֹב מְאֹד | តូចណាស់ קָטֹן מְאֹד |

## 2.2 សព្វនាមចង្អុលពហុវចនៈ («ទាំងនេះ»)

សម្រាប់សព្វនាមចង្អុលឯកវចនៈ (‘នេះ’) ភាសាហេព្រើមានទម្រង់ជាភេទប្រុស *zeh* זֶה រីឯទម្រង់ភេទស្រី *zoʾt* זֹאת ។ សព្វនាមចង្អុលពហុវចនៈ (‘ទាំងនេះ’) អាចប្រើបានសម្រាប់ទាំងពីរភេទ៖ *ʾelleh* אֵלֶּה។

| | ភេទប្រុស | ភេទស្រី |
|---|---|---|
| ឯកវចនៈ | זֶה | זֹאת |
| ពហុវចនៈ | אֵלֶּה | |

ដូចគ្នានឹង זֶה និង זֹאת ដែរ នៅពេលដែល אֵלֶּה មានតួនាទីជាគុណនាមចង្អុល វាស្ថិតនៅខាងក្រោយនាមផ្ទាល់ ហើយមាន article ជាក់លាក់ (definite article)

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ដើម្បីផ្តផ្តងនាម (ខាងឆ្វេងខាងក្រោម)។ វាក៏អាចជាសព្វនាមប្រធាននៃអនុប្រយោគ (ខាងស្តាំខាងក្រោម)។

| | | | |
|---|---|---|---|
| សេះទាំងនេះ... (គុណនាមចង្អុល) | הַסּוּסִים הָאֵלֶּה | ទាំងនេះគឺជាសេះ (សព្វនាមចង្អុល) | אֵלֶּה סוּסִים |

## 2.3 **ទម្រង់ពហុវចនៈ**

នាមភេទបុរសតម្រូវឲ្យមានការបញ្ចប់ដោយ *-im* ִים -
ដោយលែកនាមភេទស្រីតម្រូវឲ្យបញ្ចប់ដោយ *-ot* וֹת-។
គុណនាមដែលបញ្ជាក់នាមនឹងយល់ស្របជាមួយនឹងនាមតាមភេទ និងវចនៈ ដោយមានការបញ្ចប់ដូចគ្នា។

| | | | |
|---|---|---|---|
| គោបា | פַּר | មេគោ | פָּרָה |
| គោបា (ពហុវចនៈ) | פָּרִים | មេគោ (ពហុវចនៈ) | פָּרוֹת |
| គោបាធំមួយ | פַּר גָּדוֹל | មេគោធំមួយ | פָּרָה גְדוֹלָה |
| គោបាធំៗ | פָּרִים גְּדֹלִים | មេគោធំៗ | פָּרוֹת גְּדֹלוֹת |

## 2.4 **ពហុវចនៈដែលប្រែប្រួល**

នាមខ្លះមិនទៀងទាត់ ហើយប្រើបច្ច័យ (អ្វីដែលដាក់ខាងចុងនៃពាក្យ) ពហុវចនៈដែលភ្ជាប់ជាមួយភេទផ្ទុយ ឧ. הַשֻּׁאִ («ស្ត្រី») និង עֵץ («ពពែ»)

ដែលមានការបញ្ចប់ដោយពហុវចនៈភេទបុរស ִים◌- ទោះបីជាការពិតវាមានលក្ខណៈជាភេទស្រីក៏ដោយ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

យើងអាចដឹងភេទពិតរបស់ពាក្យទាំងនោះបាន តាមរយៈគុណនាមដែលបញ្ជាក់វា បញ្ចប់ដោយបច្ច័យពហុវចនៈ *וֹת-* ។

| | | | |
|---|---|---|---|
| ស្ត្រី | אִשָּׁה | ពពែ | עֵז |
| ស្ត្រី (ពហុវចនៈ) | נָשִׁים | ពពែ (ពហុចនៈ) | עִזִּים |
| ស្ត្រីធំ | נָשִׁים גְּדֹלוֹת | ពពែតូច | עִזִּים קְטַנּוֹת |

យើងនឹងឃើញទម្រង់នាមភេទប្រុសប្រែប្រួល
ដែលមានការបញ្ចប់ដោយបច្ច័យពហុវចនៈភេទស្រី នៅមេរៀនខាងមុខទៀត។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 3 - ឈ្នាប់ និងភេទ

## 3.1 ឈ្នាប់ -וְ

បុព្វបទឈ្នាប់ -וְ ( “*វ*-” ) វាចងភ្ជាប់ឃ្លានិងប្រយោគជាច្រើនប្រភេទ។ ភាគច្រើនវាមានន័យថា ‘និង’ ប៉ុន្តែអាចមានន័យថាជា “ប៉ុន្តែ” ឬ ឈ្នាប់ផ្សេងទៀត អាស្រ័យលើបរិបទ។ វាត្រូវបានសរសេរភ្ជាប់ចំពោះពាក្យដែលនៅជាប់វា។

אִישׁ וְאִשָּׁה
“បុរសម្នាក់និងស្ត្រីម្នាក់”

នៅក្នុងបរិបទខ្លះ -וְ (*វ*-) ក្លាយទៅជា –וּ (*u*-) អាស្រ័យលើពាក្យដែលវាភ្ជាប់ជាមួយ។ សម្លេងត្រូវបានផ្លាស់ប្តូរនៅក្នុងទីតាំងពីរនេះ៖

1) នៅពីមុខនៃព្យញ្ជនៈដែលមានសម្លេងត្រង់បបូរមាត់ គឺព្យញ្ជនៈទាំងបួននេះ៖ , ב , פ ו , מ (ឧ. וּפַר)
2) នៅពីមុខនៃព្យញ្ជនៈដែលមានស្រៈ *shewa* (ឧ. וּגְמַלִּים)

នៅក្នុងមេរៀននេះយើងនិងឃើញឈ្នាប់ -וּ

នៅពីមុខព្យញ្ជនៈដែលមានសម្លេងត្រង់បបូរមាត់ខ្លះដូចជា៖ ១ នៅក្នុង וּפֵרוֹת וּפַר -ល- ។

ហើយនៅពីមុខព្យញ្ជនៈដែលមានស្រៈ *shewa* ( ְ ) ដូចជា וּנְעָרוֹת וּגְמַלִּים -ល- ។ យើងនឹងឃើញឧទាហរណ៍នៃការផ្លាស់ប្តូរសម្លេងនេះបន្ថែមទៀតនៅមេរៀនបន្ទាប់។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

## 3.2 ព្យញ្ជនៈដែលមានការបញ្ចេញសម្លេង២

ព្យញ្ជនៈខ្លះ (ជាញឹកញាប់ត្រូវបានហៅថា ព្យញ្ជនៈ «បេហ្គាដកេហ្វាត» *begadkefat* ដើម្បីជួយក្នុងការចងចាំវា)[4] ក្លាយទៅជា “fricatives” នៅក្នុងបរិបទខ្លះ (ចរន្តខ្យល់ត្រូវបានបង្រួញ ប៉ុន្តែបន្តហូរជាជាងកាត់ផ្តាច់ទាំងស្រុង)។ ការបញ្ចេញសម្លេងដែលអ្នកឮនៅក្នុងវិដេអូ មានតែ ៣

ព្យញ្ជនៈប៉ុណ្ណោះដែលផ្លាស់ប្តូរសម្លេងបែបនេះ៖ פּ בּ និង כּ ។ វាតែងតែសម្គាល់ដោយសញ្ញា *dagesh* (សញ្ញាចុចតូចមួយ ត្រង់ចំណុចកណ្តាល់នៃព្យញ្ជនៈ)៖

- នៅពេលដែលមានសញ្ញា ***dagesh*** វាត្រូវបានបញ្ចេញសម្លេងជាការឈប់ (ចរន្តខ្យល់កាត់ផ្តាច់ ដូចដែលមាននៅក្នុងស្វរដើមនៃព្យញ្ជនៈ «ប» «ផ» ហើយនិង «ខ»)
- នៅពេលវាគ្មានសញ្ញា ***dagesh*** វាត្រូវបានបញ្ចេញសម្លេងជា **fricative** (ចរន្តខ្យល់បន្តអោយចេញមក ដូចដែលមាននៅក្នុងស្វរដើមនៃព្យញ្ជនៈ «វ» និង «ហ្វ»)

| | | | | | | |
|---|---|---|---|---|---|---|
| ខ | כּ | ផ | פּ | ប | בּ | សម្លេងជាការឈប់ ដែលមានសញ្ញា *dagesh* |
| (មានសម្លេង ដែលបង្កើត នៅក្នុងក្រអូមមាត់) | כ | ហ្វ | פ | វ | ב | Fricatives ដែលគ្មានសញ្ញា *dagesh* |

ដោយមូលហេតុនេះហើយបានជាអ្នកនឹងឮ ព្យញ្ជនៈខ្លះប្តូរសម្លេងទៅតាមបរិបទរបស់វា ដូចជា បន្ទាប់ពីឈ្នាប់ «-וְ» ឬ « וּ»។ នៅក្នុងមេរៀននេះ អ្នកនឹងឮថា ព្យញ្ជនៈ פּ (ផ) ប្តូរទៅជា פ(ហ្វ) ហើយ כּ (ខ) ប្តូរទៅជា כ ដូចជាឧទាហរណ៍ខាងក្រោម ។

---

[4] ព្យញ្ជនៈ *begadkefat* ទាំងអស់មាន៦ (ប ក ដ ខ ផ ថ)៖ בגדכפת។ តាមការបញ្ចេញតាមបែបបូរាណព្យញ្ជនៈទាំងអស់នេះ មានសម្លេង fricative នៅពេលដែលគ្មានសញ្ញា *dagesh* នៅចន្លោះវា៖ b → v, g → ɣ, d → ð, k → χ, p → f, t → θ។ យ៉ាងណាក៏ដោយភាសាហេព្រើរបច្ចុប្បន្នហើយនិងការបញ្ចេញសម្លេងបែប Sephardic ដែលយើងប្រើក្នុងមេរៀនជាវិដេអូដែលយើងរៀន មានព្យញ្ជនៈតែបីនេះ ដែលមានការផ្លាស់ប្តូរសម្លេង៖ ב פ כ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

នៅក្នុងមេរៀនខាងមុខទៀត អ្នកនឹងបានឮផងដែរអំពី ព្យញ្ជនៈ ב (ប) ប្ដូរសម្លេងទៅជាសម្លេង ב (វ) ។

| | | | |
|---|---|---|---|
| וּכְבָשִׂים | כְּבָשִׂים | וּפַר | פַּר |
| *u-χəvasim* | *kəvasim* | *u-far* | *par* |
| និងចៀម (ពហុ.) | ចៀម (ពហុ.) | និងគោបា | គោបា |

(ក្នុងវីដេអូ អក្សរ *begadkefat* ផ្សេងទៀតគឺ ג ד ហើយនិង ת ជានិច្ចកាលតែងតែបញ្ចេញសម្លេង «ដ» «ហ្គ» និង «ថ» ទោះបីជាវាមានឬគ្មាន *dagesh*។)

## 3.3 ភេទនិងនាមដែលមានពាក្យតែមានសំដៅទៅលើភេទទាំងពីរ អេពីសេន

នាមក្នុងភាសារហេព្រើរមានភេទប្រុស (זָכָר *zaχar*) ឬស្រី (נְקֵבָה *nəqevah*)។[5] ក្នុងវីដេអូនេះ យើងតម្រៀបនាមទាំងអស់ដែលយើងបានរៀនរហូតមកដល់ពេលនេះ ទៅតាមនាមភេទរបស់ពួកវា។ នាមភេទស្រី ជាញឹកញាប់បញ្ចប់ជាមួយ ָה- ឬ ת- ប៉ុន្តែមិនមែនជានិច្ចជាកាលបែបនេះរហូតទេ។

នៅក្នុងភាសាហេព្រើរ នាមជាសត្វមួយចំនួន មានទម្រង់តែមួយបណ្ដោះសម្រាប់នាមភេទប្រុស និងនាមភេទស្រី។ ពាក្យសម្រាប់សត្វអូដ្ឋ גָּמָל (ហ្គាម៉ាល) គឺជាពាក្យមួយ ក្នុងចំណោមពាក្យទាំងនេះ។ ទម្រង់ גָּמָל អាចសំដៅលើសត្វអូដ្ឋឈ្មោល ឬ សត្វអូដ្ឋញី ។

[5] ស្រដៀងគ្នានឹងភាសាបារាំងដែរ ភេទរបស់នាមជាភាពចាំបាច់នៅក្នុងវេយ្យាករណ៍ប៉ុណ្ណោះ។ ដូច្នេះជួនកាលយើងមិនអាចដឹងជាមុនថាវាមានភេទណាមួយ លើកលែងតែយើងមើលនៅក្នុងវចនានុក្រម។ ឧ. ពាក្យ «ថូ» ជាភេទប្រុស ប៉ុន្តែពាក្យ «កែវ» ជាភេទស្រីទោះបីជារបស់ទាំងពីរនេះ ជាអភេទតាមវេយ្យាករណ៍ខ្មែរ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

តើពាក្យ גָּמָל យើងអាចសម្គាល់វា ថាជាញីឬឈ្មោលដោយរបៀបណា?
តាមរយៈគុណនាម ឬ សព្វនាមចង្អុល យើងអាចសម្គាល់នាមនោះថា ជាភេទប្រុសឬក៏ជានាមភេទស្រី ដូចជាឧទាហរណ៍ខាងក្រោម។



| | |
|---|---|
| សត្វអូដ្ឋ(ឈ្មោល) តូចនេះ | הַגָּמָל הַקָּטָן הַזֶּה<br>*haggamal haqqaṭon hazzeh* |
| សត្វអូដ្ឋ(ញី)តូចនេះ | הַגָּמָל הַקְּטַנָּה הַזֹּאת<br>*haggamal haqqəṭannah hazzoʾt* |

សេចក្តីពន្យល់បន្ថែម

ហេតុអ្វី? ← לָמָּה

ខ្ញុំអត់ដឹងទេ ← אֵינֶנִּי יֹדַעַת

ភាសាហេព្រើរគឺអញ្ចឹង! ← כָּכָה עִבְרִית

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 4 - សព្វនាមប្រធាន

## 4.1 សព្វនាមប្រធាន

សព្វនាមប្រធានមានទម្រង់ជា ឯកវចនៈនិងពហុវចនៈ ហើយបែងចែករវាងភេទប្រុសហើយនិងភេទស្រី នៅក្នុងបុរសទី២ និងបុរសទី៣ ។ បុរសទី១អត់បែងចែកភេទទេ។ ឧទាហរណ៍ភាសាហេព្រើរប្រើពាក្យ אַתָּה *ʾattah* («អ្នក») នៅពេលដែលនិយាយជាមួយមនុស្សប្រុសម្នាក់ ហើយ אַתְּ *ʾat* នៅពេលដែលនិយាយជាមួយមនុស្សស្រីម្នាក់។ លើសពីនេះទៅទៀតភាសាហេព្រើរប្រើពាក្យ אַתֶּם *ʾattem* («អ្នករាល់គ្នា») នៅពេលដែលនិយាយជាក្រុមមនុស្សប្រុស ឬ ក្រុមចម្រុះភេទ ហើយនិង אַתֵּן *ʾatten* («អ្នករាល់គ្នា») នៅពេលដែលនិយាយជាមួយក្រុមនុស្សស្រី។

សព្វនាមបុរសទី១ឯកវចនៈ («ខ្ញុំ») ហើយនិងពហុវចនៈ («យើង») គឺដូចគ្នាដោយមិនគិតពីភេទរបស់អ្នកនិយាយ។ យ៉ាងណាក៏ដោយមានទម្រង់២ នៃសព្វនាមឯកវចនៈបុរសទី១ («ខ្ញុំ») នៅក្នុងព្រះគម្ពីរភាសាហេព្រើរគឺ ពាក្យ אֲנִי *ʾani* ដែលយើងឃើញញឹកញាប់បំផុត ហើយនិងពាក្យ אָנֹכִי *ʾanoχi* ក៏ឧស្សាហ៍ឃើញដែរ។ ពាក្យទាំងពីរនេះ មិនមានអត្ថន័យខុសគ្នាជាក់លាក់នោះទេ។

| ឯកវចនៈ | | | ពហុវចនៈ | | |
|---|---|---|---|---|---|
| នាមភេទប្រុស | នាមភេទស្រី | | នាមភេទប្រុស | នាមភេទស្រី | |
| *ʾanoχi* / *ʾani* אָנֹכִי / אֲנִי | | ខ្ញុំ | *ʾanaħnu* אֲנַחְנוּ | | យើង |
| *ʾattah* אַתָּה | *ʾatt* אַתְּ | អ្នក | *ʾattem* אַתֶּם | *ʾatten* אַתֵּן | អ្នករាល់គ្នា |
| *hu*ʾ הוּא | *hi*ʾ הִיא | គាត់ | *hem* הֵם | הֵנָּה *hennah* | ពួកគេ |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

## 4.2 ប្រយោគដែលគ្មានកិរិយាសព្ទ ( “Verbless clauses” )

ដូចប្រយោគក្នុងមេរៀនមុនៗ ប្រយោគក្នុងមេរៀននេះមានលក្ខណៈគ្មានកិរិយាសព្ទ។ ប្រយោគនិមួយៗ ត្រូវការប្រធានបទនិងការបន្ថែម (“complement”)។ ការបន្ថែមមានតួនាទីដើម្បីបញ្ជាក់អត្ថន័យឲ្យប្រធាន។ នៅក្នុងភាសាខ្មែរ គុណនាមអាចមានតួនាទីជាការបន្ថែម (“complement”) ដោយមិនត្រូវការកិរិយាសព្ទទេ (ឧ. «ផ្ទះខ្ញុំពណ៌ក្រហម»)។ រីឯភាសាខ្មែរដើម្បីភ្ជាប់នាមពីរ តំរូវឲ្យមានកិរិយាសព្ទនៅកណ្ដាល់ ទើបអាចបង្កើតជាល្បះបាន (ឧ. «ខ្ញុំជាមនុស្សប្រុស»)។

ចំណែកឯភាសាហេព្រើរ ឃ្លាអាចត្រូវបានបង្កើតឡើងដោយការភ្ជាប់ប្រធាននឹងនាម (ដូចក្នុងជួរទី១) ឬ គុណនាម (ដូចក្នុងជួរទី២) ដោយមិនចាំបាច់ប្រើកិរិយាសព្ទ។ នៅក្នុងមេរៀនក្រោយៗទៀត យើងក៏នឹងឃើញកន្សោមមានធ្នាក់ ("prepositional phrase”) នៅក្នុង ឃ្លាដែលគ្មានកិរិយាសព្ទ (“verbless clause”) ដើម្បីពិពណ៌នាអំពីទីតាំងនៃប្រធានបទ។

| | | |
|---|---|---|
| អ្នក(គឺជា)សត្វលា។ | *ʾattah ḥamor* :אַתָּה חֲמוֹר | ១ |
| អ្នកតូច។ | *ʾattah qaṭon* :אַתָּה קָטֹן | ២ |

នៅក្នុងបរិបទខ្លះ យើងអាចឃើញការបន្ថែម (“complement”) នៅខាងមុខ ហើយប្រធាននៅបន្ទាប់ (ឧ. នៅខាងក្រោម)

| | | |
|---|---|---|
| នាង(គឺជា)អ្វី? | *mah-hiʾ* :מָה־הִיא | ១ |
| នាង(នោះគឺ)ស្ត្រីតូចម្នាក់។ | *ʾishshah qəṭannah hiʾ* אִשָּׁה קְטַנָּה :הִיא | ២ |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

## សេចក្ដីពន្យល់បន្ថែម

ឈ្នាប់ כִּי មានការបកប្រែជាច្រើនបែបទៅតាមបរិបទរបស់វា ប៉ុន្តែនៅទីនេះ វាសម្គាល់សេចក្ដីថ្លែងជំទាស់បន្ទាប់ពីប្រយោគបដិសេធ ដែលមានន័យស្រដៀងទៅនឹង «ផ្ទុយទៅវិញ» ឬ «ប៉ុន្តែ...»។ ឧ.៖

| | |
|---|---|
| អ្នក(ជា)សត្វលា!<br>មិនមែនទេ! ខ្ញុំ(ជា)បុរសទេ។ | אַתָּה חֲמוֹר!<br>לֹא! כִּי אִישׁ אָנֹכִי׃ |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 5 - ពាក្យគ្រួសារ




## 5.1 បច្ច័យជាសព្វនាមដែលសម្គាល់កម្មសិទ្ធិ (pronominal suffixes)

ភាសាហេព្រើរសម្គាល់កម្មសិទ្ធិដោយសព្វនាមជាបច្ច័យ (pronominal suffixes) នៅពីក្រោយនាម។ នៅក្នុង មេរៀននេះ យើងជួបប្រទះនូវបច្ច័យចំនួនបី៖

1. បុរសទីមួយឯកវចនៈ («របស់ខ្ញុំ»)៖ -ִי
2. បុរសទីបីឯកវចនៈភេទប្រុស («របស់គាត់»)៖ -וֹ

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

3. បុរសទីបីឯកវចនៈភេទស្រ្តី («របស់នាង»)៖ הָ◌- [6]

ជាញឹកញាប់នៅពេលដែលបច្ច័យជាសព្វនាមទាំងនេះនៅជាប់ពាក្យណាមួយ ធ្វើអោយសម្លេងរបស់ស្រៈនៃនាមមួយនោះខ្លី។ ឧ. ក្នុងភាសាអង់គ្លេស ពាក្យ “write” ស្រៈ “i” មានសម្លេងវែង ប៉ុន្តែពាក្យ “written” ស្រៈ “i” មានសម្លេងខ្លី

ដូចជាឧទាហរណ៍នៅខាងក្រោមនេះ **שֵׁם → -שְׁמ**។

**שֵׁם → -שְׁמ**

| שְׁמָהּ | שְׁמוֹ | שְׁמִי | שֵׁם |
|---|---|---|---|
| ឈ្មោះរបស់នាង (ម្នាក់នោះ) | ឈ្មោះរបស់បុរស (ម្នាក់នោះ) | ឈ្មោះរបស់ខ្ញុំ | ឈ្មោះ |



שְׁמִי בַּת



שְׁמוֹ אַבְרָם



שְׁמָהּ שָׂרָה

---

[6] បច្ច័យជាសព្វនាមបុរសទីបីឯកវចនៈភេទស្រ្តីគឺ អក្សរ «ហេ» ដែលមានចុចមួយ (הּ- *-ahh*)។ ចុចមួយហ្នឹងយើងហៅថា «សញ្ញាម៉ាបពីក» *mappiq*)។ សញ្ញាម៉ាបពីកបញ្ជាក់ថាវាគឺជាបច្ច័យ មិនមែនជាអក្សរចុងក្រោយនៃពាក្យ (ה ָ *-a*).

នៅពេលដែលមានចុចនេះ (הּ- *-ahh*) នៅចុងបញ្ចប់យើងត្រូវបញ្ចប់សម្លេង *h* ប៉ុន្តែបើសិនជាគ្មានចុចទេ (ה ָ *-a*) យើងបញ្ចេញសម្លេង *a* តែប៉ុណ្ណោះ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

## 5.2 ទំរង់ផ្សារភ្ជាប់

នៅក្នុងមេរៀននេះ យើងរៀនអំពីពាក្យសម្រាប់ទំនាក់ទំនងគ្រួសារ។ សូមចំណាំថាពាក្យជាភាសាហេព្រើរដែលមានន័យថា «ប្តី» និង «ប្រពន្ធ» គឺដូចគ្នានឹង «បុរស» និង «ស្ត្រី» (ឧ. ជា «ស្ត្រីរបស់ខ្ញុំ» មានន័យថា «ប្រពន្ធរបស់ខ្ញុំ»។

នៅក្នុងមេរៀននេះ អ្នកនឹងឃើញថា ពាក្យមួយចំនួនផ្លាស់ប្តូរទម្រង់ នៅពេលដែលវាស្ថិតនៅខាងមុខ "ម្ចាស់" របស់វា (marking a genitive relationship)។ ពាក្យទាំងនេះត្រូវបានគេហៅថា "ទំរង់ផ្សារភ្ជាប់" ( "construct form" ) ហើយនេះគឺជាលក្ខណៈសំខាន់មួយនៃវេយ្យាករណ៍ភាសាហេព្រើរ។

សូមបញ្ជាក់ថា ជួនកាល ទំរង់ផ្សារភ្ជាប់ស្រដៀងគ្នានឹងពាក្យខ្មែរ «នៃ» ឬ «របស់»។ ជួនកាលទំរង់ផ្សារភ្ជាប់សម្គាល់ថាពាក្យនៅខាងមុខគឺជា «កម្មសិទ្ធ» និងពាក្យនៅខាងក្រោយគឺជា «ម្ចាស់» ឧ. זֶה בֵּית שָׂרָה មានន័យថា «នេះគឺជាផ្ទះរបស់នាងសារ៉ា»។ ប៉ុន្តែជួនកាលទំរង់ផ្សារភ្ជាប់សម្គាល់អំពីទំនាក់ទំនង ឧ. אַבְרָהָם אֲבִי יִצְחָק មានន័យថា «លោកអ័ប្រាហាំគឺជាឪពុកនៃលោកអ៊ីសាក។»

នេះត្រូវបានរៀបរាប់លម្អិតបន្ថែមទៀតនៅក្នុងមេរៀនទី 11 ប៉ុន្តែសម្រាប់ពេលនេះ គ្រាន់តែផ្តោតលើការយល់ដឹងអំពីការផ្លាស់ប្តូរដែលកើតឡើងសម្រាប់ "ទំរង់ផ្សារភ្ជាប់" ( "construct forms" )។

| | | |
|---|---|---|
| («កម្មសិទ្ធ») («ម្ចាស់») លោកអ័ប្រាហាំគឺជាឪពុករបស់លោកអ៊ីសាក។ | אַבְרָהָם אֲבִי יִצְחָק | אָב ← אֲבִי |
| («កម្មសិទ្ធ») («ម្ចាស់») អេសាវ គឺជាបងប្រុសរបស់យ៉ាកុប។ | עֵשָׂו אֲחִי יַעֲקֹב | אָח ← אֲחִי |
| («កម្មសិទ្ធ») («ម្ចាស់») សារ៉ា គឺជាប្រពន្ធរបស់លោកអ័ប្រាហាំ។ | שָׂרָה אֵשֶׁת אַבְרָהָם | אִשָּׁה ← אֵשֶׁת |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ចំណាំថាពាក្យខ្លះផ្លាស់ប្តូរអក្ខរាវិរុទ្ធនៃស្រៈរបស់វាបន្តិច នៅពេលវាជាទម្រង់ផ្សារភ្ជាប់ ( “construct form” ) ប៉ុន្តែការបញ្ចេញសំឡេងមិនផ្លាស់ប្តូរទេ។

| | | |
|---|---|---|
| ដាវីឌគឺជាកូនប្រុសរបស់អ៊ីសាយ។ | דָּוִד בֶּן־יִשַׁי | בֵּן ← בֶּן |
| រ៉ាជែលគឺជាប្អូនស្រីរបស់លេអា។ | רָחֵל אֲחוֹת לֵאָה | אָחוֹת ← אֲחוֹת |

នាមដែលស្ថិតនៅខាងមុខ “ម្ចាស់” របស់វាជាទំរង់ផ្សារភ្ជាប់ ប៉ុន្តែពាក្យមួយចំនួន (ឧ. אֵם និង בַּת) អត់ផ្លាស់ប្តូរការសរសេររបស់វា។
ការសរសេររបស់ពាក្យទាំងនេះដូចគ្នានឹងការសរសេររបស់ទំរង់ធម្មតា (ហៅថា "ទម្រង់ពេញលេញ" absolute form)។

| | | |
|---|---|---|
| សារ៉ា គឺជាម្តាយរបស់អ៊ីសាក | שָׂרָה אֵם יִצְחָק׃ | אֵם ← אֵם |
| តើអ្នកគឺជាកូនស្រីរបស់នរណា? (បើបកប្រែត្រង់៖ «កូនស្រីរបស់អ្នកណាអ្នក?») | בַּת־מִי אַתְּ׃ | בַּת ← בַּת |
| យ៉ាកុប(គឺជា)ប្តីរបស់លេអា។ | יַעֲקֹב אִישׁ לֵאָה׃ | אִישׁ ← אִישׁ |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

សូមចំណាំថា ទោះបីជាពាក្យ אָחוֹת (*aħot* «បងប្អូនស្រី») បញ្ចប់ដោយ וֹת- ( *-ot*) វាគឺជាឯកវចនៈ មិនមែនពហុវចនៈនោះទេ។[7]

## 5.3 **ព្យញ្ជនៈដែលមានការបញ្ចេញសម្លេងពីរយ៉ាង**

យើងបានឃើញនៅក្នុងផ្នែក 3.2 ព្យញ្ជនៈ “បេហ្គាដកេហ្វាត” (*begadkefat*) ពីរ គឺ៖ פּ («ព») និង כּ («ក-ខ») ។ ព្យញ្ជនៈ “បេហ្គាដកេហ្វាត” មានការផ្លាស់ប្តូរសម្លេងរបស់វា នៅពេលណាវានៅក្នុងបរិបទមួយចំនួន ហើយក្លាយជាព្យញ្ជនៈបែប “fricative” (ព្យញ្ជនៈដែលមានការកកិតខ្លស់) ឧ. פּ («ព») និង כּ («ក-ខ») ក្លាយទៅជា פ (*f* «ហ្វ») and כ ($\chi$ «ក្ស») ។ នៅក្នុងមេរៀននេះ យើងឃើញព្យញ្ជនៈ “បេហ្គាដកេហ្វាត” មួយទៀត គឺ בּ («ប») ដែលអាចមានការផ្លាស់ប្តូរដូចគ្នា៖ បន្ទាប់ពីអក្សរ «-ו» វាបាត់ dagesh ហើយក្លាយទៅជា ב ដែលត្រូវបានបញ្ចេញសម្លេង «v» («វ»)។

| | | | | | | |
|---|---|---|---|---|---|---|
| ខ | כּ | p | פּ | ព | בּ | ព្យញ្ជនៈបែប «*Stops*» ដែលមាន *dagesh* |
| χ | כ | f | פ | v | ב | ព្យញ្ជនៈបែប «*Fricative*» ដែលគ្មាន *dagesh* |

ព្យញ្ជនៈ ב គឺជាព្យញ្ជនៈ “labial” [8] មួយ ដូច្នេះវាធ្វើអោយឈ្នាប់ -וְ ( “və-” ) ផ្លាស់ប្តូរទៅ וּ ( “u-” ) ដូចគ្នានឹងអ្វីដែលយើងបានឃើញហើយនៅក្នុងផ្នែក 3.1 ។

---

[7] ក្នុងព្រះគម្ពីរសញ្ញាចាស់ អត់ដែលមានពាក្យ אָחוֹת (*aħot* «ប្អូនស្រីម្នាក់» ឬ «បងស្រីម្នាក់») ជាទម្រង់ពេញលេញ (absolute form) ប៉ុន្តែជាការប៉ាន់ស្មានថា នេះជាការសរសេរ៖ אֲחֹת «បងប្អូនស្រី»។

[8] កំណត់ត្រាបកប្រែ៖ ព្យញ្ជនៈ “Labial” មានន័យថា ព្យញ្ជនៈដែលបញ្ចេញសម្លេងដោយបបូរមាត់។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | | |
|---|---|---|---|
| וּבֵן | בֵּן | וּבַת | בַּת |
| u-ven | ben | u-vat | bat |
| និងកូនប្រុសម្នាក់ | កូនប្រុសម្នាក់ | និងកូនស្រីម្នាក់ | កូនស្រីម្នាក់ |

## 5.4 សញ្ញាម៉ាកាហ្វ ( *Maqqef*)

ជួនកាល ពាក្យមួយចំនួនត្រូវបានសរសេរភ្ជាប់ជាមួយសញ្ញារបារមួយ (־) ដែលហៅថា *maqqef*។ វាភ្ជាប់ពីរពាក្យ ហើយសម្គាល់ថា ពាក្យទាំងពីរនោះ ជាពាក្យតែមួយដែលមានការសង្កត់សំឡេងតែមួយ។ វាមិនសូវប៉ះពាល់ដល់អត្ថន័យ ឬការបញ្ចេញសំឡេងទេ។ ជារឿយៗវាជាជម្រើសនៅក្នុងព្រះគម្ពីរហេព្រើរ ឧ. «ស្ដេចអ៊ីស្រាអែល» ជួនកាលមាន («מֶֽלֶךְ־יִשְׂרָאֵל» ដូចជា អេសាយ 44:6) ជួនកាលគ្មាន («מֶֽלֶךְ יִשְׂרָאֵל» ដូចជា ១សាំ. 24:14)។ ដូច្នេះនៅក្នុងមេរៀនទាំងនេះ យើងដាក់សញ្ញា *maqqef* ឬអត់ វាអស្រ័យទៅលើ តើព្រះគម្ពីរសញ្ញាចាស់ដាក់សញ្ញា *maqqef* ជាមួយពាក្យមួយនោះច្រើនជាងអត់។

## សេចក្ដីពន្យល់បន្ថែម




| | |
|---|---|
| מִי?... | តើអ្នកណា...? |
| אֵינֶנִּי יֹדַעַת | ខ្ញុំមិនដឹងទេ |
| גַּם | «ដែរ» ឬ «ក៏...ផងដែរ» |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 6 - ធ្នាក់និង ទីតាំង




## 6.1 ធ្នាក់

នៅក្នុងមេរៀននេះ យើងរៀនធ្នាក់មួយចំនួន ដែលបញ្ជាក់ពីទីតាំងរបស់កម្មវត្ថុមួយ ទាក់ទងទៅនឹងកម្មវត្ថុមួយទៀត។ ភាសាហេព្រើមានធ្នាក់បីដែលខ្លីបំផុត គឺ לְ כְּ בְּ ។ ធ្នាក់ទាំងបីនេះ វាមានព្យញ្ជនៈតែមួយដែលនៅជាប់ទៅនឹងពាក្យដែលនៅពីក្រោយវា ហើយវាមិនអាចបំបែកចេញពីពាក្យដែលនៅពីក្រោយ បានទេ។ ដោយហេតុផលនោះ គេតែងតែហៅថា «ធ្នាក់ដែលនៅជាប់នឹងនាម» (inseparable preposition)។ ធ្នាក់ -בְּ អាចមានអត្ថន័យច្រើន ប៉ុន្តែក្នុងឧទាហរណ៍ដែលយើងលើកឡើងក្នុងមេរៀននេះ វាមានន័យថា "ក្នុង" ('in') ឬ "លើ" ('on')។ ដូចដែលយើងនឹងឃើញបន្ថែមទៀតនៅក្នុងមេរៀនបន្ទាប់ដែរ ធ្នាក់ដែលមានព្យញ្ជនៈតែមួយទាំងនេះ វាផ្សំជាមួយស្រៈនៃ article ជាក់លាក់ (definite article) -הַ នៅពេលដែលវាកើតឡើងជាមួយគ្នា ដោយសារវានៅជាប់នឹងពាក្យតែមួយ។

ដូច្នេះ -בְּ បូក -הַ ក្លាយជា -בַּ ដូចនៅក្នុងពាក្យ בַּבַּיִת ( "នៅក្នុងផ្ទះ" ) ឬ בַּדֶּרֶךְ ( "ក្នុង/លើ/តាម ផ្លូវ" )។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

בְּ + הַ- + מִדְבָּר = בַּמִּדְבָּר

*ba-midbar* – "នៅក្នុងវាលរហោស្ថាន"

ធ្នាក់ (prepositions) ផ្សេងទៀត វាមិនមែនជាបុព្វបទនោះឡើយ (មិនមែននៅជាប់នឹងពាក្យក្រោយវាទេ)។ យ៉ាងណាក៏ដោយធ្នាក់ עַל- ជាធម្មតាត្រូវបានភ្ជាប់ជាមួយសញ្ញា *maqqef* ( "-" )។

<u>កំណត់ចំណាំ</u>៖ ដូចដែលបានពិភាក្សារួចហើយនៅក្នុងមេរៀន 4.2 ប្រយោគនៅក្នុងមេរៀននេះគឺគ្មានកិរិយាស័ព្ទ។ ក្នុងប្រយោគទាំងនេះ យើងបញ្ជាក់ពីទីតាំងនៃប្រធានបទ ដោយគ្រាន់តែភ្ជាប់កន្សោមមានធ្នាក់ជាមួយប្រធានបទ។ ប្រយោគបែបនេះមិនចាំបាច់មានកិរិយាស័ព្ទនោះទេ។

הָעֵץ לִפְנֵי הַפָּר
"សត្វពពែ(នៅចំ)ពីមុខគោបា"

## 6.2 កិរិយាស័ព្ទបង្គាប់បញ្ជារ שִׂים

នៅក្នុងមេរៀននេះ យើងរៀនពី កិរិយាស័ព្ទដំបូង គឺពាក្យ שִׂים *sim* ( "ដាក់!" , 'put!' ) ដែលនៅក្នុងទម្រង់ បង្គាប់បញ្ជរ។ នៅក្នុងវីដេអូនេះ នាងបេត ប្រាប់លោកអាប់រ៉ាមឲ្យទុកដាក់គោរឬសេះនៅកន្លែងមួយចំនួន។

## 6.3 ពាក្យ -אֶת សម្គាល់ពីកម្មបទផ្ទាល់ជាក់លាក់ ( definite direct objects )

នៅពេលដែលប្រយោគមួយមានកម្មបទផ្ទាល់ជាក់លាក់ (definite)[9] ជាធម្មតាភាសាហេព្រើរសម្គាល់កម្មបទមួយនោះ ដោយដាក់ពាក្យ אֶת- នៅខាងមុខវា។ បុព្វបទនេះគឺវាមានអត្ថន័យជាវេយ្យាករណ៍សុទ្ធសាធ

[9] យើងរាប់ពាក្យណាមួយជាពាក្យ "ជាក់លាក់" (definite) គឺនៅពេលដែល ៖

1. វាមាន article ជាក់លាក់ (definite article) -ה
2. វាជានាមអសាធារណ: (proper noun ឧ. ពាក្យជាឈ្មោះ) ឬក៏
3. វាមានបច្ច័យនៃកម្មសិទ្ធ (possessive suffix)។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ដែលមិនអាចបកប្រែជាភាសាអង់គ្លេសឬខ្មែរបានទេ។ ដូចគ្នានឹងធ្នាក់ ־עַל  ដែរ ពាក្យ ־אֶת ជាធម្មតាត្រូវបានភ្ជាប់ទៅពាក្យខាងក្រោមដោយសញ្ញា *maqqef* ( ־ ) ប៉ុន្តែពេលខ្លះវាលេចឡើងដោយខ្លួនឯងថាជា אֵת។

សូមកត់សម្គាល់ពីភាពខុសគ្នារវាងប្រយោគក្នុងប្រអប់ 1 និងប្រយោគក្នុងប្រអប់ 3។ ប្រយោគក្នុងប្រអប់ 1 វាមានកម្មបទផ្ទាល់ដែលមិនជាក់លាក់ ( פָּרָה 'គោមួយ') ប៉ុន្តែប្រយោគក្នុងប្រអប់ 3 វាមានកម្មបទផ្ទាល់ជាក់លាក់ (אֶת־הַפָּרָה 'គោ [មួយនោះ]') ។

| | | |
|---|---|---|
| ចូរដាក់គោ[មួយ]នៅខាងក្រោយផ្ទះចុះ | שִׂים פָּרָה אַחֲרֵי הַבַּיִת׃ | 1 |
| ទេ គោនេះគឺនៅលើផ្ទះ។ | לֹא, הַפָּרָה הַזֹּאת עַל־הַבַּיִת׃ | 2 |
| ចូរដាក់គោ[មួយនេះ]នៅខាងក្រោយផ្ទះចុះ | שִׂים אֶת־הַפָּרָה אַחֲרֵי הַבַּיִת׃ | 3 |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 7 - អក្សរក្រម វគ្គទី 1

នៅក្នុងមេរៀននេះ យើងរៀនព្យញ្ជនៈប្រាំពីរនៃអក្សរក្រមហេព្រើរ និងស្រៈបួន (ហៅថា «*niqqud*»)។ ភាសាហេព្រើរត្រូវបានសរសេរពីស្តាំទៅឆ្វេង ហើយដើមឡើយត្រូវបានសរសេរដោយតែអក្សរព្យញ្ជនៈប៉ុណ្ណោះ។ សម្រាប់ភាសាហេព្រើរ យើងសរសេរស្រៈនៅខាងលើនិងខាងក្រោមព្យញ្ជនៈ។ ជូនជាតិហេព្រើរចាប់ផ្តើមសរសេរស្រៈបែបនេះ គឺនៅក្នុងអំឡុងសតវត្សចុងក្រោយនៃសហវត្សទី១ គ.ស.។

នៅក្នុងមេរៀនរបស់យើង ជាញឹកញាប់យើងនឹងពន្យល់ការបញ្ចេញសំឡេងតាមរយៈ «អក្សរក្រមសូរសព្ទអន្តរជាតិ» (IPA)។ ប្រសិនបើអ្នកមិនស្គាល់ជាមួយ IPA អ្នកអាចស្តាប់ពីរបៀបដែលនិមិត្តសញ្ញានីមួយៗមានសំឡេងនៅ internationalphoneticalphabet.org។

## 7.1 ព្យញ្ជនៈមួយចំនួន

- *Aleph* א
- *Bet* ב
- *Yod* י
- *Tav* תּ
- *Shin* שׁ
- *He* ה
- *Vav* ו

## 7.2 ស្រៈមួយចំនួន

- *Qamets* ◌ָ
- *Hireq* ◌ִ
- *Pataḥ* ◌ַ
- *Shewa* ◌ְ

## 7.3 ការសរសេរ Article ជាក់លាក់

Article ជាក់លាក់ (definite article, បុព្វបទ -הַ) វាសរសេរដោយព្យញ្ជនៈ *he* និងស្រៈ *pataḥ* ហើយវាក៏ តំរូវឲ្យយើងបញ្ចេញសម្លេងនៃព្យញ្ជនៈបន្ទាប់ "ទ្វេដង" (សម្គាល់វាដោយចំនុចមួយ ដែលយើងហៅថា "សញ្ញា *dagesh*")។

הַ- + מִדְבָּר = הַמִּדְבָּר

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

הַשֵּׁם = שֵׁם + הַ-

យ៉ាងណាក៏ដោយ ភាសាហេព្រើរមានព្យញ្ជនៈខ្លះដែលមិនដាក់សញ្ញា *dagesh* បានទេ។ ក្នុងចំណោមព្យញ្ជនៈបែបនេះ មាន ע א ហើយនិង ר។ នៅពេលដែល הַ- នៅខាងមុនពាក្យដែលចាប់ផ្តើមដោយព្យញ្ជនៈបីនេះ នោះស្រៈ *pataḥ* "បន្លាយទៅជា" ( “lengthens” ) *qamets* ។ ឧ. នៅក្នុងមេរៀននេះ មានពាក្យមួយចំនួនដែលមាន article ជាក់លាក់ (definite article) ហើយក៏ចាប់ផ្តើមដោយព្យញ្ជនៈ א។ សម្រាប់ពាក្យបែបនេះ article ជាក់លាក់របស់វា មានស្រៈ *qamets* ( הָ- ) ដូចនៅក្នុងពាក្យ הָאִישׁ។ នេះមិនប៉ះពាល់ដល់ការបញ្ចេញសំឡេងទេ វាគ្រាន់តែជាច្បាប់ប្រកបប៉ុណ្ណោះ។
យើងសូមណែនាំដើម្បីកុំឱ្យអ្នកខ្វល់ខ្វាយអំពីការទន្ទេញចាំច្បាប់ឥឡូវនេះ ដោយគ្រាន់តែអាចស្គាល់ הַ- និង הָ- ជា article ជាក់លាក់ នៅពេលអ្នកឃើញវា។

ដូចគ្នានឹងអ្វីដែលយើងបានពិភាក្សាក្នុងមេរៀន 6.1 ធ្នាក់ដែលមានព្យញ្ជនៈតែមួយ ( “inseparable prepositions” ) ក៏ផ្លាស់ប្តូរបន្តិចដែរ នៅពេលណាវានៅជាប់នឹង article។ ធ្នាក់ដែលមានព្យញ្ជនៈតែមួយ រួមបញ្ចូលគ្នាជាមួយស្រៈ *pataḥ* របស់ הַ-។ ដូច្នេះធ្នាក់ בְּ- បូក הַ- ក្លាយជា בַּ- ឧ. នៅក្នុងពាក្យ בַּבַּיִת៖

בַּבַּיִת = בַּיִת + הַ- + בְּ-

“នៅក្នុងផ្ទះ”

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 8 - អវយវៈនៃរាងកាយ

## 8.1 **ទម្រង់គូ ( “dual form” )**

នាមភាគច្រើនលេចឡើងជាទម្រង់ពីរ៖ ឯកវចនៈ (១) និងពហុវចនៈ (២ ឬច្រើន)។ ទោះយ៉ាងណាក៏ដោយ ពាក្យមួយចំនួននៅក្នុងភាសាហេព្រើរមាន «ទម្រង់គូ» (“dual form”) ដែលបញ្ជាក់ថា នាមមួយនេះមានចំនួនពីរ (2)។
មាននាមខ្លះដែលអាចលេចឡើងជាទម្រង់គូ ឬ ទម្រង់ពហុវចនៈ តែមាននាមខ្លះដែលលេចឡើងជាទម្រង់គូតែប៉ុណ្ណោះ ដែលអត់មានទម្រង់ពហុវចនៈ ជាពិសេសរបស់ដែលមកជាគូ ឧ. ភ្នែក ត្រចៀក ហើយ ដៃ ហើយនឹងជើង។
ទម្រង់គូនេះត្រូវបានសម្គាល់ដោយបច្ច័យ *-ayim* ַיִם។

| | ទម្រង់គូ | | | ទម្រង់ឯកវចនៈ | |
|---|---|---|---|---|---|
| ភ្នែកពីរ | עֵינַיִם *ʿenayim* | 👁️ 👁️ | ភ្នែកមួយ | עַיִן *ʿayin* | 👁️ |
| ត្រចៀកពីរ | אָזְנַיִם[10] *ʾoznayim* | 👂🏽 👂🏽 | ត្រចៀកមួយ | אֹזֶן *ʾozen* | 👂🏽 |
| ដៃពីរ | יָדַיִם *yadayim* | ✋🏽 ✋🏽 | ដៃមួយ | יָד *yad* | ✋🏽 |
| ជើងពីរ | רַגְלַיִם *raglayim* | 🦵🏽 🦵🏽 | ជើងមួយ | רֶגֶל *regel* | 🦵🏽 |

[10] នៅពេលណាស្រះ *qamets* ( ָ ) ជាព្យាង្គដែលបិទ ( “closed” ) ហើយគ្មានការសង្កត់សម្លេង ( “unaccented” ) នោះគេបញ្ចេញ [o] ជាជាង [a]។ ដូច្នេះពាក្យនេះអានថា “*oznayim*”។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | | | | |
|---|---|---|---|---|---|
| បាតដៃពីរ | כַּפַּיִם *kappayim* | 🤲🏾 | បាតដៃមួយ | כַּף *kaf* | ✋🏾 |

## 8.2 នាមដែលលេចឡើងតែក្នុងទម្រង់ជាពហុវចនៈ

នាមខ្លះលេចឡើងតែក្នុងទម្រង់ជាពហុវចនៈ ដែលគ្មានទម្រង់ឯកវចនៈ ឧ. ពាក្យ *panim* פָּנִים ( ‘មុខ’ ) ក្នុងមេរៀននេះ។ ដូច្នេះ פָּנִים អាចសំដៅទៅលើ មុខតែមួយ (ឯកវចនៈ) ឬ មុខច្រើន (ពហុវចនៈ) អាស្រ័យលើបរិបទ។

## 8.3 នាមជាទម្រង់ផ្សាភ្ជាប់

នៅក្នុងផ្នែកចុងក្រោយនៃវីដេអូនេះ គ្រប់ផ្នែករាងកាយដែលលេចឡើងជាមួយ “ម្ចាស់” របស់វា ដូចជា סוּס רֶגֶל (“*regel sus”* ដែលមានន័យថា «ជើងសេះ») ឬ בֶּטֶן אִשָּׁה

( “*beten ishah*” ដែលមានន័យថា “ពោះរបស់ស្ត្រី”) គឺនៅក្នុងទម្រង់ផ្សារភ្ជាប់។ យ៉ាងណាក៏ដោយ ពាក្យបែបនេះដែលនៅក្នុងទម្រង់ផ្សាភ្ជាប់

មានសម្លេងនិងការប្រកបដូចគ្នានឹងទម្រង់ពេញលេញរបស់វា លើកលែងតែពាក្យ יָד (“*yad*” “ដៃ”) ដែលផ្លាស់ប្តូរការប្រកបរបស់វាទៅជា יַד ក្នុងទម្រង់ផ្សារភ្ជាប់ (ប៉ុន្តែវានៅតែមានសំឡេងដដែល)។ នៅក្នុងមេរៀនទី 11 យើងនឹងសិក្សាបន្ថែមអំពីទម្រង់ផ្សារភ្ជាប់។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 9 - ឈ្មោះនិង អាក្រក់

## 9.1 រំលឹកអំពីបច្ច័យកម្មសិទ្ធ

នៅក្នុងមេរៀននេះ យើងពិនិត្យឡើងវិញនូវបច្ច័យកម្មសិទ្ធិ (“possessive suffixes” ឬ “pronominal suffixes”) ដែលភ្ជាប់ទៅនឹងពាក្យ שֵׁם (“ឈ្មោះ”)
ដូចនឹងអ្វីដែលយើងរៀននៅក្នុងមេរៀន 5.1។ សូមចាំថា ឈ្នាប់ -ךָ ក្លាយជា -ךְ
នៅពីមុខពាក្យណាដែលមានមានស្រៈ *shewa* នៅក្រោមព្យញ្ជនៈដំបូង។ ឧ.៖

| | |
|---|---|
| רוּת וּשְׁמָהּ נָעֳמִי שְׁמָהּ | מִי הֵנָּה: |
| ឈ្មោះរបស់នាង[នេះគឺ] រស់ និងឈ្មោះរបស់នាង[នោះគឺ] ណាអូមី[11] | តើពួកគេ(ភេទស្រី) ជានរណា? |

## 9.2 ពាក្យ דָּבָר

ជាទូទៅ ពាក្យ דָּבָר មានន័យថា “វត្ថុ” ឬ “ពាក្យ”។ នៅក្នុងមេរៀននេះ យើងប្រើពាក្យនេះក្នុងន័យបី៖

1. “វត្ថុ” ដែលរូបិយ (យើងមើលឃើញ)
2. “ពាក្យ” ឬ “ព្រះបន្ទូល”
3. “រឿង” ឬ “ការ” (សំដៅទៅលើ បញ្ហា ស្ថានភាព ឬ កិច្ចការ ណាមួយ)។

---

[11] នៅក្នុងមេរៀនក្រោយៗ ទៀត យើងនឹងរៀបរាប់ពីមូលហេតុ ដែលយើងបញ្ចេញសម្លេង [o] ក្នុងករណីពិសេសពីរយ៉ាង៖

1. នៅពេលដែល ស្រៈ *qamets hatuf* ( ָ) ជាព្យាង្គដែលបិទ ( “closed” ) ហើយគ្មានការសង្កត់សម្លេង ( “unaccented” )
2. *ḥaṭef qamets* ( ֳ)

ដូច្នេះហើយបានជាឈ្មោះ “ណាអូមី” (נָעֳמִי) ជាភាសាហេព្រើរគឺថា No’ omi [noʕo'mi] ហើយនឹង ឈ្មោះ “កូលីយ៉ាត” (גָּלְיָת) ជាភាសាហេព្រើរគឺថា Goliat [gol'jat] ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

រីឯនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពាក្យ « דָּבָר» មានអត្ថន័យដូចជាលេខពីរ និងលេខបីច្រើនជាង។

| | | |
|---|---|---|
| តើវត្ថុនេះគឺជាអ្វី?<br>វត្ថុនេះគឺជាពាងមួយ។ | מָה־הַדָּבָר הַזֶּה:<br>הַדָּבָר הַזֶּה כַּד: | 1 |
| "ផ្ទះ" "បុរស" "ឪពុក" ទាំងនេះគឺជាពាក្យ។ | בַּיִת, הָאִישׁ, אָב, אֵלֶּה דְּבָרִים: | 2 |
| [បុរសពីរនាក់កំពុងប្រយុទ្ធគ្នាដោយសារពួកគាត់ខឹង]<br>តើការនេះល្អទេ?<br>ទេ ការនេះពិតជាអាក្រក់ណាស់ | הֲטוֹב הַדָּבָר הַזֶּה:<br>לֹא, הַדָּבָר הַזֶּה רַע מְאֹד: | 3 |

## 9.3 គុណនាម "ល្អ" និង "អាក្រក់"

នៅក្នុងមេរៀននេះ យើងបានរៀនគុណនាមចំនួន២ គឺពាក្យ "טוֹב" ("ល្អ") និងពាក្យ "רַע" ("អាក្រក់")។

| | ភេទស្រី | | ភេទប្រុស | |
|---|---|---|---|---|
| ឯកវចនៈ | ស្រ្តីល្អ | אִשָּׁה טוֹבָה | បុរសល្អ | אִישׁ טוֹב |
| | ទឹកដីអាក្រក់ | אֶרֶץ רָעָה | ការអាក្រក់ | דָּבָר רַע |
| ពហុវចនៈ | ស្រ្តីល្អៗ | נָשִׁים טוֹבוֹת | ការល្អៗ | דְּבָרִים טוֹבִים |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | |
|---|---|---|
| | ស្ត្រីអាក្រក់ៗ נָשִׁים רָעוֹת | ការអាក្រក់ៗ דְּבָרִים רָעִים |

## 9.4 បុព្វបទសំណួរ ដែលសួរពី "បាទ-ទេ" ( “Yes-No questions” )

របៀតមកដល់ពេលនេះ យើងបានឃើញសំណួរជាច្រើន ដែលប្រើពាក្យ מִי («តើ...អ្នកណា?») ឬ מָה («តើ...អ្វី?») ។ ឧ. מִי הֵם (“តើពួកគេជានរណា?”) និង מָה־זֶּה “តើនេះគឺជាអ្វី?”

ដើម្បីសួរសំណួរ "បាទ-ទេ" (“Yes-No questions”) ជាធម្មតាត្រូវមានបុព្វបទ -הֲ នៅជាប់នឹងពាក្យដើមនៃប្រយោគសំណួរ ឧ.៖

הֲטוֹבִים הַדְּבָרִים הָאֵלֶּה: טוֹבִים הֵם:

តើរបស់ទាំងនេះល្អទេ? របស់ទាំងនេះល្អ

យើងអាចបកប្រែពាក្យ «-הֲ» ទៅជា «តើ...ដែរឬទេ?»។

បុព្វបទសំណួរ - הֲស្តាប់ទៅដូចជា article ជាក់លាក់ (“definite article”) -הַ
ប៉ុន្តែជាធម្មតាយើងអាចសម្គាល់បុព្វបទសំណួរ - הֲតាមរយៈ ស្រៈ ḥaṭef pataḥ (ֲ)។
ជាទូទៅយើងក៏អាចវែកញែកបុព្វបទទាំងពីរនេះ តាមរយៈបរិបទ៖ បុព្វបទសំណួរ - הֲ តែងតែភ្ជាប់ទៅនឹងពាក្យដើមនៃ “សំណួរ បាទ-ទេ” (yes-no question)។

## 9.5 *Hinneh* הִנֵּה

ក្នុងភាសាហេព្រើរ គេប្រើពាក្យ הִנֵּה
ដើម្បីនាំឲ្យអ្នកស្តាប់យកចិត្តទុកដាក់ទៅលើអ្វីដែលគេរៀបនឹងនិយាយ។
ភាគច្រើនយើងបកប្រែថា “មើល ...”។

| | |
|---|---|
| “មើល (ទីនេះ)! មនុស្សទាំងនេះ...” | הִנֵּה הָאֲנָשִׁים הָאֵלֶּה |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 10 - អក្សរក្រម វគ្គទី 2

មេរៀននេះផ្តោតទៅលើ ព្យញ្ជនៈបីទៀត និងស្រៈ (*“niqqud”*) បីទៀត ។

## 10.1 ព្យញ្ជនៈមួយចំនួន

- *Resh* ר
- *Dalet* ד
- *Mem* ם מ ព្យញ្ជនៈ מ មានទម្រង់ពីរ៖ នៅពេលដែលវានៅដើមពាក្យ ឬ នៅកណ្តាលពាក្យគឺ מ ប៉ុន្តែនៅពេលដែលវាប្រើនៅចុងពាក្យ គឺ ם (*mem sofit*)។

## 10.2 ស្រៈមួយចំនួន

- *Holem* ֹ
- *Tsere* ֵ
- *Shewa* ְ

## 10.3 សញ្ញាម៉ាកាហ្វ ( *Maqqef*) - រំលឹកពីមេរៀន 5.4

ជួនកាល ពាក្យមួយចំនួនត្រូវបានសរសេរភ្ជាប់ជាមួយសញ្ញារបារមួយ (־) ដែលហៅថា *maqqef*។ វាភ្ជាប់ពីរពាក្យ ហើយសម្គាល់ថា ពាក្យទាំងពីរនោះ ជាពាក្យតែមួយដែលមានការសង្កត់សំឡេងតែមួយ។ វាមិនសូវប៉ះពាល់ដល់អត្ថន័យ ឬការបញ្ចេញសំឡេងទេ។ ជារឿយៗវាជាជម្រើសនៅក្នុងព្រះគម្ពីរហេព្រើរ ឧ. «ស្តេចអ៊ីស្រាអែល» ជួនកាលមាន («מֶלֶךְ־יִשְׂרָאֵל» ដូចជា អេសាយ 44:6) ជួនកាលគ្មាន («מֶלֶךְ יִשְׂרָאֵל» ដូចជា ១សាំ. 24:14)។ ដូច្នេះនៅក្នុងមេរៀនទាំងនេះ យើងដាក់សញ្ញា *maqqef* ឬអត់ វាអស្រ័យទៅលើ តើព្រះគម្ពីរសញ្ញាចាស់ដាក់សញ្ញា *maqqef* ជាមួយពាក្យមួយនោះច្រើនជាងអត់។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 11 - ទម្រង់ផ្សាភ្ជាប់

## 11.1 ទម្រង់ពហុវចនៈសម្រាប់ពាក្យកូនប្រុសនិងកូនស្រី

ទម្រង់ពហុវចនៈនៃពាក្យសម្រាប់គ្រួសារ בֵּן (“កូនប្រុស”) និង בַּת (“កូនស្រី”) គឺ៖

בָּנִים (*banim* “កូនប្រុសៗ”) 👦🏽👦🏽👦🏽

בָּנוֹת (*banot* “កូនស្រីៗ”) 👧🏽👧🏽👧🏽

## 11.2 ទម្រង់ផ្សាភ្ជាប់

ដូចដែលបានណែនាំដោយសង្ខេបក្នុងមេរៀន 5.2 ជាភាសាហេព្រើរ ទម្រង់ផ្សាភ្ជាប់ជាទូទៅមានអត្ថន័យស្រដៀងគ្នានឹងធ្នាក់ជាភាសាខ្មែរ “នៃ” ឬ “របស់” (“of” ជាភាសាអង់គ្លេស)។ នៅក្នុងភាសាផ្សេងទៀត ដូចជាភាសាក្រិកអាចហៅវាថា “genitive”។ បើសិនជាមានទម្រោងផ្សាភ្ជាប់លើសពីមួយ ជាធម្មតាយើងហៅថា «សង្វាក់នៃទម្រង់ផ្សាភ្ជាប់» ដូចឧទាហរណ៍ ១.៣ និង ១.៤ នៅខាងក្រោម។

| | | |
|---|---|---|
| אָב ← אֲבִי<br>ឪពុក ← ឪពុករបស់ | אֲבִי הַנַּעַר<br>ឪពុករបស់ក្មេងប្រុស | ១.១ |
| בֵּן ← בֶּן־<br>កូនប្រុស ← កូនប្រុសរបស់ | בֶּן־יוֹסֵף<br>កូនប្រុសរបស់យ៉ូសែប | ១.២ |
| בַּיִת ← בֵּית<br>ផ្ទះ ← ផ្ទះរបស់<br>אִשָּׁה ← אֵשֶׁת<br>ប្រពន្ធ ← ប្រពន្ធនៃ | בֵּית אֵשֶׁת הָאִישׁ<br>ផ្ទះរបស់ប្រពន្ធនៃបុរសនោះ | ១.៣ |
| בַּיִת ← בֵּית<br>אִשָּׁה ← אֵשֶׁת<br>בֵּן ← בֶּן־ | בֵּית אֵשֶׁת בֶּן־יוֹסֵף<br>ផ្ទះរបស់ប្រពន្ធកូនប្រុសយ៉ូសែប<br>(មានន័យថា «ផ្ទះរបស់កូនស្រីប្រសារយ៉ូសែប») | ១.៤ |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ចំណែកឯទម្រង់ពហុវចនៈ (-ִים) និងទម្រង់គូ (-ַיִם) ទាំងពីរផ្លាស់ប្តូរបញ្ចប់ដោយ -ֵי ជាទម្រង់ផ្សារភ្ជាប់។

| | | |
|---|---|---|
| בָּנִים ← בְּנֵי | בְּנֵי יוֹסֵף<br>កូនប្រុសៗរបស់យ៉ូសែប | ២.១ |
| נָשִׁים ← נְשֵׁי | נְשֵׁי יַעֲקֹב<br>ពួកប្រពន្ធរបស់យ៉ាកុប | ២.២ |
| אֹהָלִים ← אָהֳלֵי | אָהֳלֵי[12] אַבְרָהָם<br>តង់(ពហុ.)របស់អ័ប្រាហាំ | ២.៣ |
| עֵינַיִם ← עֵינֵי | עֵינֵי אַבְרָם<br>ភ្នែក(ពហុ.)របស់អាប់រ៉ាម | ២.៤ |

រីឯនាមណាដែលមានទម្រង់ពេញលេញបញ្ចប់ដោយ ָה
នឹងមានទម្រង់ផ្សារភ្ជាប់បញ្ចប់ដោយ ַת វិញ៖

| | | |
|---|---|---|
| פָּרָה ← פָּרַת | פָּרַת יוֹסֵף<br>មេគោរបស់យ៉ូសែប | ៣.១ |

ម៉្យាងទៀតនាមពហុវចនៈណាដែលមានទម្រង់ពេញលេញបញ្ចប់ដោយ וֹת-
ជាធម្មតាយើងត្រូវបញ្ចេញសម្លេងស្រៈឲ្យខ្លីសម្រាប់ទម្រង់ផ្សារភ្ជាប់៖

---

[12] នៅពេលណាស្រៈ *qamets* ( ָ ) ជាព្យាង្គដែលបិទ ( "closed" ) ហើយគ្មានការសង្កត់សម្លេង ( "unaccented" ) នោះគេបញ្ចេញ [o] ជាជាង [a]។ សូមមើលមេរៀន 9.1 ទំព័រ 36 លេខយោង 11។ ហេតុនេះហើយបានជាពាក្យ אָהֳלֵי គឺបញ្ចេញសម្លេងជា "*oholey*" [ʔohoˈle]។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | |
|---|---|---|
| בָּנוֹת ← בְּנוֹת | בְּנוֹת יוֹסֵף<br>កូនស្រីៗរបស់យ៉ូសែប | ៥.១ |

រីឯភាពជាក់លាក់ (“definiteness”) នៃទម្រង់ផ្សារភ្ជាប់ គឺវាអាស្រ័យទៅលើភាពជាក់លាក់ (“definiteness”) នៃនាមខាងក្រោយនៅក្នុងសង្វាក់នៃទម្រង់ផ្សាភ្ជាប់ (“construct chain”)។ បើសិនជានាមខាងក្រោយមិនជាក់លាក់ (“indefinite”)
នោះសង្វាក់នៃទម្រង់ផ្សាភ្ជាប់ទាំងមូលក៏មិនជាក់លាក់ដែរ (ដូចនៅក្នុងឧ. ៥.១)។
បើសិនជានាមខាងក្រោយជាក់លាក់ (“definite”)
នោះសង្វាក់នៃទម្រង់ផ្សាភ្ជាប់ទាំងមូលក៏ជាក់លាក់ដែរ (ដូចនៅក្នុងឧ. ៥.២ និង ៥.៣)។

| | | | |
|---|---|---|---|
| ផ្ទះរបស់បុរសម្នាក់<br>(មិនជាក់លាក់) | בֵּית אִישׁ | ៥.១ | 🧍🏠 |
| ផ្ទះរបស់បុរសម្នាក់នោះ<br>(បុរសជាក់លាក់<br>ដូច្នេះផ្ទះក៏ជាក់លាក់ដែរ) | בֵּית הָאִישׁ | ៥.២ | |
| ផ្ទះរបស់អ័ប្រហាំ<br>(ឈ្មោះតែងតែជាក់លាក់<br>ដូច្នេះផ្ទះក៏ជាក់លាក់ដែរ) | בֵּית אַבְרָהָם | ៥.៣ | |

កំណត់ចំណាំ៖ នាមអសាធារណៈ (មានដូចជាឈ្មោះមនុស្សឬឈ្មោះទីកន្លែង) គឺមានលក្ខណៈជាក់លាក់ហើយ ដូចជាឧទាហរណ៍ ៥.៣ នៅខាងលើ។

សូមបញ្ជាក់ថា មានតែនាមខាងក្រោយដែលអាចមាន article ជាក់លាក់ (“definite article”) -הַ ។ ដូច្នេះឧទាហរណ៍ ៥.៤ នៅខាងក្រោម មិនត្រឹមត្រូវទេ វាគួរតែជាដូចជាឧទាហរណ៍ ៥.២ នៅខាងលើវិញ។

| | | |
|---|---|---|
| ផ្ទះរបស់បុរសម្នាក់នោះ | הַבֵּית הָאִישׁ*<br>មិនត្រឹមត្រូវ<br>! | ៥.៤ |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

### 11.3 ល្អឬអាក្រក់នៅក្នុងភ្នែករបស់... 👁️👁️

ក្នុងភាសាហេព្រើរ យើងបញ្ជាក់ថានរណាម្នាក់ពេញចិត្តអ្វីមួយ ឬមិនពេញចិត្តអ្វីមួយ ដោយប្រើពាក្យ“ល្អ/អាក្រក់នៅក្នុងភ្នែករបស់_______” (ឧ. លោក. 16:6; 19:8; 20:15; ជន. 36:6; ចោទ. 6:18; ចៅ. 19:24។ល។)។

| | | |
|---|---|---|
| តើអាប្រាំពេញចិត្តនឹងរឿងនេះទេ?<br>បកប្រែតាមពាក្យ៖ «តើរឿងនេះល្អទេនៅក្នុងភ្នែករបស់អាប្រាំ?» | הֲטוֹב הַדָּבָר הַזֶּה בְּעֵינֵי אַבְרָם׃ | ៦.១ |
| អាប្រាំមិនពេញចិត្តនឹងរឿងនេះទេ។<br>បកប្រែតាមពាក្យ៖ «រឿងនេះអត់ល្អទេនៅក្នុងភ្នែករបស់អាប្រាំ។» | לֹא טוֹב הַדָּבָר בְּעֵינֵי אַבְרָם׃ | ៦.២ |
| អាប្រាំឃើញថារឿងនេះមិនល្អសោះ។<br>បកប្រែតាមពាក្យ៖ «រឿងនេះអាក្រក់នៅក្នុងភ្នែករបស់អាប្រាំ» | רַע הַדָּבָר בְּעֵינֵי אַבְרָם׃ | ៦.៣ |

សូមមើលផ្ទាក់ -בְּ ដែលយើងឃើញនៅជាប់នឹងពាក្យ עֵינַיִם(“ភ្នែក”) ជាទម្រង់ផ្សាភ្ជាប់ក្នុងឧទាហរណ៍ខាងលើនេះ។ វាគ្មាន article ជាក់លាក់ទេ ដែលយើងអាចសម្គាល់បានដោយ វាអត់មានស្រៈនៃ article ជាក់លាក់នោះទេ (בְּעֵינֵי មិនមែន בָּעֵינֵי)។

យ៉ាងណាក៏ដោយពាក្យ «ភ្នែក» មានភាពជាក់លាក់ដដែល។ ដូចនឹងអ្វីដែលយើងបានពន្យល់នៅក្នុង 11.2 ភាពជាក់លាក់ (“definiteness”) នៃពាក្យ «ភ្នែក» នៅក្នុងល្បះ «ភ្នែករបស់អាប្រាំ» កើតចេញពីភាពជាក់លាក់នៃនាមខាងក្រោយរបស់សង្វាត់ទម្រង់ផ្សាភ្ជាប់(«អាប្រាំ»)។

# មេរៀនទី 12 - លេខ ១-៥

### 12.1 លេខ ១-៥

មេរៀននេះណែនាំឲ្យបានស្គាល់នូវចំនួនលេខ១ដល់៥។ ដូចគ្នានឹងគុណនាមដែរ នៅពេលដែលយើងប្រើភ្ជាប់ជាមួយនាម លេខមានលក្ខណៈជាភេទប្រុសផង និងភេទស្រីផង អាស្រ័យទៅលើភេទនាមដែលវានៅជាប់ជាមួយ។ នៅពេលដែលយើងរាប់ យើងប្រើជាទម្រង់បែបភេទស្រី។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | <u>ជាមួយនឹងនាមប្រុស៖</u> | <u>ជាមួយនឹងនាមស្រី៖</u> |
|---|---|---|
| 1 ◦ | אֶחָד *ʾeħad* | אַחַת *ʾaħat* |
| 2 ◦◦ | שְׁנַיִם *shənayim* | שְׁתַּיִם *shətayim* |
| 3 ◦◦◦ | שְׁלֹשָׁה *shəloshah* | שָׁלוֹשׁ *shalosh* |
| 4 ◦◦◦◦ | אַרְבָּעָה *ʾarbaʿah* | אַרְבַּע *ʾarbaʿ* |
| 5 ◦◦◦◦◦ | חֲמִשָּׁה *ħamishshah* | חָמֵשׁ *ħamesh* |

លេខអាចដាក់នៅខាងមុខឬខាងក្រោយនាមដែលវាបញ្ជាក់ន័យឲ្យ ប៉ុន្តែភាគច្រើនគេដាក់លេខ១ (אֶחָד ឬ אַחַת) នៅ<u>ខាងក្រោយ</u>នាម (ដូចនៅក្នុង ឧ. ១.១) ហើយដាក់លេខផ្សេងទៀតនៅ<u>ខាងមុខ</u>នាម (ដូចនៅក្នុង ឧ. ១.២ និង ១.៣) ។

| | | | |
|---|---|---|---|
| 🧍 | បុរសមួយនាក់ | אִישׁ אֶחָד | ១.១ |
| 🧍 🧍 🧍 | បុរសបីនាក់ | שְׁלֹשָׁה אֲנָשִׁים | ១.២ |
| 🧍 🧍 🧍 🧍 🧍 | បុរសប្រាំនាក់ | חֲמִשָּׁה אֲנָשִׁים | ១.៣ |

សម្រាប់លេខពី (שְׁתַּיִם) គេប្រើជាទម្រង់គូ។ ជាទូទៅ គេដាក់នៅខាងមុខនាមដែលវាបញ្ជាក់ន័យឲ្យ ហើយគេក៏ប្រើជាទម្រង់ផ្សាភ្ជាប់ (construct form) ដែរ។

| | | |
|---|---|---|
| ស្ត្រីក្មេងពីរនាក់ | שְׁתֵּי נְעָרוֹת | שְׁתַּיִם ← שְׁתֵּי |
| ប្រុសក្មេងពីរនាក់ | שְׁנֵי נְעָרִים | שְׁנַיִם ← שְׁנֵי |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

លេខជាភាសាហេព្រើរមានលក្ខណៈមិនប្រក្រតី។ ជាទូទៅ លក្ខណៈភេទស្រី គឺបញ្ចប់ដោយ ה ָ- រីឯទម្រង់ប្រុសគ្មានទេ។ ចំណែកឯទម្រង់លេខ គឺមានលក្ខណៈផ្ទុយពីខាងលើ ដូចជានៅក្នុងឧទាហរណ៍នៅខាងក្រោម៖

| | | | |
|---|---|---|---|
| סוּס אֶחָד | 🐎 | פָּרָה אַחַת | 🐄 |
| שְׁנֵי סוּסִים | 🐎🐎 | שְׁתֵּי פָּרוֹת | 🐄🐄 |
| שְׁלֹשָׁה סוּסִים | 🐎🐎🐎 | שָׁלוֹשׁ פָּרוֹת | 🐄🐄🐄 |
| אַרְבָּעָה סוּסִים | 🐎🐎🐎🐎 | אַרְבַּע פָּרוֹת | 🐄🐄🐄🐄 |
| חֲמִשָּׁה סוּסִים | 🐎🐎🐎🐎🐎 | חָמֵשׁ פָּרוֹת | 🐄🐄🐄🐄🐄 |

## 12.2 **កិរិយាសព្ទបញ្ជា** ( **Imperative verb** ) **קַח**

នៅក្នុងមេរៀននេះ យើងរៀនពីកិរិយាសព្ទមួយទៀត ដែលមានទម្រង់ជាកិរិយាសព្ទបញ្ជា קַח (*qaḥ*, “យកចុះ!”[13] នាង Beth (בֵּת) ប្រាប់លោកអាប់រ៉ាម אַבְרָם)) ឲ្យយកចំនួនគោ សេះ និង មនុស្ស។

## 12.3 **ទាំងអស់ (כֹּל / כָּל־)**

ពាក្យ כֹּל (ដែលភាគច្រើនគេសរសេរជា«כָּל־» ទាំងពីរអានថា *kol*[14]) មានន័យថា “ទាំងអស់” (ដូចនៅក្នុង ឧ. ២.១) “រាល់”/“និមួយៗ” (ដូចនៅក្នុង ឧ. ២.២) ឬ “ទាំងមូល” (ដូចនៅក្នុង ឧ. ២.៣)។

នៅក្នុងមេរៀននេះ ពាក្យនេះមានអត្ថន័យថា “ទាំងអស់” តែប៉ុណ្ណោះ៖ Beth ប្រាប់លោកអាប់រ៉ាម (אַבְרָם) ឲ្យយកសេះទាំងអស់ មនុស្សទាំងអស់ ។ល។

---

[13] ទម្រង់ «קַח» គឺ ភេទប្រុសឯកវចនៈ ដែលគេប្រើនៅពេលតែកំពុងតែនិយាយទៅកាន់មនុស្សប្រុសម្នាក់ ដូចលោក Avram នៅក្នុងវិដេអូនេះ)។ រីឯការនិយាយទៅកាន់មនុស្សស្រីម្នាក់ គេប្រើទម្រង់ស្រីឯកវចនៈ «קְחִי»។

[14] នៅពេលណាស្រៈ *qamets* ( ָ ) ជាព្យាង្គដែលបិទ ( “closed” ) ហើយគ្មានការសង្កត់សម្លេង ( “unaccented” ) នោះគេបញ្ចេញ [o] ជាជាង [a]។ សូមមើលមេរៀន 9.1 ទំព័រ 36 លេខយោង 11។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | |
|---|---|---|
| សេះទាំងអស់ (ឧ. លោក. 45:1) | כָּל־הַסּוּסִים | ២.១ |
| បុរសនិមួយៗ (ឧ. លោក. 7:19) | כָּל־אִישׁ | ២.២ |
| ផ្ទះទាំងមូល (ឪ. ១ពង. 6:22) | כָּל־הַבַּיִת | ២.៣ |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 13 - អក្សរក្រម វគ្គទី 3

## 13.1 ព្យញ្ជនៈមួយចំនួន

- *Lamed* ל
- *Nun* ן נ ព្យញ្ជនៈ נ មានទម្រង់ពីរ៖ នៅពេលដែលវានៅដើមពាក្យ ឬ នៅកណ្ដាលពាក្យគឺ נ ប៉ុន្តែនៅពេលដែលវាប្រើនៅចុងពាក្យ គឺ ן (*nun sofit*)។

## 13.2 ស្រៈមួយចំនួន

- *Segol* ֶ

*Vav* អាចប្រើជាព្យញ្ជនៈបាន (សូមមើលមេរៀនទី៧ និង ទី១០)។ នៅក្នុងមេរៀននេះ យើងរៀនថាអក្សរ *vav* អាចប្រើបានជាស្រៈពីរទម្រង់៖

- *Holem vav* וֹ (*ô*) ដែលមានសម្លេង «អូ» [o] ដូចជា «ដូរ»។
- *Shureq* וּ (*û*) ដែលមានសម្លេង «អ៊ូ» [u] ដូចជា «ទូ»[15]

សូមកំណត់ចំណាំថា មានស្រៈមួយទៀត ដែលមានសម្លេង «អ៊ូ» [u] ដែរគឺ *qibbuts* ֻ។ ស្រៈនេះយើងមិនសូវឃើញញឹកញាប់ទេ។ ដូច្នេះយើងអត់បានបង្រៀននៅក្នុងមេរៀននេះទេ។

## 13.3 ព្យញ្ជនៈដែលមានសម្លេងពីរ (ព្យញ្ជនៈ ***begadkefat***)

ដូចដែលយើងបានបង្រៀននៅក្នុងមេរៀន 3.2 និង 5.3 ព្យញ្ជនៈ *begadkefat* អត់មានសញ្ញា *dagesh* នៅក្នុងបរិបទមួយចំនួន។ ជាទូទៅព្យញ្ជនៈ *begadkefat* អត់មានសញ្ញា *dagesh* នៅពេលដែលវាស្ថិតនៅចន្លោះស្រៈពីរ ឧ. ពេលវានៅក្រោយឈ្នាប់ -וּ (“waw conjunction”) ដូចពាក្យ וּבַת (*u-vat* «និងកូនស្រី»)។

---

[15] យូរៗម្ដងព្យញ្ជនៈ *vav* មានសញ្ញា *dagesh* ( וּ ) ដូច្នេះវាមើលទៅដូចគ្នានឹងស្រៈ *shureq* ( וּ )។ អ្នកអាចសម្គាល់ពីភាពខុសគ្នានៃព្យញ្ជនៈ *vav*ដែលមានសញ្ញា *dagesh* ( וּ ) នឹងស្រៈ *shureq*

ដោយសារព្យញ្ជនៈ *vav* ដែលមាន *dagesh* តែងតែមានស្រៈនៅជាប់ជាមួយវា ឧ.: וֵּ וַּ וֶּ ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ក្នុងបរិបទផ្សេងទៀត គឺនៅពេលដែលពាក្យខាងដើមបញ្ចប់ដោយស្រៈសង្កត់សម្លេង (*open accented final vowel*) វាក៏អាចមិនមានសញ្ញា *dagesh* នៅក្នុងវា
ប៉ុន្តែវាមិនជានិច្ចកាលនោះទេ។

នៅក្នុងមេរៀននេះ ព្យញ្ជនៈ *bet* ב គ្មានសញ្ញា *dagesh* ពេលវានៅបន្ទាប់ពីពាក្យ שְׁלֹשָׁה ឬ שְׁנֵי/שְׁתֵּי ដោយព្រោះពាក្យទាំងនេះបញ្ចប់ដោយស្រៈសង្កត់សម្លេង (*shəlo**sháh**, shə**téy**, shə**néy***)។

| | |
|---|---|
| בָּתִּים ← בָתִּים | בָּנוֹת ← בָנוֹת |
| שְׁלֹשָׁה בָתִּים<br>ផ្ទះបី<br>🏠🏠🏠 | שְׁתֵּי בָנוֹת<br>កូនស្រីពីរ<br>👧🏽👧🏽 |

ពាក្យ אֵלֶּה ក៏បញ្ចប់ដោយស្រៈដែរ
ប៉ុន្តែដោយសារតែការសង្កត់សម្លេងស្ថិតលើព្យាង្គទីមួយនៃពាក្យ ជាជាងព្យាង្គចុងក្រោយ (*‘**él**leh* មិនមែន *‘el**léh***) នោះពាក្យនេះមិនប៉ះពាល់ពាក្យបន្ទាប់ទេ។

ដូច្នេះបើសិនជាពាក្យបន្ទាប់ពីពាក្យ אֵלֶּה ចាប់ផ្តើមដោយព្យញ្ជនៈ *begadkefat* នោះវាអាចមានសញ្ញា *daghesh* បាន ដូចជាឧទាហរណ៍នៅខាងក្រោម៖[16]

אֵלֶּה בָּנִים

ទាំងនេះគឺជាកូនប្រុស

# មេរៀនទី 14 - ធម្មជាតិនិងប្រយោគដែលបញ្ជាក់ពីវត្តមាន

## 14.1 នាមដែលមានទម្រង់ជាពហុវចនៈប៉ុណ្ណោះ

ដូចជាពាក្យ פָּנִים ដែលយើងបានរៀននៅក្នុងមេរៀនទី៨ ពាក្យ שָׁמַיִם («ស្ថានសួគ៌» ឬ «ផ្ទៃមេឃ») និង מַיִם («ទឹក») មានទម្រង់ជាពហុវចនៈប៉ុណ្ណោះ។

---

[16] នៅក្នុងមេរៀន 13.3 នេះ យើងបានលើកឡើងពីគោលការវេយ្យាករណ៍មួយចំនួនដែលពន្យល់ពីបរិបទដែលធ្វើឲ្យព្យញ្ជនៈ *begadkefat* បាត់បង់សញ្ញា *dagesh*។
សូមបញ្ជាក់ថា គោលការវេយ្យាករណ៍ទាំងនេះវាមិនកើតឡើងជានិច្ចកាលនោះឡើយ។
ជួនកាលនៅក្នុងបរិបទខ្លះ វាអាចមានសញ្ញា *dagesh* នៅក្នុងវាដែរ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ពាក្យទាំងនេះគ្មានទម្រង់ជាឯកវចនៈទេ។ ដូច្នេះ រាល់គុណនាម សព្វនាមចង្អុល គុណនាមចង្អុល ឬកិរិយាសព្ទ ត្រូវតែមានទម្រង់ជាពហុវចនៈផងដែរ។

הַמַּיִם הָאֵלֶּה៖ «ទឹកនេះ» (តាមន័យពាក្យ៖ «ទឹកទាំងនេះ»)

מַיִם רַבִּים៖ «ទឹកជាច្រើន»

## 14.2 **អត្ថន័យធៀបដែលទាក់ទងនឹងពាក្យនៃអវៈយវៈ**

ភាសាហេព្រើរសម្បូរពាក្យប្រៀបធៀបដោយប្រើពាក្យអវៈយវៈជំនួស។ នៅក្នុងមេរៀននេះ យើងនឹងឃើញថាពាក្យ שָׂפָה («បបូរមាត់») ជាន័យធៀបដែលមានន័យថា «ឆ្នេរ» ឬ «ខាងចុង» (ឧ. និក្ខ. 26:4)។ ម្យ៉ាងទៀត ពាក្យ פָּנִים («មុខ») អាចមានន័យថា «ផ្ទៃ» ឧ.៖



- שְׂפַת הַיָּם៖ ឆ្នេរសមុទ្រ (ឧ. លោក. 22:17; បកប្រែតាមន័យពាក្យ៖ «មាត់សមុទ្រ»)
- פְּנֵי הַמָּיִם៖ ផ្ទៃទឹក (ឧ. លោក. 1:2; បកប្រែតាមន័យពាក្យ៖ «មុខទឹក»)



## 14.3 **គុណកិរិយាទាក់ទងនឹងពេលថ្ងៃនិងពេលយប់**

ពាក្យ יוֹם (*yom* “ថ្ងៃ”) និង לַיְלָה (*lailah* “យប់”)

វាមានទម្រង់ខុសគ្នានៅពេលដែលយើងប្រើវាជាទម្រង់គុណកិរិយា។ រីឯពាក្យ יוֹם (*yom* ) ដើម្បីប្រើជាទម្រង់គុណកិរិយា (“នៅពេលថ្ងៃ”) យើងត្រូវដាក់បច្ច័យជាមួយវា ដើម្បីឲ្យក្លាយទៅជា יוֹמָם (*yomam*)។

រីឯពាក្យ לַיְלָה (*lailah*) ដើម្បីប្រើជាទម្រង់គុណកិរិយា (“នៅពេលយប់”) ជួនកាលអាចប្រើពាក្យ לַיְלָה ដដែល ប៉ុន្តែជួនកាលមានផ្ទាក់ -בְּ ភ្ជាប់មកជាមួយ៖ בַּלַּיְלָה។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | |
|---|---|---|
| הָאִישׁ בַּמִּדְבָּר יוֹמָם<br>បុរសនៅទីរហោស្ថាន<br>នៅពេលថ្ងៃ។ | יוֹם<br>ថ្ងៃ | ☀️ |
| הָאִישׁ בַּמִּדְבָּר לַיְלָה<br>បុរសនៅទីរហោស្ថាន<br>នៅពេលយប់។ | לַיְלָה<br>យប់ | 🌒 |

## 14.4 នាមដែលមានទម្រង់ជាឯកវចនៈ តែមានន័យជាពហុវចនៈ (“Collective Nouns”)

ភាសាហេព្រើរមាននាមមួយចំនួនដែលមានទម្រង់ជាឯកវចនៈ តែមានន័យជាពហុវចនៈ (“Collective Nouns”)។ មាននាមបែបនេះជាច្រើន ដែលប្រើសំដៅទៅលើសត្វ ឧ. דָּגָה (*dagah* “ត្រី”)។ ពាក្យត្រី មានទម្រង់ពីរ៖ דָּגָה ជាភេទស្រី (“ត្រីញី”) ហើយវាតែងតែមានទម្រង់ជាឯកវចនៈ តែមានន័យជាពហុវចនៈ។ ផ្ទុយទៅវិញទម្រង់ប្រុស דָּג (“ត្រីឈ្មោល”) អាចមានជាទម្រង់ឯកវចនៈផង និង ពហុវចនៈផង (דָּגִים)។[17] ទោះបីជាទម្រង់វេយ្យាករណ៍មានលក្ខណៈខុសគ្នាក៏ដោយ តែអត្ថន័យមិនខុសគ្នា៖ ឧ. ទម្រង់ דָּג និង דָּגָה ទាំងពីរសំដៅទៅលើត្រីតែមួយនៅក្នុងគម្ពីរយ៉ូណាស (ភេទស្រី៖ 2:2; ភេទប្រុស៖ 2:1,11)។

ឧទាហរណ៍មួយទៀត គឺពាក្យ עוֹף («បក្សី») ដែលមានទម្រង់ជាឯកវចនៈ តែភាគច្រើនមានន័យជាពហុវចនៈ។

- דְּגַת הַיָּם - ត្រីសមុទ្រ



- עוֹף הַשָּׁמַיִם - បក្សីវេហា



[17] កំណត់ចំណាំអ្នកបកប្រែ៖ នៅក្នុង នេ. 13:16 គេប្រើពាក្យ «דָּאג» ដែលមានទម្រង់ ... ជាពហុវចនៈ ( “Collective Nouns” )។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

## 14.5 ប្រយោគដែលបញ្ជាក់ពីវត្តមាននៃកម្មវត្ថុ ( **“Existence clauses”** )

ក្នុងភាសាហេព្រើរ
មានពាក្យពីរដែលប្រើដើម្បីបញ្ជាក់ពីភាពវត្តមានឬភាពអវត្តមាននៃកម្មវត្ថុ។
ដើម្បីបញ្ជាក់ពីភាពវត្តមាន គេប្រើពាក្យ יֵשׁ (*yesh*) (“មាន”)
ហើយដើម្បីបញ្ជាក់ពីភាពអវត្តមាន គេប្រើពាក្យ אַיִן (*’ayin* “អត់មាន”)។

ពាក្យ אַיִן (*’ayin*) មានទម្រង់ផ្សាភ្ជាប់ אֵין (*’eyn* )
ដែលត្រូវបានប្រើពេលវាភ្ជាប់នឹងពាក្យមួយទៀត។ រីឯពាក្យ יֵשׁ )*yesh* ( ជាធម្មតាត្រូវសរសេរដាក់ស្រៈ
*seghol* នៅខាងក្រោមវាដូចនេះ៖ ־יֶשׁ តែជួនកាលដាក់ស្រៈ *tsere* វិញដូចនេះ៖ ־יֵשׁ។

| | | | |
|---|---|---|---|
| មាន បុរស[ម្នាក់] នៅឯវាល | יֵשׁ אִישׁ בַּשָּׂדֶה | មាន | יֵשׁ |
| គ្មាន បុរស[ម្នាក់] នៅឯវាល | אֵין אִישׁ בַּשָּׂדֶה | គ្មាន | אַיִן |

ដើម្បីសួរពីវត្តមាននៃរបស់ណាមួយ យើងអាចដាក់បុព្វបទ הֲ־ នៅពីខាងមុខពាក្យ יֵשׁ
ក្លាយទៅជាពាក្យ הֲיֵשׁ ) “តើមាន …ដែរឬទេ ?” ) ឬនៅពីខាងមុខពាក្យ אֵין
ក្លាយទៅជាពាក្យ הַאֵין ) “តើមិនមាន …ទេឬ ?” )។ (កំណត់ចំណាំ៖ មេរៀនទី១៥ នេះ
មិនមានប្រើពាក្យ הַאֵין នោះទេ)។
ភាសាហេព្រើរនៅសម័យព្រះគម្ពីរអត់មានពាក្យទូទៅសម្រាប់ «បាទ» ឬ «ចាស» ទេ។
ដូច្នេះចំពោះចំឡើយជាវិជ្ជមាន គេប្រើកិរិយាសព្ទ ឬ ពាក្យផ្សេងដកស្រង់ចេញពីសំណួរ។

ឧ. នៅក្នុងភាសាខ្មែរ បើគេសួរ «តើអ្នកញ៉ាំបាយហើយឬនៅ?» ចំឡើយ «ញ៉ាំហើយ»។
ដូច្នេះសម្រាប់សំណួរដែលប្រើពាក្យ יֵשׁ ឬ אַיִן )ឧ. הֲיֵשׁ כִּסֵּה

“តើមានកៅអីដែរឬទេ ?” ) នោះគេក៏ប្រើពាក្យ יֵשׁឬ אַיִן នៅក្នុងចំឡើយ (ឧ. יֵשׁ “មាន”)។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

<table>
<tr><td>יֵשׁ<br>មាន</td><td rowspan="2">הֲיֵשׁ מַיִם בַּכַּד <br>តើមានទឹកនៅក្នុងថូរទេ?</td></tr>
<tr><td>אַיִן, אֵין מַיִם בַּכַּד<br>ទេ<br>គ្មានទឹកនៅក្នុងថូរទេ</td></tr>
</table>

សូមកំណត់ចំណាំថា ប្រយោគខាងក្រោមទាំងពីរនេះ មានប្រើស្រៈខុសគ្នា ក្រោមផ្នាក់ בְּ៖

1. יֵשׁ בְּיַד אַבְרָם דָּבָר׃ - «មានរបស់មួយនៅក្នុងដៃលោកអាប្រាំ (אַבְרָם)»។ គេដាក់ស្រៈស្វា ដូច្នេះវាគ្មាន article ជាក់លាក់ទេ។
2. יֵשׁ דָּבָר בַּיָּד הַזֹּאת׃ - «មានរបស់មួយនៅក្នុងដៃនេះ»។ គេដាក់ស្រៈ *pataḥ* ដូច្នេះវាមាន article ជាក់លាក់។

ចូរចាំថា នាមដែលជាទម្រង់ផ្សាភ្ជាប់ មិនមានភ្ជាប់ជាមួយ article ជាក់លាក់ទេ (សូមមើលមេរៀន 11.2)។ យើងអាចបញ្ជាក់ពីភាពជាក់លាក់របស់វា តាមរយៈពាក្យដែលនៅបន្ទាប់វា។

ដូច្នេះនៅក្នុងឧទាហរណ៍ទីមួយនេះ ពាក្យ בְּיַד  អត់មានភ្ជាប់ជាមួយ article ជាក់លាក់ទេ តែវានៅតែជាក់លាក់ដដែលដោយសារនៅខាងមុខវា គឺមានឈ្មោះមនុស្សដែលជាអសាធារណៈនាម ("proper noun")។ ផ្ទុយទៅវិញ នៅក្នុងឧទាហរណ៍ទីពីរ ប្រយោគ בַּיָּד הַזֹּאת ("នៅក្នុងដៃនេះ") ពាក្យ "ដៃ" មិនមែនជាទម្រង់ផ្សាភ្ជាប់ទេ ដូច្នេះវាត្រូវការ article ជាក់លាក់ (សូមមើលមេរៀន 6.1)។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 15 - ភូមិសាស្ត្រនិងប្រធានបទផ្សេងៗទៀត

## 15.1 ច្រើន

ពាក្យ רַב (មានន័យថា “ច្រើន”) វាគឺជាគុណនាម ដូច្នេះវាត្រូវស្រប់គ្នានឹងនាមខាងឯភេទ/ចំនួន។ វាមានបួនទម្រង់

| ពហុ. | ឯក. | |
|---|---|---|
| כְּבָשִׂים רַבִּים<br>ចៀមឈ្មោល ច្រើន | בָּקָר רַב<br>គោឈ្មោល ច្រើន | ប្រុស |
| פָּרוֹת רַבּוֹת<br>មេគោច្រើន | דָּגָה רַבָּה<br>ត្រីច្រើន | ស្រី |

<u>កំណត់ចំណាំ</u>៖ នាមដែលមានទម្រង់ជាឯកវចនៈ តែមានន័យជាពហុវចនៈ (“Collective Nouns” ឧ. ពាក្យ בָּקָר និង דָּגָה នៅខាងលើ) ពេលវាប្រើភ្ជាប់ជាមួយគុណនាម ត្រូវតែជាគុណនាមឯកវចនៈ។

## 15.2 នាមថ្មីពីរទៀត ដែលមានទម្រង់ជាឯកវចនៈ តែមានន័យជាពហុវចនៈ

## ( “Collective Nouns” )

នៅក្នុងមេរៀននេះ យើងរៀននាមថ្មីពីរទៀត ដែលជា collective noun (សូមមើល មេរៀន 14.4)។ គឺដូចគ្នានឹងនាមមុនដែរ នាមទាំងពីរនេះសំដៅទៅលើសត្វ។ ពាក្យ צֹאן (*tso'n*) និង בָּקָר (*baqar*) គឺមានទម្រង់ជាឯកវចនៈ ទោះបីជាភាគច្រើនវានិយាយសំដៅទៅលើហ្វូងសត្វដែលមានលក្ខណៈជាពហុវចនៈក៏ដោយ។

- ពាក្យ צֹאן អាចមានន័យថា ហ្វូងចៀម ឬ ពពែ អាស្រ័យទៅលើបរិបទរបស់វា។
- ពាក្យ בָּקָר មានន័យថា ហ្វូងគោ (ភាសាអង់គ្លេស គឺតំរូមទាំង cows, bulls, oxen,។ល។)។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

## 15.3 **ទន្លេនិងទន្លេស្ងួត** (**“wadi”**)



ភាសាហេព្រើរ មានពាក្យពីរដាច់ដោយឡែកពីគ្នា ដែលសំដៅលើផ្លូវទឹក។ ពាក្យទាំងពីរនេះមានសម្លេងស្រដៀងគ្នា ប៉ុន្តែសំដៅទៅលើរបស់ពីរខុសគ្នា។ ពាក្យ נָהָר *nahár* គឺសំដៅទៅលើទន្លេធំ ដែលមានទឹកហូរ ឧ. ទន្លេយ័រដាន់។ រីឯពាក្យ נַחַל *náħal* គឺអាចមានន័យផ្សេងៗគ្នា ឧ.៖

- ទន្លេស្ងួត (“wadi”) ដែលជួនកាលមានទឹកបាក់ខ្លាំងនៅរដូវភ្លៀង
- អូរឬស្ទឹង
- ទឹកដែលហូរខ្លាំង (ឧ. ទំនុក. 18:5)

នៅតំបន់ស្រុកអ៊ីស្រាអែល មានទន្លេស្ងួត (“wadi” ដូចក្នុងរូបភាព) គឺជាផ្លូវទឹក នៅចន្លោះជ្រលងភ្នំក្នុងវាលរហោស្ថាន។ ទន្លេស្ងួតបែបនេះ វាមានទឹកហូរខ្លាំងពេលមានភ្លៀង ប៉ុន្តែក្រោយមកវាស្ងួតទៅវិញ។ នៅស្រុកអ៊ីស្រាអែល មានទន្លេស្ងួតជាច្រើនដែលស្ថិតនៅនាយទាំងសងខាងនៃទន្លេយ័រដាន់ (សូមមើល យ៉ូប 6:15; យេរ. 15:18 ក៏សំដៅទៅលើទន្លេស្ងួតដែរ ប៉ុន្តែប្រើពាក្យផ្សេង)។







Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 16 - អក្សរក្រម វគ្គទី 4

## 16.1 ព្យញ្ជនៈមួយចំនួន

- *Gimel* ג
- *Sin* שׂ សូមមើលមេរៀន 7.1 ដើម្បីរំលឹកពីរបៀបនៃព្យញ្ជនៈ שׁ និង שׂ ដែលបញ្ចេញសម្លេងខុសពីគ្នា។
- *Kaf* ך כ כּ ךּ មានសម្លេង *k* (ខ) ពេលវាមានសញ្ញា *dagesh* (ឧ. כּ ךּ) ហើយមានសម្លេង *χ* ពេលវាគ្មានសញ្ញា *dagesh* (ឧ. כ ךְ)។
- *Pe* פ פּ ף មានសម្លេង *p* (ផ) ពេលវាមានសញ្ញា *dagesh* (ឧ. פּ) ហើយមានសម្លេង *f* (ហ្វ) ពេលវាគ្មានសញ្ញា *dagesh* (ឧ. ף פ)។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 17 - ធ្នាក់ ל ( Lamedh ) និងកម្មសិទ្ធិ

## 17.1 ការបញ្ជាក់ពីកម្មសិទ្ធ

ភាសាហេព្រើរគ្មានពាក្យដែលមានន័យស្មើនឹងកិរិយាសព្ទ «មាន» ទេ។
ដើម្បីបញ្ជាក់ពីកម្មសិទ្ធ ភាសាហេព្រើរប្រើបុព្វបទធ្នាក់ -לְ។ ជាធម្មតា ធ្នាក់ -לְ មានន័យថា «មក/ទៅ» ប៉ុន្តែវាអាចបញ្ជាក់ពីកម្មសិទ្ធបានដែរ អាស្រ័យទៅលើបរិបទ។

ធ្នាក់ -לְ ដូចជាបុព្វបទធ្នាក់ -בְּ (សូមមើលមេរៀន 6.1) បុព្វបទធ្នាក់ -לְ វាតែងតែភ្ជាប់មុខជាមួយនឹងនាមឬសព្វនាមជាបច្ច័យ ដូចខាងក្រោម៖

| បុរស | ឯកវចនៈ<br>ប្រុស<br>ស្រី | | ពហុវចនៈ<br>ប្រុស ស្រី | |
|---|---|---|---|---|
| បុរសទី ១ | לִי<br>មកខ្ញុំ ឬ របស់ខ្ញុំ | | לָנוּ<br>មកយើង ឬ របស់យើង | |
| បុរសទី ២ | לְךָ<br>មក/ទៅអ្នក ឬ របស់អ្នក (ប្រុស ឯក.) | לָךְ<br>មក/ទៅអ្នក ឬ របស់អ្នក (ស្រី ឯក.) | לָכֶם<br>មក/ទៅអ្នករាល់គ្នា ឬ របស់អ្នករាល់គ្នា (ប្រុស ពហុ.) | לָכֶן<br>មក/ទៅអ្នករាល់គ្នា ឬ របស់អ្នករាល់គ្នា (ស្រី ពហុ.) |
| បុរសទី ៣ | לוֹ<br>មក/ទៅគាត់ ឬ របស់គាត់ (ប្រុស ឯក.) | [18]לָהּ<br>មក/ទៅគាត់ ឬ របស់គាត់ (ស្រី ឯក.) | לָהֶם<br>មក/ទៅពួកគាត់ ឬ របស់ពួកគាត់ (ប្រុស ពហុ.) | לָהֶן<br>មក/ទៅពួកគាត់ ឬ របស់ពួកគាត់ (ស្រីពហុ.) |

ជួនកាល ដើម្បីបញ្ជាក់កម្មសិទ្ធ គេដាក់ធ្នាក -לְ ជាមួយពាក្យ יֵשׁ ឬ אֵין ("existence words"; សូមមើល មេរៀន 14.5) ឧ. ___יֶשׁ־לִי (មានន័យថា "ខ្ញុំមាន ___") ___אֵין־לוֹ (មាន័យថា "គាត់មិនមាន___ទេ"។

[18] ពេលព្យញ្ជនៈ *he* ប្រើជាព្យញ្ជនៈ វាមានសញ្ញា *dagesh* ( הּ-) ប៉ុន្តែបើប្រើជាស្រៈវិញ វាគ្មានសញ្ញា *dagesh* ទេ (ה ָ)។ ពេលមានសញ្ញា *dagesh* ( הּ- ) ពាក្យនោះបញ្ចប់ដោយសម្លេង *h* ("អះ" ឧ. לָהּ គឺបញ្ចេញសម្លេង "ឡោះ" ) ជាជាង *a* ("អ") ដូចនៅក្នុង ה ָ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | |
|---|---|
| ខ្ញុំមានរបស់ច្រើន។ | יֶשׁ־לִי דְבָרִים רַבִּים |
| ខ្ញុំមិនមានចៀមទេ។ | אֵין־לִי כֶּבֶשׂ |
| ពួកគេមានសេះ។ | יֶשׁ־לָהֶם סוּס |

ដើម្បីសួរបញ្ជាក់អំពីកម្មសិទ្ធ (“តើអ្នកមាន___ដែរឬទេ?”) គេអាចថែមបុព្វបទសំណួរដែលសួរពី "បាទ-ទេ" -הֲ (“Yes-No questions”; សូមមើល 9.4)៖

| | |
|---|---|
| តើនាងមានថូរទេ? | הֲיֵשׁ לָךְ כַּד |

## 17.2 គុណនាមដែលមានតួនាទីជានាម

នៅក្នុង លោក. 29:16 មានគុណនាមដែលមានភ្ជាប់នឹង article ជាក់លាក់ (definite article) ដើម្បីប្រើជានាម។ គេប្រើទម្រង់នេះច្រើននៅក្នុងភាសាហេព្រើរនៅក្នុងសម័យព្រះគម្ពីរ។

וּלְלָבָן שְׁתֵּי בָנוֹת שֵׁם הַגְּדֹלָה לֵאָה וְשֵׁם הַקְּטַנָּה רָחֵל

ហើយលោកឡាបានមានកូនស្រីពីរនាក់។ អាមួយបងឈ្មោះ ឡេអា និងអាមួយប្អូនឈ្មោះ រ៉ាជែល។

- הַגְּדֹלָה – “អាមួយបង/ធំ” (ភេទស្រី)
- הַקְּטַנָּה – “អាមួយប្អូន/តូច” (ភេទស្រី)

## <u>សេចក្ដីពន្យល់បន្ថែម</u>

- ខ្ញុំអត់មានអ្វីសោះ ← אֵין לִי מְאוּמָה

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 18 - កុមារនិងពួកចាស់ទុំ

## 18.1 កំណត់ចំណាំពីវគ្គសព្ទ

នៅក្នុងមេរៀននេះ មិនមានចំណុចថ្មីខាងវេយ្យាករណ៍ទេ ប៉ុន្តែយើងបង្ហាញវគ្គសព្ទថ្មីខ្លះនៅក្នុងមេរៀននេះ រួមទាំងនាមឯកវចនៈ នាមពហុវចនៈ និងពាក្យដែលមានទម្រង់ផ្សាភ្ជាប់។

| ទម្រង់ផ្សាភ្ជាប់ពហុវចនៈ | ទម្រង់ផ្សាភ្ជាប់ឯកវចនៈ | នាមពហុវចនៈ | នាមឯកវចនៈ | |
|---|---|---|---|---|
| יַלְדֵי הָאִישׁ<br>កូនប្រុសៗបុរស[នោះ] | | *yəladim* יְלָדִים<br>👦🏽👦🏽👦🏽 | *yeled* יֶלֶד | 👦🏽 |
| | יַלְדַּת הָאִשָּׁה<br>កូនស្រីៗបុរស[នោះ] | *yəladot* יְלָדוֹת<br>👧🏽👧🏽👧🏽 | *yaldah* יַלְדָּה | 👧🏽 |
| זִקְנֵי יִשְׂרָאֵל<br>ពួកចាស់ទុំសាសន៍អ៊ីស្រាអែល | | *zəqenim* זְקֵנִים<br>👴🏽👴🏽👴🏽 | *zaqen* זָקֵן | 👴🏽 |

- עַם (*‘am*) គឺជានាមដែលមានទម្រង់ជាឯកវចនៈ តែមានន័យជាពហុវចនៈ (collective noun) ដែលមានន័យថា “ប្រជាជន” ឬ “ប្រជារាស្ត្រ”
- וַיְהִי (*vayyəhi*) គឺជាទម្រង់កិរិយាសព្ទ “ជា/គឺជា” ដែលគេដាក់ជាតំណភ្ជាប់នៅខាងមុខវគ្គផ្សេងទៀតនៃសាច់រឿង (ឧ. លោក. 10:19, 30; 11:1, 2; 12:10)










Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 19 - អក្សរក្រម វគ្គទី 5

## 19.1 ព្យញ្ជនៈមួយចំនួន

- ז *zayin*
- ע *'ayin*
- צ ץ *tsade*
- ח *ħet*
- ק *qof*
- ט *tet*
- ס *samekh*

## 19.2 *pataħ* សម្លេងខ្លី ( reduced *pataħ* )

ស្រៈ ֲ *ħatef pataħ* (reduced *pataħ*) គឺជាស្រៈមួយដែលមានសម្លេងខ្លីជាងស្រៈ *pataħ* ធម្មតា ( )។ គេប្រើស្រៈនេះនៅក្រោមព្យញ្ជនៈតែមួយប្រភេទប៉ុណ្ណោះ គឺ ព្យញ្ជនៈបែប guttural៖ ,א ע ,ח, ហើយនិង ה ។ ( ព្យញ្ជនៈបែប guttural គឺជាព្យញ្ជនៈដែលមានសម្លេងត្រង់បំពុងក )។

ព្យញ្ជនៈបែប guttural មិនអាចភ្ជាប់ជាមួយនឹងស្រៈ *shewa* ( ְ ) ដែលមានសម្លេង (vocalized shewa) បានទេ។ ដូច្នេះសម្រាប់ព្យញ្ជនៈបែប guttural ទាំងនេះ គេប្រើស្រៈ *ħatef pataħ* ជំនួសវិញ។ ចូរប្រៀបធៀបទម្រង់ពាក្យជាពហុវចនៈនៅខាងក្រោមនេះ៖

| នាមឯកវចនៈ | នាមពហុវចនៈ | | |
|---|---|---|---|
| כֶּבֶשׂ – ចៀម | כְּבָשִׂים – ហ្វូងចៀម | ពាក្យដែលចាប់ផ្តើមដោយព្យញ្ជនៈដែលអាចភ្ជាប់ជាមួយនឹងស្រៈ *shewa* ( ְ ) | ១ |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | | |
|---|---|---|---|
| | | ដែលមានសម្លេងបាន | |
| אִישׁ – បុរស | אֲנָשִׁים – ពួកបុរស | ពាក្យដែលចាប់ផ្តើមដោយព្យញ្ជនៈដែលមិនអាចភ្ជាប់ជាមួយនឹងស្រៈ *shewa* ( ְ ) ដែលមានសម្លេងបានទេ | ២ |

យោងតាមច្បាប់វេយ្យាករណ៍នេះ ពាក្យ אֲנָשִׁים នៅក្នុងឧទាហរណ៍លេខ២ គួរតែមាន *shewa* ក្រោមព្យញ្ជនៈដើមពាក្យ ដូចនៅក្នុងឧទាហរណ៍លេខ១នៅខាងលើ כְּבָשִׂים។ ប៉ុន្តែដោយព្រោះពាក្យ אֲנָשִׁים ចាប់ផ្តើមដោយព្យញ្ជនៈ *aleph* នោះត្រូវដាក់ស្រៈ *ħatef pataħ* ជំនួសវិញ។

## 19.3 **Furtive *pataħ***

នៅពេលដែលស្រៈ *pataħ* ( ַ ) ស្ថិតនៅលើព្យញ្ជនៈ ע ח ឬ ה ដែលនៅខាងចុងពាក្យ នោះយើងត្រូវបញ្ចេញសម្លេងមុនព្យញ្ជនៈ វាខុសពីធម្មតា។ យើងអាចសម្គាល់វាតាមរយៈទីតាំងនៃស្រៈ ដែលស្ថិតនៅក្រោមព្យញ្ជនៈ។
ជាធម្មតាវាស្ថិតនៅចំកណ្តាលនៃព្យញ្ជនៈ ប៉ុន្តែពាក្យនេះងាកទៅខាងស្តាំនៃព្យញ្ជនៈ ដែលយើងហៅថា “furtive *pataħ*” ឬ “transitional *pataħ*”។

| | |
|---|---|
| אֵחַ<br>furtive *pataħ*<br>(ត្រូវបញ្ចេញសម្លេង៖ *aħ*) | חַ<br>*pataħ* ធម្មតា<br>(ត្រូវបញ្ចេញសម្លេង៖ *ħa*) |




Draft copy. This work is Public Domain. You may share, adapt, and re
permission.

មកដល់ឥឡូវនេះ យើងបានរៀនពាក្យតែមួយដែលមានផ្ទុកស្រៈ furtive *pataħ* គឺពាក្យ יָרֵחַ (*yareaħ* “ព្រះចន្ទ”)។

<u>កំណត់ចំណាំ</u>៖ ពុម្ពអក្សរភាសាហេព្រើរបច្ចុប្បន្ន (Modern Hebrew fonts) គឺគ្មានលក្ខណៈខុសគ្នារវាង *pataħ* ធម្មតានឹង furtive *pataħ* ដូច្នេះពុម្ពអក្សរទាំងនោះ furtive *pataħ* តែងតែស្ថិតចំកណ្តាលនៃព្យញ្ជនៈ ដូចគ្នានឹង *pataħ* ធម្មតា។ ពុម្ពអក្សរ Times New Roman ដែលយើងប្រើនៅក្នុងឯកសារនេះ ក៏អញ្ចឹងដែរ។

# មេរៀនទី 20 - ពាក្យ אֲשֶׁר ( *‘asher*) & ល្បះដែលមានសព្វនាមទំនាក់ទំនងជាចំណង (Relative Clauses)

## 20.1 ផ្នាក់ផ្សំ

មានផ្នាក់ខ្លះដែលបង្កើតឡើងដោយពាក្យពីរផ្សំគ្នា ដូចខាងក្រោមនេះ៖

(ផ្នាក់មួយ) + (ពាក្យអវៈយវៈជាទម្រង់ផ្សាភ្ជាប់) → (ផ្នាក់ថ្មីមួយទៀត)

ឧទាហរណ៍៖




- יָד + לְ ( “ដៃ” ) → לְיַד ( “នៅក្បែរខាង” )
- פָּנִים + לְ ( “មុខ” ) → לִפְנֵי ( “នៅខាងមុខ” ឬ “នៅចំពោះមុខ” )

<u>ចំណាត់ចំណាំ</u>៖ ពាក្យ פָּנִים ជាទម្រង់ផ្សាភ្ជាប់គឺ פְּנֵי ។ ឧ.៖

פְּנֵי אַבְרָם “មុខរបស់លោកអាប់រ៉ាម (אַבְרָם)”

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

## 20.2 **បុព្វបទផ្ទាក់ដែលនៅជាប់នឹងនាម** ( **inseparable preposition** ) **ពេលប្រើជាមួយនឹង article ជាក់លាក់** ( **definite article** )

នៅក្នុងភាសាហេព្រើរ មានផ្ទាក់បីដែលមានតួព្យញ្ជនៈតែមួយ ហើយវាតែងតែភ្ជាប់ជាមួយនឹងពាក្យបន្ទាប់៖ לְ כְּ בְּ (យើងនឹងរៀនពីផ្ទាក់ כְּ នៅក្នុងមេរៀនទី 41)។ ជូនកាលផ្ទាក់បែបនេះ មានភ្ជាប់ជាមួយនឹងនាម ដែលមាន article ជាក់លាក់ (definite article)។ ជាធម្មតា article ជាក់លាក់ គេសរសេរបែបដូចនេះ៖ -הַ (*ha-*)។ ប៉ុន្តែក្នុងករណីនេះ គេលប់ចោលអក្សរ ה ហើយដាក់ស្រៈរបស់ article ជាក់លាក់នោះនៅខាងក្រោមផ្ទាក់វិញ។

(យើងក៏ឃើញពីលក្ខណៈបែបនេះខ្លះនៅក្នុងមេរៀន 7.3)។

| | |
|---|---|
| នៅក្នុងវាលរហោស្ថាន [នោះ] | בְּ + הַ + מִדְבָּר ← בַּמִּדְבָּר |
| នៅក្នុងវាល [នោះ] | בְּ + הַ + שָׂדֶה = בַּשָּׂדֶה |

ចូរប្រៀបធៀបពីលក្ខណៈខុសគ្នារបស់ពាក្យទាំងពីរខាងក្រោមនេះ ដែលមួយមាន article ជាក់លាក់ មួយអត់៖

| | |
|---|---|
| ទៅកាន់ស្ត្រី [ម្នាក់] | לְ + אִשָּׁה ← לְאִשָּׁה |
| ទៅកាន់ស្ត្រី [ម្នាក់នោះ] | לְ + הָ + אִשָּׁה ← לָאִשָּׁה |

## 20.3 **ពេលដែលឈ្នាប់** -וְ ( *və-* ) **ក្លាយជា** -וּ ( *u-* ) ( **ការរំលឹកមេរៀនទី** 3.1 )

នៅក្នុងកាលៈទេសៈខ្លះ ឈ្នាប់ -וְ (*və-*) ក្លាយជា -וּ (*u-*) អាស្រ័យលើព្យញ្ជនៈដែលនៅជាប់នឹងវា។ ឈ្នាប់ -וְ មានការផ្លាស់ប្តូរសម្លេងក្នុងករណីខាងក្រោមនេះ៖

1) ពេលឈ្នាប់នៅជាប់នឹងព្យញ្ជនៈដែលមានសម្លេងនៅបបូរមាត់ (labial)៖

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

- פּ
- בּ
- מּ

- អក្សរ ។ ពេលវាបញ្ចេញសម្លេងជាព្យញ្ជនៈ (ּ)

2) ពេលឈ្នាប់នៅជាប់នឹងព្យញ្ជនៈដែលមានស្រៈ *shewa* ( ְ ) ឧ.៖ וּגְמַלִּים ( “ហើយសត្វអូដ្ឋ” ) វាណוּנְעָרוֹת ( “ហើយស្រ្តីក្មេងៗ” ) ។ល។

## 20.4 **សព្វនាមទំនាក់ទំនង אֲשֶׁר** (’***asher***)

ពាក្យ אֲשֶׁר (’*asher*) មានមុខងារជាសព្វនាមទំនាក់ទំនង ដូចជាពាក្យ «ដែល» ក្នុងភាសាខ្មែរ។ គេប្រើពាក្យនេះនៅខាងដើមឃ្លារណប (dependent clause) ដូចជា “បុរសដែលនៅក្នុងវាល...” ឬ “ស្រ្តីដែលមកផ្ទះ...” ដើម្បីបង្កើតល្បះដែលមានសព្វនាមទំនាក់ទំនងជាចំណង (“relative clause”)។

| | |
|---|---|
| តើក្មេងប្រុសដែលនៅលើ[ខ្ទង]លា នៅឯណា?<br><br>គាត់គឺជាក្មេងប្រុសដែលនៅលើ[ខ្ទង]លា។ | אַיֵּה הַיֶּלֶד אֲשֶׁר עַל־חֲמוֹר?<br><br>הוּא הַיֶּלֶד אֲשֶׁר עַל־חֲמוֹר׃ |
| តើបុរសដែលមានក្មេងប្រុសនៅឯណា?<br><br>គាត់គឺជាបុរសដែលមានក្មេងប្រុស។ | אַיֵּה הָאִישׁ אֲשֶׁר יֶשׁ־לוֹ יֶלֶד?<br><br>הוּא הָאִישׁ אֲשֶׁר יֶשׁ־לוֹ יֶלֶד׃ |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 20b - ការសរសេរអក្សរក្រមភាសាហេព្រើរ

## 20b.1 អក្សរក្រមភាសាហេព្រើរ ( **“Aleph-Bet”** )

អក្សរក្រមភាសាហេព្រើរបូរាណ ខុសគ្នាពីអក្សរក្រមភាសាហេព្រើរបច្ចុប្បន្ននេះ។ មុនឆ្នាំ 1500 ម.គ.ស. ពួកអម្បូរសេមីត (a semitic people) ដែលរស់នៅចន្លោះ Phoenicia (ដូចក្រុងស៊ីដូន) និងតំបន់ស៊ីណាយ ពួកគេបានបង្កើតតួអក្សរដែលមានរូបរៀងជារូបភាពសត្វឬឧបករណ៍ផ្សេងៗ។ អ្នកអាចសិក្សាបន្ថែម [នៅទីនេះ](https://en.wikipedia.org/wiki/Hebrew_alphabet) បាន (https://en.wikipedia.org/wiki/Hebrew_alphabet)។







យើងហៅតួអក្សរភាសាហេព្រើរដែលយើងប្រើនៅពេលបច្ចុប្បន្ននេះ ថា អក្សរជ្រុងបែបអារ៉ាម(“Aramaic square script”) ដែលមានព្យញ្ជន:២២តួ។ មុនដំបូងភាសាហេព្រើរអត់មានស្រៈទេ អស់

រយៈពេលរាប់ពាន់ឆ្នាំ។ ប៉ុន្តែក្រោយមក គេបានយកអក្សរបួន (ឱ. ក និង I) មកប្រើដោយមានមុខងារជាស្រៈ ដូចជាអ្វីដែលយើងឃើញនៅក្នុងក្រាំងនៅសមុទ្រស្លាប់ (Dead Sea Scrolls)។

ក្រាំងដែលគេប្រើនៅក្នុងសាលាប្រជុំសាសន៍យូដា នៅតែមិនមានប្រើស្រៈ រីឯភាសាហេព្រើរបច្ចុប្បន្នក៏មិនមានប្រើស្រៈដែរ (លើកលែងតែនៅក្នុងកំណាព្យឬសៀវភៅក្មេងៗប៉ុណ្ណោះ)។ កាលដែលគេប្រើស្រៈដំបូងនៅក្នុងគម្ពីរសញ្ញាចាស់ គឺដើម្បីរក្សាការបញ្ចេញសម្លេងត្រឹមត្រូវតាមសំនៀងដើម។ កាលដំបូងដែលគេចាប់ផ្ដើមប្រើស្រៈ (ដែលជួនកាលគេហៅថា «*niqqud*») ប្រហែលនៅឆ្នាំ




Draft copy. This work is Public permission.

700 គ.ស. ហើយបញ្ឈប់ទៅវិញ ប្រហែលនៅឆ្នាំ 950 គ.ស.។ ពួកម៉ាសូរ៉េត(Masoretes) គឺជាអ្នកដែលបន្ថែមស្រៈដែលយើងប្រើនៅក្នុងព្រះគម្ពីរភាសាហេព្រើរសព្វថ្ងៃនេះ។

វាជាការសំខាន់ដែលយើងត្រូវទន្ទេញព្យញ្ជនៈឲ្យចាំទៅតាមលំដាប់លំដោយ ដើម្បីឲ្យយើងអាចប្រើវចនានុក្រមៗ អ្នកអាចចូលស្ដាប់ បទចម្រៀងព្យញ្ជនៈនេះ ដើម្បីជួយអ្នកឲ្យបានយល់បន្ថែមទៀត។

នៅពេលដែលយើងរៀនសរសេរព្យញ្ជនៈ ចូរហាត់តាមវិដេអូ ហើយសរសេរព្យញ្ជនៈនីមួយៗឲ្យបាន១០ដងយ៉ាងតិចណាស់។ សូមបន្តហាត់សរសេររហូតដល់អ្នកអាចចាំស្ទាត់។ បន្ទាប់មកទៀត ចូរសរសេរអក្សរក្រមទាំងមូលឲ្យបាន២០ដងគិតរួមទាំងទម្រង់ផ្សេងៗនៃមុខងារអក្សរនីមួយៗ (ឧ. נ ן)។

ប្រសិនបើអ្នកចង់រៀនចេះប្រើកុំព្យូទ័រជាភាសាហេព្រើរ សូមចុចទីនេះ។ (http://bibleandtech.blogspot.com/2010/06/typing-biblical-hebrew.html)

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 21- កិរិយាស័ព្ទ «មក» និង «ទៅ» ( qatal ឯកវចនៈ )

## 21.1 សេចក្តីណែនាំស្តីពីកិរិយាស័ព្ទនៃភាសាហេព្រើរ

កិរិយាស័ព្ទនៃភាសាហេព្រើរ ត្រូវបានបង្កើតចេញមកពីឫសពាក្យដែលមានព្យញ្ជនៈបីតួ។ តាមរយៈការបន្ថែមបច្ច័យ បុព្វបទ (suffixes and prefixes) ហើយនឹងស្រៈទៅលើឫសនៃពាក្យនោះ យើងអាចបង្កើតអត្ថន័យផ្សេងៗពីគ្នា។

ឧ. នៅក្នុង វិដេអូនៃមេរៀននេះ យើងបានឃើញថា មនុស្សប្រុសម្នាក់បានដើរ (הָלַךְ)។ យើងហៅកិរិយាស័ព្ទនេះថា ជាកិរិយាស័ព្ទបុរសទីបីឯកវចនៈភេទប្រុស (third-person-masculine-singular ឬក៏ "3ms")។ នោះមានន័យថា៖

- គាត់ (បុរសទីបី)
- ភេទ៖ ប្រុស
- ចំនួនអ្នកប្រព្រឹត្ត៖ មានតែម្នាក់ (ឯកវចនៈ)

### បុរសទីប៉ុន្មាន?

នៅក្នុងសៀវភៅវេយ្យាករណ៍ភាសាហេព្រើរនិងសៀវអត្ថាធិប្បាយជាច្រើន អ្នកនិពន្ធតែងតែបញ្ជាក់ពីលក្ខណៈរបស់ប្រធានដែលបានប្រព្រឹត្តសកម្មភាព៖ បុរសទីមួយ បុរសទីពីរ ឬ បុរសទីបី។ ពាក្យទាំងនេះមានអត្ថន័យដូចខាងក្រោមនេះ៖

- បុរសទីមួយ **(1st person)**៖ ខ្ញុំ ឬ យើង  (សម្រាប់ភាសាស្តេច៖ អញ ឬ យើង)
- បុរសទីពីរ **(2nd person)**៖ អ្នក ឬ អ្នករាល់គ្នា (សម្រាប់ភាសាស្តេច៖ ឯង ឬ ព្រះអង្គ)
- បុរសទីបី **(3rd person)**៖ គាត់ គេ ពួកគាត់ ឬ ពួកគេ (សម្រាប់ភាសាស្តេច៖ ទ្រង់)

### ភេទអី?

ភេទរបស់ប្រធានមានការផ្លាស់ប្តូរ ប្រសិនបើយើងផ្លាស់ប្តូរទម្រង់នៃពាក្យ។ ឧ. ពាក្យ הָלַךְ ("មនុស្សប្រុសម្នាក់បានដើរ") ប្តូរជាពាក្យ הָלְכָה (ដោយបន្ថែមបច្ច័យ ־ָה នៅខាងចុង) នោះវាបានប្តូរអត្ថន័យទៅជា "មនុស្សស្រីម្នាក់បានដើរ។

មានឧទាហរណ៍ផ្សេងទៀតនៅក្នុងវិដេអូនេះ៖

| | |
|---|---|
| בָּא | គាត់(ប្រុស)បានមក |
| בָּאָה | គាត់(ស្រី)បានមក |
| בָּאתִי | ខ្ញុំបានមក |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

សូមកំណត់ចំណាំថា នៅក្នុងវគ្គដំបូងនៃមេរៀនទាំងនេះ ផ្តោតសំខាន់ទៅលើទម្រង់នៃកិរិយាស័ព្ទ *qatal* ដែលភាគច្រើនបញ្ជាក់ពីអតីតកាល។ យើងអត់ទាន់ប្រើកិរិយាស័ព្ទជាទម្រង់ infinitive ទម្រង់ participle ឬ ទម្រង់ផ្សេងទៀតកិរិយាស័ព្ទនៅឡើយ។ ព្រះគម្ពីរជាភាសាហេព្រើរ ពិពណ៌នាជាច្រើនអំពីអ្វីដែលបានកើតឡើងនៅអតីតកាល ដូច្នេះហើយបានជាព្រះគម្ពីរសញ្ញាចាស់ប្រើទម្រង់ qatal យ៉ាងច្រើនដែរ។ ដូច្នេះទម្រង់នៃកិរិយាស័ព្ទនេះមានសារៈសំខាន់ណាស់ សម្រាប់យើងយល់ពីអត្ថន័យស៊ីជំរៅនៃព្រះគម្ពីរភាសាហេព្រើរ។

## 21.2 **Aspect**

កិរិយាស័ព្ទនៃភាសាហេព្រើរមិនមានកាល (verb *tenses*) ដូចភាសាខ្មែរទេ ប៉ុន្តែវាមាន "*aspect*"។ ផ្នែកនេះអាចមានភាពស្មុគស្មាញ ប៉ុន្តែជាទូទៅទម្រង់ *qatal* (ដែលមាន "*perfective aspect*") សំដៅទៅលើអតីតកាល ហើយទម្រង់មួយទៀតហៅថា *yiqtol* (ដែលមាន "*imperfective aspect*") សំដៅទៅលើអនាគតកាល។

ទម្រង់ *qatal* មកពីពាក្យកិរិយាស័ព្ទ קָטַל (ដែលមានន័យថា «សម្លាប់»)។ គេប្រើជាញឹកញាប់ពាក្យ קָטַל ក្នុងតារាងកិរិយាស័ព្ទ។

## 21.3 **កិរិយាស័ព្ទប្រក្រតី និង កិរិយាស័ព្ទមិនប្រក្រតី (Weak** & **Strong Verbs)**

នៅក្នុងភាសាហេព្រើរ មានកិរិយាស័ព្ទប្រក្រតី និង កិរិយាស័ព្ទមិនប្រក្រតី (regular and irregular verbs)។ កិរិយាស័ព្ទមិនប្រក្រតី វាមានការផ្លាស់ប្តូរស្មុគស្មាញជាងកិរិយាស័ព្ទប្រក្រតី។

ឧ. នៅក្នុងភាសាអង់គ្លេសពាក្យ *walk* ប្រក្រតី ដោយព្រោះយើងឃើញឫសពាក្យ *walk* នៅក្នុងទម្រង់ទាំងអស់៖ "I walk" "he walks" "I walked" "he walked" ។ល។ រីឯពាក្យ *go* មិនប្រក្រតីដោយព្រោះយើងមិនដែលនិយាយ "I goed" សម្រាប់អតីតកាលឡើយ យើងប្រើពាក្យ "I *went*" ជំនួសវិញ។ភាគច្រើនកិរិយាស័ព្ទមិនប្រក្រតី យើងគេប្រើជាញឹកញាប់ ដូច្នេះហើយបានជាយើងត្រូវតែរៀនកិរិយាស័ព្ទមិនប្រក្រតីជាមុន។

កិរិយាស័ព្ទប្រក្រតី គេហៅថា «កិរិយាស័ព្ទខ្លាំង» (*strong* verbs) ផ្ទុយទៅវិញកិរិយាស័ព្ទមិនប្រក្រតី គេហៅថា «កិរិយាស័ព្ទខ្សោយ» (*weak* verbs) ពីព្រោះព្យញ្ជនៈរបស់វាអាចត្រូវកាត់ចេញពេលដែលទម្រង់របស់វាផ្លាស់ប្តូរ។ ឧ. គេរាប់ព្យញ្ជនៈ ה ថាជាព្យញ្ជនៈខ្សោយ ដោយព្រោះវាត្រូវបានគេយកចេញពេលប្រើជាមួយនឹងទម្រង់ឯទៀត ដូចឫសពាក្យ הלך («គាត់បានទៅ») ក្លាយទៅជាពាក្យ לֵךְ («ទៅចុះ!» ភេទប្រុសឯកវចនៈ) ពេលប្រើជាពាក្យបង្គាប់។

យើងនឹងពន្យល់បន្ថែមទៀតអំពីលក្ខណៈរបស់កិរិយាស័ព្ទខ្សោយនេះ នៅមេរៀនក្រោយ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

## 21.4 **Binyanim** ( **stems** ) & **Qal**

ក្នុងភាសាហេព្រើរមិនមែនគ្រាន់តែមាន aspects ប៉ុណ្ណោះទេ ប៉ុន្តែវាក៏មាន *stems* (ឬ *binyanim* ជាពាក្យហេព្រើរ) ។ ក្នុងភាសាហេព្រើរ មាន *binyanim* ចំបងៗ ប្រាំពីរប្រភេទ។ នៅក្នុងមេរៀនរិដេអររបស់យើង stem ដំបូងដែលបានណែនាំឲ្យស្គាល់គឺ *qal*។ អ្នកអាចសន្មត់ថា កិរិយាសព្ទទាំងអស់ដែលយើងប្រើនៅក្នុងមេរៀនវគ្គដំបូងនេះ គឺជា *qal* ដែលជា stem សាមញ្ញ។

ប្រសិនបើយើងក្រឡេកមើលទៅលើកិរិយាសព្ទមួយនៅក្នុងវចនានុក្រមភាសាហេព្រើរ ការពន្យល់តែងតែបង្ហាញជាទម្រង់ qal perfect បុរសទីបី ភេទប្រុស ឯកវចនៈ (3MS)។ ឧ. ប្រសិនបើអ្នកឃើញកិរិយាសព្ទ הָלְכָה នៅក្នុងខគម្ពីរណាមួយ ហើយចង់រកមើលវានៅក្នុងវចនានុក្រម នោះអ្នកត្រូវរកមើលឫសពាក្យ הלך។ យើងហៅទម្រង់នេះ ជា “lexical form” ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 22 - "និយាយ" ( אָמַר ) និងពាក្យបង្គាប់ ( "imperatives" )

## 22.1 אָמַר - «គាត់(ប្រុស)បាននិយាយ» ឬ «ទ្រង់មានបន្ទូល»

នៅក្នុងមេរៀននេះ យើងណែនាំឲ្យស្គាល់កិរិយាសព្ទ "និយាយ" אָמַר។ សូមចាំថា នៅក្នុងវគ្គដំបូងនេះយើងផ្តោតទៅលើកិរិយាសព្ទដែលមាន *perfective aspect* គឺជាកិរិយាសព្ទដែលពិពណ៌នាពីសកម្មភាពដែលបានបញ្ចប់ទៅហើយ។ ក្នុងករណីដូចមេរៀននេះ យើងនិយាយសំដៅទៅលើសកម្មភាពដែលបានកើតឡើងនៅក្នុងអតីតកាល។ ដូច្នេះពាក្យ אָמַר មានន័យថា "គាត់បាននិយាយ"។ ពាក្យនេះមានទម្រង់ជា qal បុរសទីបី ភេទប្រុស ឯកវចនៈ (3MS) ដែលជាទម្រង់ដែលយើងឃើញនៅក្នុងវចនានុក្រម ("lexical form")។ នៅក្នុងវិដេអូនេះ យើងក៏ប្រើទម្រង់ផ្សេងទៀតនៃពាក្យ אָמַר ផងដែរ ដូចខាងក្រោមនេះ៖

| | |
|---|---|
| אָמְרָה | គាត់(ស្រី)បាននិយាយ (qal qatal 3FS) |
| אָמַרְתְּ | អ្នក(ស្រី)បាននិយាយ (qal qatal 2FS) |
| אָמַרְתָּ | អ្នក(ប្រុស)បាននិយាយ (qal qatal 2MS) |
| אָמַרְתִּי | ខ្ញុំបាននិយាយ (qal qatal 1CS) |

## 22.2 ពាក្យបង្គាប់ ( "imperatives" )

"An imperative" គឺជាពាក្យបង្គាប់។

ពាក្យបង្គាប់ដំបូងដែលយើងឃើញនៅក្នុងមេរៀននេះ គឺ לֵךְ គឺជាពាក្យដែលយើងប្រើទៅកាន់មនុស្សប្រុស ប្រសិនបើអ្នកចង់ឲ្យគាត់ទៅកន្លែងណាមួយ («ចូរទៅ...!») ប្រសិនបើអ្នកនិយាយ "ចូរទៅ!" ទៅកាន់ស្ត្រីម្នាក់ នោះអ្នកត្រូវប្រើពាក្យ לְכִי វិញ។ ឫសនៃពាក្យបង្គាប់នេះ הָלַךְ («គាត់បានទៅ/ដើរ») គឺយើងបានរៀននៅក្នុងមេរៀនមុនរួចហើយ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

សូមកត់សម្គាល់ថា ពាក្យ לֵךְ មិនមានព្យញ្ជនៈ ה ដូច lexical form הָלַךְ នោះទេ។

ពាក្យបង្គាប់ដែលមានព្យញ្ជនៈខ្សោយនៅខាងដើម (ដូចជាព្យញ្ជនៈ ה) វាអាចបាត់បង់ព្យញ្ជនៈដើមនៃឫសពាក្យនោះ (សូមមើលមេរៀនទី២១)។

ប៉ុន្តែពាក្យដែលមិនមានព្យញ្ជនៈខ្សោយនៅខាងដើមដូចជាពាក្យ בֹּא វាមិនបាត់បង់ព្យញ្ជនៈខាងដើមនោះឡើយ ពេលដែលយើងប្រើវាជាពាក្យបង្គាប់។ វាគ្រាន់មានការផ្លាស់ប្តូរស្រៈតែប៉ុណ្ណោះ។

នៅក្នុងវីដេអូនេះ នាង Beth បង្គាប់ទៅលោកអាប់រ៉ាម (אַבְרָם) ដោយប្រើពាក្យថា «בּוֹא»។ នេះជាពាក្យបង្គាប់ភេទប្រុសឯកវចនៈ (impv ms) មកពីឫសពាក្យ בֹּא។ ផ្ទុយទៅវិញ បើសិនជាលោកអាប់រ៉ាម បង្គាប់ទៅនាង Beth ឲ្យមក នោះគាត់ត្រូវប្រើពាក្យភេទស្រី «בּוֹאִי» (impv fs)។

ពាក្យបង្គាប់ប្រើសម្រាប់តែបុរសទីពីរប៉ុណ្ណោះ (អ្នក ឬ អ្នកទាំងអស់គ្នា)។ ទម្រង់ពាក្យបង្គាប់ក្នុងភាសាហេព្រើរ គេប្រើសម្រាប់តែជាការបង្គាប់បែបវិជ្ជមាន គេមិនដែលប្រើសម្រាប់ទម្រង់អវិជ្ជមាន (បដិសេធ) ទេ។ ប្រសិនបើអ្នកចង់និយាយថា "កុំទៅ" នោះអ្នកត្រូវប្រើទម្រង់ផ្សេងដែលយើងនឹងរៀននៅមេរៀនក្រោយ។ ឧ. ពាក្យ «កុំឲ្យមានព្រះឯណាទៀតនៅចំពោះអញឲ្យសោះ» នៅក្នុងក្រឹត្យវិន័យ១០ប្រការ (KHOV និក្ខ. 20:3) មិនមានប្រើទម្រង់ពាក្យបង្គាប់ទេ ដោយសារតែវាជាទម្រង់បដិសេធ។

## 22.3 **ទម្រង់** ***vayyiqtol*** (**vav-consecutive-imperfect**)

ភាសាហេព្រើរមានចំណុចពិសេសមួយ ដែលខុសគ្នាពីភាសាអង់គ្លេសនិងខ្មែរ គឺមានទម្រង់ពិសេសរបស់កិរិយាសព្ទ ដែលប្រើសម្រាប់ជាការនិទានរឿង។ ទម្រង់នេះគេហៅថា vav-consecutive-imperfect ឬ *vayyiqtol*។ ពាក្យនេះមកពីពាក្យហេព្រើរ "וַיִּקְטֹל" ដែលជួនកាលគេសរសេរអក្សរ "ו" ជាមួយអក្សរអង់គ្លេស "v" ជួនកាលជាមួយ "w" ដូច្នេះសៀវភៅផ្សេងទៀតអាចប្រើពាក្យ waw-consecutive-imperfect ឬ *wayyiqtol*។ ភាសាហេព្រើរសម័យព្រះគម្ពីរគេប្រើទម្រង់កិរិយាសព្ទនេះ ក្នុងការចងភ្ជាប់កិរិយាសព្ទផ្សេងគ្នា ដើម្បីប្រើក្នុងការនិទានរឿង (ជាពិសេសសម្រាប់ទម្រង់អក្សរសាស្ត្របែបប្រវត្តិសាស្ត្រ)។ ចំណុចវេយ្យាករណ៍នេះ អាចពិបាកយល់បន្តិច ប៉ុន្តែទម្រង់នេះមានការប្រើប្រាស់រាប់ពាន់ដងនៅក្នុងព្រះគម្ពីរជាភាសាហេព្រើរ ដូច្នេះយើងត្រូវចំណាយពេលដើម្បីស្វែងយល់ឲ្យបានស៊ីជំរៅទៅលើវា។

ដូចជាអ្វីដែលយើងបានពន្យល់ហើយនៅក្នុងមេរៀនមុនស្តីពីពាក្យ אָמַר («គាត់បាននិយាយ») គឺជាកិរិយាសព្ទជាទម្រង់ *perfective aspect* (សំដៅទៅលើសកម្មភាពដែលបានបញ្ចប់ហើយ) ដែលភាគច្រើនបានកើតឡើងរួចហើយនៅក្នុងអតិតកាល។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ប្រហែលទម្រង់កិរិយាសព្ទបែបនេះ គួរតែប្រើដើម្បីនិទានរឿង ប៉ុន្តែភាសាហេព្រើរនៅសម័យព្រះគម្ពីរ គេមិនបានប្រើទម្រង់បែបដូចនេះទេ គឺគេប្រើទម្រង់ *vayyiqtol* ទៅវិញ នៅពេលដែលយើងបរិយាយរឿងអ្វីមួយ។

នៅក្នុងវីដេអូ យើងឃើញឧទាហរណ៍ដំបូងនៃទម្រង់កិរិយាសព្ទនេះ៖ וַיֹּאמֶר ( “ហើយគាត់បាននិយាយ” )។ និយាយបែបសាមញ្ញគឺថា យើងអាចបង្កើតទម្រង់ *vayyiqtol* ដោយយើងគ្រាន់តែបន្ថែម បុព្វបទ “וַ” បូកជាមួយនឹងកិរិយាសព្ទ។ ទម្រង់ *qatal* និង *vayyiqtol* ទាំងពីរគឺមាន *perfective aspect* ដូចគ្នា ដូច្នេះពាក្យ אָמַר និង וַיֹּאמֶר មានអត្ថន័យទូទៅដូចគ្នា៖ “គាត់បាននិយាយ”។ ប៉ុន្តែការបកប្រែជាភាសាអង់គ្លេសជាញឹកញាប់ គេបកប្រែឈ្នាប់ ו ទៅជា “and”។ ការបកប្រែជាភាសាខ្មែរជាញឹកញាប់ គេបកប្រែឈ្នាប់ ו ទៅជា «បន្ទាប់មក» «រួច» ឬ «នោះ»៖ “បន្ទាប់មក...ទ្រង់មានបន្ទូលថា...” (ឧ. លោក. 1:6 ប៉ុន្តែសូមមើល លោក. 1:4 ដែលគ្មានពាក្យ «បន្ទាប់មក» ឬ «នោះ»)។ តាមពិតទៅជាភាសាខ្មែរ យើងប្រើឈ្នាប់ខុសៗគ្នាដើម្បីនិទានរឿង៖ “ការនេះបានកើតឡើង... <u>ហើយ</u>ការនោះក៏បានកើតឡើង... <u>រួច</u>ការមួយទៀតក៏បានកើតឡើង...”។ ផ្ទុយទៅវិញភាសាហេព្រើរមានលក្ខណៈខុសគ្នាបន្តិច ដោយព្រោះភាគច្រើនគេប្រើទម្រង់ *vayyiqtol* តែមួយដដែល ជាជាងប្រើឈ្នាប់ខុសៗគ្នា។

ដូច្នេះហើយបានជា នាង Beth ក៏ប្រើទម្រង់ *vayyiqtol* នេះ នៅពេលដែលគាត់កំពុងតែនិទានរឿងតាមលំដាប់លំដោយនៃសាច់រឿង (a *sequence* or *chain* of events)៖

אָמַרְתִּי אֶל־אַבְרָם שָׁלוֹם: וַיֹּאמֶר אַבְרָם שָׁלוֹם:

ខ្ញុំនិយាយទៅលោកអាប់រ៉ាម ថា “សាឡូម” ហើយលោកអាប់រ៉ាម និយាយថា “សាឡូម”។

នេះគឺជាឧទាហរណ៍មួយទៀត៖

אָמַרְתִּי אֶל־יַעֲקֹב בֶּן־מִי אַתָּה: וַיֹּאמֶר בֶּן־יִצְחָק אָנֹכִי:

ខ្ញុំបាននិយាយទៅលោកយ៉ាកូបថា “តើអ្នកជាកូនអ្នកណា?” ហើយគាត់បានឆ្លើយតបថា “ខ្ញុំជាកូនរបស់អ៊ីសាក”។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 23 - បច្ច័យកម្មសិទ្ធិ (“possessive suffixes”) ផ្នែកទី១ & អវយវៈនៃរាងកាយ

## 23.1 បច្ច័យកម្មសិទ្ធិ (“possessive suffixes”)

ជាភាសាហេព្រើរ ប្រសិនបើយើងចង់និយាយថារបស់មួយជាកម្មសិទ្ធរបស់អ្នកណាម្នាក់ នោះយើងអាចបន្ថែមបច្ច័យកម្មសិទ្ធ (“*possessive suffix*”) នៅខាងចុងនៃពាក្យនោះ។ ទម្រង់បែបនេះគេហៅថា បច្ច័យកម្មសិទ្ធ (“*possessive suffixes*”) ឬក៏ បច្ច័យសព្វនាម (“*pronominal suffixes*”)។[19] ឧទាហរណ៍ ដើម្បីនិយាយ “ក្បាលខ្ញុំ” ឬ “ក្បាលរបស់ខ្ញុំ” នោះយើងយកពាក្យ רֹאשׁ ហើយបន្ថែម *hireq-yod* (ִי) នៅខាងចុងវា៖ רֹאשִׁי។

សូមបញ្ជាក់ថា ពាក្យដែលមានព្យញ្ជនៈខ្សោយដូចពាក្យ פֶּה (“មាត់”) យើងត្រូវលប់បំបាត់ព្យញ្ជនៈខ្សោយ ה នោះចេញនៅពេលដែលយើងបន្ថែមបច្ច័យកម្មសិទ្ធ៖ פִּי (“មាត់ខ្ញុំ”)។

ឧ.៖

| | |
|---|---|
| אַפִּי ← אַף<br>ច្រមុះខ្ញុំ ← ច្រមុះ | כַּפִּי ← כַּף<br>បាតដៃខ្ញុំ ← បាតដៃ |

### បច្ច័យកម្មសិទ្ធ បុរសទីបីឯកវចនៈ

បច្ច័យ וֹ- មានទម្រង់ជា 3MS (បុរសទីបី ភេទប្រុស ឯកវចនៈ ឬក៏ third-masculine-singular)៖ “របស់គាត់[ប្រុស]”។ ដូច្នេះ ដើម្បីនិយាយ “ឈ្មោះរបស់គាត់[ប្រុស]” នោះគេត្រូវនិយាយថា שְׁמוֹ។ ប្រសិនបើស្រៈស្ថិតនៅខាងមុខបច្ច័យ 3MS នោះស្រៈ “וֹ” នឹងត្រឡប់ទៅជាព្យញ្ជនៈ “ו” (*vav*)៖

פִּיו ←) וֹ + פֶּה (← פֶּה

“មាត់គាត់” ← “មាត់”

[19] សូមមើលមេរៀនទី 5.1 និង 9.1 ដែលពន្យល់ពីចំណុចនេះផងដែរ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ដើម្បីនិយាយ “ឈ្មោះគាត់[ស្រី]” នោះយើងប្រើបច្ច័យ ָהּ- ៖ שְׁמָהּ។ សូមរំលឹកថា បច្ច័យ ָהּ- មានសម្លេងខ្យល់ចេញពីពោះ (aspirated/rough sound)
ដើម្បីញែកដាច់ចេញពីពាក្យផ្សេងដែលបញ្ចប់ដោយអក្សរ ה ។

តារាងនៅខាងក្រោមនេះបានប្រាប់យើងពីបច្ច័យកម្មសិទ្ធិដែលមាននៅក្នុងវីដេអូ៖

| | |
|---|---|
| របស់គាត់[ប្រុស] (3MS)👳 | וֹ |
| របស់គាត់[ស្រី] (3FS)👩 | ָהּ |
| របស់អ្នក[ប្រុស] (2MS)👳 | ְךָ |
| របស់អ្នក[ស្រី] (2FS)👩 | ֵךְ |
| របស់ខ្ញុំ (1CS)👩/👳 | ִי |



שְׁמָהּ שָׂרָה

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 24 - បច្ច័យកម្មសិទ្ធផ្នែកទី២ & ពាក្យគ្រួសារ

## 24.1 ពាក្យគ្រួសារ

### בֵּית אָב

នៅក្នុងមេរៀននេះ យើងបង្រៀនពាក្យថ្មី៖ בֵּית אָב ("គ្រួសាររបស់ឪពុក" ឬ ជាភាសាខ្មែរ "ក្រុមគ្រួសារឪពុក" ឧ. ជន. 3:24; 25:15)។
ពាក្យនេះសំដៅទៅលើគ្រួសារមួយ។ ដូច្នេះនាង Beth




បានណែនាំឲ្យស្គាល់សាជិករបស់គ្រួសាររបស់នាងដោយនាងនិយាយថា "זֶה בֵּית אָבִי" («នេះគឺជាគ្រួសាររបស់ឪពុកខ្ញុំ»)។

### បច្ច័យកម្មសិទ្ធិ 1CS

ផ្នែកបន្ទាប់បានរំលឹកឡើងវិញពីចំណុចមួយដែលយើងបានរៀននៅក្នុងមេរៀនមុនស្តីពីបច្ច័យកម្មសិទ្ធិ 1CS («របស់ខ្ញុំ»; បុរសទីមួយ អាចជាភេទទាំងពីរ ឯកវចនៈ)។
នៅក្នុងមេរៀននេះ នាង Beth និយាយថា៖

- "הוּא אָבִי" («គាត់ជាឪពុករបស់ខ្ញុំ»)
- "הִיא אִמִּי" («គាត់ជាម្តាយរបស់ខ្ញុំ»)
- "הוּא אָחִי" («គាត់ជាបងប្អូនប្រុសខ្ញុំ»)
- "הִיא אֲחֹתִי" («គាត់ជាបងប្អូនស្រីខ្ញុំ»)
- ។ល។

នៅពេលដែលនាងណែនាំឲ្យស្គាល់ឪពុកលោកអាប់រ៉ាម គាត់និយាយថា៖ "הוּא אֲבִי אַבְרָם"។ ទោះបីជាពាក្យ אֲבִי មានសម្លេងដូចគ្នាទៅនឹងពាក្យ אָבִי តែពាក្យទាំងពីរនេះមិនមានន័យដូចគ្នាទេ។ ពាក្យ אֲבִי មានន័យថា "ឪពុករបស់" ហើយពាក្យ אָבִי មានន័យថា "ឪពុកខ្ញុំ"។

### ទម្រង់ផ្សារភ្ជាប់ដែលមាននាមអសាធារណៈ (proper nouns)

ចូរកំណត់ចំណាំថា ពាក្យទាំងពីរនេះមានស្រៈផ្សេងគ្នាដែលស្ថិតនៅក្រោមព្យញ្ជនៈ א។ យោងទៅលើលក្ខណៈបច្ចេកទេស ពាក្យ אֲבִי ជាទម្រង់ផ្សារភ្ជាប់ (*construct form*) នៃពាក្យ אָב។ ចូរចងចាំថា
នៅពេលដែលពាក្យណាមួយប្រើជាទម្រង់ផ្សារភ្ជាប់ជាមួយនឹងនាមអសាធារណៈ (ដូចជា "_____ របស់ [ឈ្មោះគេ]" ឧ. "ផ្ទះរបស់សុខ") នោះគេរាប់ទម្រង់នោះ

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ថាវាជាទម្រង់ជាក់លាក់ (*definite*) ហើយ។ ឧ. ជាភាសាអង់គ្លេស គេតែងតែដាក់ពាក្យ "*the*"
នៅខាងមុខទម្រង់នោះ។ ដូច្នេះ הוּא אֲבִי אַבְרָם មានន័យថា
"គាត់គឺជាឪពុករបស់លោកអាប់រ៉ាម" មិនមែន
"គាត់គឺជាឪពុកម្នាក់របស់លោកអាប់រ៉ាម"នោះឡើយ។

### ពាក្យ «ប្ដីរបស់នាង»

ចំណុចមួយទៀតដែលងាយឲ្យយើងយល់ច្រឡំគឺពេលដែលយើងនិយាយថា
«ប្ដីរបស់នាង» (אִישָׁהּ) ឧ. "אֲנִי אִישָׁהּ" ("ខ្ញុំគឺជាប្ដីរបស់នាង")។
នៅពេលដែលលោកអាប់រ៉ាមនិយាយពាក្យនេះ
ស្ដាប់ទៅវាមានសម្លេងស្រដៀងគ្នាទៅនឹងពាក្យ "ខ្ញុំជាស្ត្រី" (אֲנִי אִשָּׁה)។
ហេតុហេះហើយបានជាយើងត្រូវបញ្ចេញខ្យល់ឲ្យខ្លាំងពោះនៅពេលដែលយើងពាក្យ
"אִישָׁהּ" ("ប្ដីរបស់នាង") ដើម្បីញែកឲ្យដាច់ពី គ្នានឹងពាក្យ "אִשָּׁה " ("ស្ត្រី")។




### הָ បន្ទាប់ពី ִי

នៅផ្នែកខាងក្រោយនៃវីដេអូនេះ យើងឃើញថា
នៅពេលដែលយើងប្រើបច្ច័យកម្មសិទ្ធិ 3FS הָ
(បុរសទីបី ភេទស្រី ឯកវចនៈ) បន្ទាប់ពីស្រៈ ִי
នោះវាត្រឡប់ទៅជា יהָ ។ ឧ. אָחִיהָ
("បងប្អូនប្រុសរបស់នាង") និង ពាក្យ אָבִיהָ
("ឪពុករបស់នាង")។

### បច្ច័យកម្មសិទ្ធថ្មី

នៅក្នុងមេរៀននេះយើងនឹងរៀនបច្ច័យកម្មសិទ្ធថ្មី
ហើយនឹងរបៀបដែលបច្ច័យកម្មសិទ្ធភ្ជាប់ជាមួយនឹងនាម<u>ឯកវចនៈ</u>។ ទីមួយគឺ "របស់យើង"
(1CP = បុរសទីមួយ អាចជាភេទទាំងពីរ ពហុវចនៈ)។ ដូច្នេះពេលយើងនិយាយថា
"សេះរបស់យើង" នោះយើងត្រូវភ្ជាប់បច្ច័យ ֵנוּ ទៅនឹងពាក្យ סוּס ៖ סוּסֵנוּ។ ដូចគ្នានេះដែរ
ពាក្យ "ផ្ទះរបស់យើង" នៅក្នុងភាសាហេព្រើរគឺជា בֵּיתֵנוּ។

ទីពីរគឺបច្ច័យ כֶם- ("របស់អ្នករាល់គ្នា[ប្រុស]") ដែលជាបច្ច័យកម្មសិទ្ធ 2MP (បុរសទីពីរ
ភេទប្រុស ពហុវចនៈ) ។ នាង Beth បានលើកឧទាហរណ៍មួយគឺ יֵשׁ לָכֶם בַּיִת
ដែលមានន័យថា "អ្នករាល់គ្នាមានផ្ទះ"។ នៅពេលដែលយើងនិយាយថា
"នេះគឺជាផ្ទះរបស់អ្នករាល់គ្នា" នោះយើងនិយាយថា៖ זֶה בֵּיתְכֶם។

ទីពីរគឺបច្ច័យ כֶן- ("របស់អ្នករាល់គ្នា[ស្រី]") ដែលជាបច្ច័យកម្មសិទ្ធ 2FP (បុរសទីពីរ
ភេទស្រី ពហុវចនៈ)។ ឧ.៖

- "គាត់គឺជាឪពុករបស់អ្នករាល់គ្នា[ស្រី]" = הוּא אֲבִיכֶן
- "គាត់គឺជាបងប្អូនប្រុសរបស់អ្នករាល់គ្នា[ស្រី]" = אֲחִיכֶן

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

សូមបញ្ជាក់ថា ក្នុងភាសាហេព្រើរ ចំនួនមនុស្សដែលជាពហុវចនៈ
ដែលមានប្រុសនិងស្រីទាំងពីរ យើងប្រើសព្វនាមភេទប្រុសតំណាងឲ្យមនុស្សទាំងនោះ។
ឧ. បើសិនជាអ្នកកំពុងតែនិយាយជាមួយបងប្អូនប្រុសស្រីពីរនាក់
ហើយចង់និយាយសំដៅទៅលើឪពុករបស់ពួកគេ («ឪពុករបស់អ្នករាល់គ្នា»)
នោះអ្នកអាចនិយាយថា “2) ”אֲחִיכֶםMP) មិនមែន “2) ”אֲחִיכֶןFP)។

តារាងនៅខាងក្រោមនេះបានប្រាប់យើងពីបច្ច័យកម្មសិទ្ធិដែលមាននៅក្នុងវីដេអូ៖

| | |
|---|---|
| Their (3MP)👳👳 | ָם |
| Their (3FP)👩👩 | ָן |
| Your/y’all’s (2MP)👳👳 | כֶם |
| Your/y’all’s (2FP)👩👩 | כֶן |
| Our (1CP)👩👳 | ֵנוּ |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 25 - ការស្ដាប់ & ការស្ដាប់បង្គាប់

## 25.1 **សម្លេង** - קוֹל

នៅក្នុងមេរៀននេះ យើងរៀនពាក្យ קוֹל ដែលមានន័យថា «សម្លេង»។

សូមបញ្ជាក់ថា កុំច្រឡំពាក្យ קוֹל ជាមួយនឹងពាក្យ כֹּל ឬ כָּל־ («ទាំងអស់»/«រាល់»)។ ទម្រង់ផ្សារភ្ជាប់នៃពាក្យ קוֹל វានៅតែដដែល ដូច្នេះដើម្បីនិយាយ "សម្លេងរបស់បុរស" នោះយើងត្រូវនិយាយ៖ "קוֹל אִישׁ"។

## 25.2 **ការស្ដាប់ & ការស្ដាប់បង្គាប់**

នៅក្នុងភាសាហេព្រើរ យើងប្រើកិរិសព្ទដូចគ្នាសម្រាប់ពាក្យ «ស្ដាប់» និង «ស្ដាប់បង្គាប់»៖ שָׁמַע។

ដូចនៅក្នុងមេរៀនមុន យើងឃើញគេប្រើកិរិយាសព្ទ ដែលមាន *perfective aspect* ដែលសំដៅទៅលើសកម្មភាពដែលបានបញ្ចប់រួចហើយ ឬកើតឡើងនៅពេលអតីតកាល (*completed* or *past* action)។ អក្សរ שָׁמַע ("គាត់[ប្រុស]បានលឺ") គឺជាឫសនៃពាក្យ ហើយក៏ជាទម្រង់ដែលយើងឃើញនៅក្នុងវចនានុក្រម (the lexical/dictionary form)។ នៅខាងក្រោមនេះ គឺជាឧទាហរណ៍ខ្លះ ដែលគេប្រើពាក្យនេះក្នុងទម្រង់ផ្សេងៗ៖

אַבְרָם שָׁמַע
លោកអាប់រ៉ាមបានលឺ (3MS)

בֵּת שָׁמְעָה
នាង Beth បានលឺ (3FS)

אֲנִי שָׁמַ֫עְתִּי
ខ្ញុំបានលឺ (1CS)

ដូច្នេះ តើយើងដឹងយ៉ាងម៉េច ថាពាក្យ שָׁמַע មានន័យថា «លឺ» ឬ «ស្ដាប់បង្គាប់»? ចំឡើយគឺពេលវាប្រើជាមួយនឹងពាក្យ קוֹלבְּ។ នៅក្នុងពាក្យ קוֹלבְּ នេះ យើងឃើញថាធ្នាក់ בְּ ដែលភ្ជាប់នឹងពាក្យ קוֹל វាបញ្ជាក់ថា ពាក្យ קוֹל ដើរតួនាទីជាកម្មបទផ្ទាល់។ ឧ. យើងអាចបងប្រែពាក្យ "שָׁמַעְתִּי בְּקוֹלוֹ" ជា «ខ្ញុំបានស្ដាប់បង្គាប់គាត់» (ឬតាមន័យត្រង់ «ខ្ញុំបានស្ដាប់បង្គាប់សម្លេងគាត់») មិនមែនជា «ខ្ញុំបានស្ដាប់បង្គាប់ក្នុង/ដោយគាត់»។

ដូច្នេះហើយបានជាយើងឃើញ នាង Beth និយាយថា៖

אַבְרָם שָׁמַעְתִּי בְּקוֹלְךָ
(«លោកអាប់រ៉ាម ខ្ញុំបានស្ដាប់បង្គាប់អ្នក»)

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ហើយលោកអាប់រ៉ាមឆ្លើយតបថា៖ שָׁמַעְתָּ בְּקוֹלִי («អ្នកបានស្ដាប់បង្គាប់ខ្ញុំ»)

## 25.3 ព្រះនាមនៃព្រះ

ព្រះនាមទ្រង់ផ្ទាល់របស់ព្រះជាម្ចាស់ (אֱלֹהִים) គឺត្រូវបានណែនាំនៅក្នុងនិក្ខមនំ 3:15៖ יהוה។ នៅក្នុងវិដេអូរបស់យើង យើងមិនសរសេរព្រះនាមរបស់ព្រះដោយប្រើស្រៈទេ ដោយព្រោះការបញ្ចេញសម្លេងតាមបែបសំនៀងដើម ត្រូវបានបាត់បង់។

យោងតាមទម្លាប់របស់សាសន៍យូដា គឺគេប្រើគោរមនាមជំនួស ដើម្បីសំដៅទៅលើព្រះជាម្ចាស់៖ אֲדֹנָי (ដែលបកប្រែទៅខ្មែរថា «ព្រះអម្ចាស់»)។ ពួកម៉ាសសូរ៉េត (Masoretes) បានថែរក្សានូវទម្លាប់មួយនេះហើយពួកគេក៏ជាអ្នកដែលបានបង្កើតប្រពន្ធស្រៈនៃភាសាហេព្រើរ។ ពួកគេបានថែរក្សានូវទម្លាប់នេះ ដោយដាក់ស្រៈរបស់ពាក្យ אֲדֹנָי ទៅដាក់បញ្ចូលទៅក្នុងពាក្យ יהוה ដូច្នេះគេសរសេរបែបនេះ៖ יְהֹוָה ។ ជួនកាលគេក៏ដកយកស្រៈ *holem* ចេញហើយសរសេរជាសាមញ្ញដូចនេះ៖ יְהוָה។

ប្រសិនបើអ្នកមានចម្ងល់ថា ហេតុអ្វីពួកយើងជ្រើសរើសយកបញ្ចេញសម្លេងព្រះនាមរបស់ទ្រង់ថា ព្រះយេហូវ៉ា (យ៉ាហ្វេ) នៅក្នុងវិដេអូរបស់យើង សូមចូលទៅក្នុងលីងនេះ៖ http://freehebrew.online/pronunciation ។ នៅទីនោះ អ្នកនឹងឃើញធនធានផ្សេងៗមួយចំនួនទៀត ដែលជួយពន្យល់បន្ថែម។ យើងក៏បាននិពន្ធសៀវភៅ ដែលពន្យល់អំពីមូលហេតុដែលមនុស្សខ្លះចៀសវាងបញ្ចេញសម្លេងនៃព្រះនាមទ្រង់ ប៉ុន្តែព្រះគម្ពីរបានបង្រៀនយើងយ៉ាងដូចម្ដេច។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 26 - «គឺជា» & សម្រស់

## 26.1 **«គឺជា»** ( **To Be** ) - **הָיָה**

ឫសនៃកិរិយាសព្ទ הָיָה មានន័យថា "គាត់គឺជា" "មាន" (ឧ. "មានកន្លែងមួយ...") ឬ "វាគឺជា"។ ដូចគ្នានឹងវិដេអូមុនដែរ ឫសនៃកិរិយាសព្ទ הָיָה មាន *perfective* aspect ដែលសំដៅលើអតិតកាល ឧ.៖

אַבְרָם הָיָה יֶלֶד : עַתָּה אַבְרָם אִישׁ:

"[ពីមុន]លោកអាប់រ៉ាមគឺជាកុមារ។ ឥឡូវលោកអាប់រ៉ាមបុរស។"

សូមបញ្ជាក់ថាយើងអត់បានប្រើពាក្យ הָיָה ពេលនិយាយអំពីបច្ចុប្បន្នកាលទេ ដូចដែលយើងឃើញនៅក្នុងឃ្លានេះ៖

עַתָּה אַבְרָם אִישׁ:

ឥឡូវលោកអាប់រ៉ាមបុរស។

ភាសាហេព្រើរនៅក្នុងសម័យព្រះគម្ពីរ ភាគច្រើនមិនមានប្រើកិរិយាសព្ទ ដើម្បីនិយាយអំពីបច្ចុប្បន្នកាលទេ។ ឧទាហរណ៍ រាល់លើកនាង Beth និយាយថា אֲנִי בֵּת ("ខ្ញុំ[ជា]នាង Beth") នៅខាងដើមមេរៀន នាងមិនបានប្រើពាក្យ הָיָה នោះទេ គឺគាត់គ្រាន់តែប្រើឃ្លាមិនមានកិរិយាសព្ទ (verbless clause)។

នេះគឺជាទម្រង់សម្រាប់ពាក្យ הָיָה៖

| | |
|---|---|
| គាត់[ប្រុស]គឺជា (3MS)👳 | הָיָה |
| គាត់[ស្រី]គឺជា (3FS)👩 | הָיְתָה |
| អ្នក[ប្រុស]គឺជា (2MS)👳 | הָיִיתָ |
| អ្នក[ស្រី]គឺជា (2FS)👩 | הָיִית |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| ខ្ញុំគឺជា (1CS) | הָיִיתִי |
|---|---|

<u>កំណត់ចំណាំ</u>៖
សូមវែកញែកឲ្យដាច់ចេញពីគ្នារវាងពាក្យ אַתָּה (“អ្នក”[ប្រុស]) និងពាក្យ עַתָּה (“ឥឡូវ”) ដែលមានសម្លេងប្រហាក់ប្រហែលគ្នា។

ជាញឹកញាប់គេប្រើពាក្យ הָיָה ក្នុងការនិទានរឿង ជាទម្រង់ *vayyiqtol* (ដែលជួនកាលគេហៅ ទម្រង់ *vav-consecutive-imperfect*)៖ וַיְהִי។ សូមចាំថា ទម្រង់ *vayyiqtol* មាន perfective aspect ដូចគ្នានឹង ទម្រង់ *qatal* ដែរ ដូច្នេះពាក្យ וַיְהִי អាចប្រែថា “ហើយមាន...” ឬ “មាន....”។ ជាញឹកញាប់ ពាក្យ នៅ  וַיְהִי ខាងដើមសាច់រឿង ឬចំណុចចាប់ផ្តើមថ្មីនៃសាច់រឿង។ ឧទាហរណ៍ នៅពេលដែលអ្នកនិពន្ធណែនាំយើងឲ្យស្គាល់លោកអែលកាណា នៅក្នុង១សាំយ៉ូអែល នោះគាត់បាននិយាយថា៖

וַיְהִי אִישׁ אֶחָד... וּשְׁמוֹ אֶלְקָנָה׃

”នោះមានមនុស្សម្នាក់ ហើយគាត់ឈ្មោះអែលកាណា“

## 26.2 សម្រស់ - יָפֶה និង יָפָה

ពាក្យ יָפֶה គឺជាគុណនាមដែលមានន័យថា “ស្អាត”។ តើអ្នកនៅចាំទេ? ពាក្យ יָפֶה ជាពាក្យដែលនាង Beth បានប្រើដើម្បីសរសើរលោកអាប់រ៉ាម នៅពេលដែលគាត់ឆ្លើយសំណួរត្រូវ។ ប៉ុន្តែនៅក្នុងព្រះគម្ពីរ ជាធម្មតាវាមានន័យថា «ស្អាត»។ ពាក្យ יָפֶה អាចប្រើសំដៅទៅលើមនុស្សប្រុសដែលសង្ហា (ឧ. លោក. 39:6) ប៉ុន្តែភាគច្រើនពាក្យប្រើជាភេទស្រី (יָפָה) ដើម្បីពិពណ៌នាពីភាពស្រស់ស្អាតនៃស្ត្រី។ ជួនកាលពាក្យនេះប្រើភ្ជាប់ជាមួយនឹងនាម מַרְאֶה ដែលមានន័យថា “រូបរាង”។

ឧ. ដើម្បីនិយាយថា “គាត់ជាស្ត្រីដែលមានរូបរាងស្អាត” នោះយើងនិយាយថា៖ הִיא אִשָּׁה יְפַת מַרְאֶה ។ ខ្លះបកប្រែពាក្យនេះថា “គាត់ជាស្ត្រីដែលស្រស់ស្អាតខាងរូបរាង” ប៉ុន្តែយើងអាចនិយាយបែបសាមញ្ញថា “គាត់ជាស្ត្រីស្អាត”។ នៅក្នុងឃ្លានេះ ពាក្យ יְפַת ជាទម្រង់ផ្សាភ្ជាប់ (*construct* form) នៃពាក្យ יָפָה។

<u>កំណត់ចំណាំ</u>៖ យើងអាចនិយាយបែបម៉្យាងទៀតថា טוֹבַת מַרְאֶה («គាត់មានរូបរាងដ៏ល្អ») ដែលមានអត្ថន័យប្រហាក់ប្រហែលគ្នា។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 27 - ឲ្យ & យក; ប្រាក់ & មាស

## 27.1 **ឲ្យ** (**נָתַן**) & **យក** (**לָקַח**)

នៅក្នុងមេរៀនមុន យើងបានឃើញរួចមកហើយពីពាក្យបង្គាប់ដែលមានន័យថា “យក”៖ קַח។ នៅក្នុងមេរៀននេះ យើងនឹងរៀនពាក្យថ្មីដែលមានទម្រង់ចេញមកពីឫសពាក្យដូចគ្នា ដែលបញ្ជាក់ពីសកម្មភាពដែលបានកើតឡើងនៅអតីតកាល (ឧ. «គាត់បានយក» ឬ «អ្នកបានយក» ។ល។)។

នេះគឺជាទម្រង់ *qatal* ឯកវចនៈនៃឫសពាក្យ לָקַח៖

| | |
|---|---|
| គាត់[ប្រុស]បានយក (3MS)👳 | לָקַח |
| គាត់[ស្រី]បានយក (3FS)👩 | לָקְחָה |
| អ្នក[ប្រុស]បានយក (2MS)👳 | לָקַחְתָּ |
| អ្នក[ស្រី]បានយក (2FS)👩 | לָקַחְתְּ |
| ខ្ញុំបានយក (1CS) | לָקַחְתִּי |

នៅក្នុងមេរៀននេះ យើងក៏បង្រៀនពាក្យបង្គាប់ תֵּן (“ឲ្យមក!”

ពេលនិយាយទៅកាន់មនុស្សប្រុស)ហើយនិងពាក្យ *qatal* נָתַן (“គាត់[ប្រុស]បានឲ្យ”) ផងដែរ។

នេះគឺជាទម្រង់ *qatal* ឯកវចនៈនៃឫសពាក្យ נָתַן៖

| | |
|---|---|
| គាត់[ប្រុស]បានឲ្យ (3MS)👳 | נָתַן |
| គាត់[ស្រី]បានឲ្យ (3FS)👩 | נָתְנָה |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | |
|---|---|
| អ្នក[ប្រុស]បានឲ្យ (2MS)👳 | נָתַתָּ |
| អ្នក[ស្រី]បានឲ្យ (2FS)👩 | נָתַתְּ |
| ខ្ញុំបានឲ្យ (1CS) | נָתַתִּי |

កិរិយាសព្ទ נָתַן គឺជាកិរិយាសព្ទដែលមានព្យញ្ជនៈខ្សោយពីរ (*doubly weak* verb) ដោយព្រោះវាមានព្យញ្ជនៈ נ ពីរតួ។ ព្យញ្ជនៈ נ ខ្សោយដោយសារវាងាយនឹងចូលរួមជាមួយនឹងព្យញ្ជនៈដែលនៅបន្ទាប់វា (*assimilation*)។ ឧ. ពាក្យ נָתַתִּי ("ខ្ញុំបានឲ្យ") បានបាត់បង់ព្យញ្ជនៈ נ ទីពីរដោយសារវានៅជាប់ជាមួយនឹងបច្ច័យ 1CS תִּי។ តាមពិតវាមិនបានបាត់បង់ទាំងស្រុងទេ វាគ្រាន់តែច្របាច់បញ្ចូលជាមួយនឹងព្យញ្ជនៈបន្ទាប់វា ដូច្នេះយើងឃើញថា វាមានសញ្ញា *dagesh* នៅក្នុងវា៖ נָתַתִּי (ជាជាង נָתַנְתִּי)។

តាមរបៀបនេះ យើងអាចសម្គាល់ថា ឫសពាក្យដើមរបស់ពាក្យ נָתַתִּי គឺជា נָתַן ជាទម្រង់ដែលយើងឃើញនៅក្នុងវចនានុក្រម។

<u>កំណត់ចំណាំ</u>៖ នៅក្នុងបរិបទផ្សេង ពាក្យ נָתַן អាចមានអត្ថន័យផ្សេងថា "ដាក់"។

## 27.2 **កិរិយាសព្ទដែលមានទម្រង់ពហុវចនៈ**

ផ្នែកទីពីរនៃវិដេអូនេះ បង្ហាញអំពីសកម្មភាពរបស់មនុស្សជាពហុវចនៈ («ពួកយើង» «ពួកគេ» ឬ «អ្នករាល់គ្នា») ឧ.៖

אַבְרָם וְהַנְּעָרוֹת **לָקְחוּ** אֲבָנִים׃<br>
("លោកអាប់រ៉ាមហើយស្ត្រីវ័យក្មេងបានយកថ្ម")<br>
אֲנַחְנוּ **לָקַחְנוּ** אֲבָנִים׃<br>
("យើងបានយកថ្ម")<br>
**לְקַחְתֶּם** אֲבָנִים<br>
("អ្នករាល់គ្នាបានយកថ្ម")

ចូរចាំថា នៅពេលដែលមានភេទប្រុស ភេទស្រីជាចំរុះ នោះយើងប្រើពាក្យទម្រង់ភេទប្រុស ទោះបីជាមានមនុស្សភាគច្រើនជាភេទស្រីក៏ដោយ។ ដូច្នេះពាក្យ לְקַחְתֶּם אֲבָנִים ("អ្នករាល់គ្នាបានយកថ្ម") ជាទម្រង់បុរសទីពីរ ភេទប្រុស ពហុវចនៈ (មកពីឫសពាក្យ לָקַח) ដោយព្រោះលោកអាប់រ៉ាមនៅទីនោះដែរ។ ប្រសិនបើមនុស្សទាំងអស់ជាស្ត្រីសុទ្ធ នោះយើងនឹងប្រើទម្រង់ភេទស្រី៖ לְקַחְתֶּן ។

អ្នកអាចប្រើតារាងខាងក្រោមនេះ ដើម្បីជួយក្នុងការសម្គាល់ទម្រង់ពហុវចនៈដែលមានក្នុងវិដេអូ៖

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| ឫសពាក្យ | הָלַךְ | בּוֹא | נָתַן | הָיָה |
|---|---|---|---|---|
| ទម្រង់ (***qatal*** ពហុវ. **1CP**) | הָלַ֫כְנוּ<br>យើងបានទៅ/ដើរ | בָּ֫אנוּ<br>យើងបានមក | נָתַ֫נּוּ<br>យើងបានឲ្យ | הָיִינוּ<br>យើងបាន__ (we were) |

# មេរៀនទី 28 - អាពាហ៍ពិពាហ៍

## 28.1 ពាក្យថ្មី៖ רוּחַ

វាសំខាន់ដែលត្រូវយល់ថា ពាក្យ רוּחַ អាចមានន័យថា វិញ្ញាណ ដង្ហើម ឬ ខ្យល់។

<u>កំណត់ចំណាំ</u>៖ ពាក្យ רוּחַ មានស្រៈ *furtive pataḥ* ស្ថិតនៅក្រោមព្យញ្ជនៈចុងក្រោយនៃពាក្យ។ សម្រាប់ពត៌មាន បន្ថែមអំពី *furtive pataḥ* សូមមើលមេរៀនទី 19.3 ។




## 28.2 ការរំលឹកឡើងវិញអំពី *Vayyiqtol*

ដូចទៅនឹងអ្វីដែលយើងបានឃើញនៅក្នុងមេរៀនទី 22.3 ភាសាហេព្រើរប្រើទម្រង់កិរិយាសព្ទពិសេសសម្រាប់ពិពណ៌នាអំពីព្រឹត្តិការណ៍ដែលកើតឡើងបន្តបន្ទាប់គ្នា (sequence of events) ដែលគេហៅថា *vayyiqtol* (ឬ vav-consecutive-imperfect)។ កណ្ឌប្រវត្តិសាស្ត្រនៃគម្ពីរភាសាហេព្រើរបានប្រើប្រាស់ប្រភេទនៃទម្រង់កិរិយាសព្ទនេះផងដែរ។

នៅក្នុងមេរៀនមុនៗ យើងបានឃើញរួចមកហើយនូវពាក្យ וַיֹּ֫אמֶר («ហើយគាត់[ប្រុស]និយាយ»)។ នៅក្នុងមេរៀននេះ យើងបង្រៀនទម្រង់ 3FS នៃពាក្យខាងលើនេះ៖ וַתֹּ֫אמַר («ហើយគាត់[ស្រី]និយាយ») ដែរ។ ចូរចាំថា ជាធម្មតាក្នុងភាសាហេព្រើរគេចាប់ផ្តើមឃ្លាជាមួយនឹងកិរិយាសព្ទ ហើយបន្ទាប់បានប្រធានបទ ឧ.៖

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

וַיֹּאמֶר הָאִישׁ ... וַתֹּאמֶר הָאִשָּׁה...
«...ហើយបុរសនិយាយថា...ហើយស្ត្រីនិយាយថា...»
លំដាប់លំដោយនៃភាសាហេព្រើរ៖
"...ហើយនិយាយ (កិរិ.) បុរស (ប្រធាន.) ថា ...ហើយនិយាយ (កិរិ.) ស្ត្រី (ប្រធាន.) ថា"
នៅក្នុងមេរៀននេះ យើងក៏បានបង្រៀនផងដែរ អំពីទម្រង់ 3FS *vayyiqtol* នៃឫសពាក្យ הָיָה ("គឺជា")៖ וַתְּהִי ។ ឧ.៖

וַיְהִי אִישׁ וּשְׁמוֹ אֶלְקָנָה: וַתְּהִי אִשָּׁה וּשְׁמָהּ חַנָּה:

"ហើយមានបុរសម្នាក់ ហើយឈ្មោះគាត់[គឺ]អែលកាណា។ ហើយមាន ស្ត្រីម្នាក់ ហើយឈ្មោះគាត់[គឺ] ហាណា"

## 28.3 ការ «យក» & ការ «ឲ្យ» ប្រពន្ធ

ជាភាសាហេព្រើរ ដើម្បីនិយាយថា "គាត់រៀបការ" នោះគេនិយាយថា "គាត់យកប្រពន្ធសម្រាប់ខ្លួនឯង"៖ לָקַח לוֹ אִשָּׁה។ ឧ. ដើម្បីនិយាយថា "លោកអាប់រ៉ាមរៀបការជាមួយនាង Beth" នោះគេនិយាយថា៖ אַבְרָם לָקַח אֶת־בֵּת לוֹ לְאִשָּׁה: ។ អត្ថន័យត្រង់គឺ "លោកអាប់រ៉ាមយកនាង Beth ធ្វើជាប្រពន្ធសម្រាប់ខ្លួនឯង"។

នៅក្នុងព្រះគម្ពីរ ពេលម្តាយនិងឪពុករកប្រពន្ធឲ្យកូន គេប្រើពាក្យ "គេយកប្រពន្ធសម្រាប់កូនប្រុស" (លោក. 21:21, 38:6)។
រីឯឪពុកកូនក្រមុំក៏ប្រើទម្រង់ពាក្យដូចនេះដែរ គេឲ្យ (נָתַן) កូនស្រីធ្វើជាប្រពន្ធគាត់ ឧ.៖

לָבָן נָתַן לְיַעֲקֹב אֶת־לֵאָה בִּתּוֹ לוֹ לְאִשָּׁה:

ការបកប្រែតាមពាក្យ៖ "ឡាបាន់បានឲ្យលោកយ៉ាកុប នាងលេអាជាកូនស្រីគាត់សម្រាប់ជាប្រពន្ធ"

អត្ថន័យ៖ "ឡាបាន់បានឲ្យនាងលេអាជាកូនស្រីគាត់ ធ្វើជាប្រពន្ធលោកយ៉ាកុប"

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 29 - ធ្លាក់ផ្សេងទៀត

## 29.1 ក្រុង - עִיר

នៅក្នុងមេរៀននេះ ពេលដែលយើងរៀនពាក្យ עִיר ("ក្រុង" ឬ "ទីក្រុង" ឬ "ភូមិ") នាង Beth ជួយពន្យល់ថាពាក្យនេះ គឺជានាមមិនធម្មតា (irregular noun) ដោយសារទម្រង់ពហុវចនៈរបស់វាមានបច្ច័យភេទប្រុសនៅខាងចុង (ִים) ទោះបីជា ពាក្យ עִיר ភេទស្រី (נְקֵבָה)។ ដូច្នេះគ្រប់ទាំងគុណនាមដែលបញ្ជាក់ន័យឲ្យពាក្យ עִיר ត្រូវតែជាភេទស្រី។ ខាងក្រោមនេះគឺជាឧទាហរណ៍បែបពហុវចនៈនៃនាមមិនធម្មតា ដូចពាក្យ עִיר អញ្ចឹងដែរ៖

| | | |
|---|---|---|
| עָרִים גְּדֹלוֹת "ទីក្រុងធំៗ" | נָשִׁים טֹבוֹת "ស្រ្តីល្អៗ" | אֲבָנִים קְטַנּוֹת "ថ្មតូចៗ" |

## 29.2 ការនិយាយ - לֵאמֹר

ពាក្យ לֵאמֹר (មកពីពាក្យ "និយាយ") ជាពាក្យដែលគេប្រើញឹកញាប់បំផុត មានចំនួនជ 900 ដងជាងនៅក្នុងព្រះគម្ពីរហេព្រើរ ដូច្នេះវាមានសារៈសំខាន់សម្រាប់យើងក្នុងការស្គាល់ពីរបៀបប្រើប្រាស់វា។ ឫសពាក្យនៃកិរិយាសព្ទនេះគឺ אָמַר ។ តាមលក្ខណៈវេយ្យាករណ៍ ពាក្យ לֵאמֹר មានទម្រង់ជា *infinitive construct*។

គេហៅទម្រង់នេះ "*infinitive*" ដោយព្រោះវាមិនកំណត់ពីពេលវេលា (these verbs aren't bound by time)។ នេះមានន័យថា កិរិយាសព្ទទម្រង់ *infinitive construct* អាចសំដៅទៅលើសកម្មភាពដែលកើតឡើងនៅអតីតកាល អនាគតកាល ឬបច្ចុប្បន្នកាល។

គេប្រើទម្រង់ *infinitive construct* ដើម្បីជួយបន្ថែមន័យដល់កិរិយាសព្ទមួយទៀត ឧ. ពាក្យ «ដើរលេង» នៅក្នុងឃ្លា «ខ្ញុំចូលចិត្តដើរលេង»។ នៅទីនេះយើងឃើញថា ពាក្យ «ដើរលេង» មិនមែនជាកិរិយាសព្ទចំបងទេ ប៉ុន្តែវាដើរតួជាកម្មបទ (ចូរប្រៀបធៀបជាមួយឃ្លា «ខ្ញុំចូលចិត្តសៀវភៅ» ដែលមាននាមនៅខាងចុង)។ ភាសាអង់គ្លេស សម្រាប់ទម្រង់នេះ គេថែមពាក្យ "to" នៅកណ្ដាល ឧ. ពាក្យ "to go out" នៅក្នុងឃ្លា "I like to go out"។

ម៉្យាងទៀត ភាសាហេព្រើរប្រើទម្រង់ *infinitive construct* ជាមួយធ្នាក់។

នេះគឺជាអ្វីដែលយើងឃើញនៅក្នុងករណីរបស់ពាក្យ לֵאמֹר ដែលភ្ជាប់នឹងធ្នាក់ לְ ជាបុព្វបទ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ពាក្យ לֵאמֹר ជាពាក្យពិសេសមួយដែលមិនមាននៅក្នុងភាសាខ្មែរឬអង់គ្លេស។ យើងអាចនិយាយថាវាស្រដៀងគ្នានឹងពាក្យ «ថា» នៅក្នុងឃ្លា «គាត់បាននិយាយទៅកាន់មិត្តគាត់ថា» ប៉ុន្តែតាមពិតពាក្យ «ថា» ក៏ខុសគ្នាដែរ ដោយសារគេប្រើពាក្យ לֵאמֹר សម្រាប់តែការនិយាយប៉ុណ្ណោះ ហើយម៉្យាងទៀត ភាសាហេព្រើរមានពាក្យមួយទៀតដែលមានន័យថា «ថា»៖ כִּי (ឧ.៖

ចៅ. 3:10 “אָמַ֫רְתִּי כִּי־שָׂנֹא שְׂנֵאתָהּ
«ខ្ញុំបាននិយាយថា អ្នកពិតជាស្អប់នាងមែន»

យ៉ាងណាក៏ដោយ ភាគច្រើនយើងអាចបកប្រែពាក្យ לֵאמֹר ជា «ថា» (ឧ. លោក. 1:22) ដោយព្រោះ ពាក្យ לֵאמֹר បង្ហាញដល់អ្នកអានថា ប្រយោគបន្ទាប់គឺជា កថាបទផ្ទាល់ ឬ ពាក្យសំដីផ្ទាល់របស់គេ។ ឧទាហរណ៍ នៅដើមរឿងយ៉ូណាស យើងឃើញពាក្យ៖

וַיְהִי דְּבַר־יְהוָה אֶל־יוֹנָה לֵאמֹר לֵךְ אֶל־נִינְוֵה
“ហើយព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកកាន់លោកយ៉ូណាស់ថា ‘ចូរទៅក្រុងនីនីវេ’”

## 29.3 ធ្នាក់ מִן

ធ្នាក់ מִן («ពី») អាចជាធ្នាក់ធម្មតា ឬជាបុព្វបទធ្នាក់ដែលនៅជាប់នឹងនាម។ ប្រសិនបើយើងប្រើជាធ្នាក់ធម្មតា នោះវាសរសេរដាច់ដោយឡែកពីនាម ដោយត្រូវការភ្ជាប់ជាមួយនឹងនាមដោយសញ្ញា *maqqef* (សូមមើល ផ្នែក 5.4)។ ឧ.៖

ជាបុព្វបទធ្នាក់៖ מֵאֶרֶץ מִצְרַיִם («ពីស្រុកអេស៊ីប»)

ដាច់ដោយឡែក៖ מִן־הַיְאֹר («ពីទន្លេនីល»)

នៅពេលដែលធ្នាក់ מִן ធ្វើជាបុព្វបទភ្ជាប់នឹងនាម នោះគឺមានច្បាប់ខ្លះដែលយើងត្រូវចាំ៖

1. នៅពេលដែលយើងប្រើធ្នាក់ מִן នៅខាងមុខព្យញ្ជនៈដែលមិនមែន guttural[20] នោះព្យញ្ជនៈ ן ចូលរួម (*assimilates*) ជាមួយនឹងព្យញ្ជនៈដែលនៅបន្ទាប់វា ហើយក្លាយទៅជាសញ្ញា *dagesh forte* ។ ឧ.៖ מִבֵּיתוֹ אֶל־הַיָּם («ពីផ្ទះគាត់ទៅសមុទ្រ»)
2. នៅពេលដែលយើងភ្ជាប់ធ្នាក់ מִן ជាមួយពាក្យដែលមានស្រៈ *shewa* ពីក្រោមព្យញ្ជនៈដើមនៃពាក្យ នោះសញ្ញា *dagesh forte* អាចនឹងត្រូវបាត់។ ប្រសិនបើព្យញ្ជនៈដើមនៃពាក្យនោះគឺជា י នោះស្រៈ *shewa* នឹងត្រូវបាត់ដែរ។ ឧ.៖ מִיהוּדָה («ពីយូដាស») = מִן + יְהוּדָה

[20] ព្យញ្ជនៈបែប guttural គឺជាព្យញ្ជនៈដែលមានសម្លេងត្រង់បំពុងក ឧ. א ח ហើយនឹង ע។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

3. នៅពេលដែលយើងភ្ជាប់ធ្នាក់ מִן ជាមួយព្យញ្ជនៈ guttural នោះស្រៈរបស់ធ្នាក់ מִן ក្លាយទៅជាស្រៈសម្លេងវែង *tsere* ( ֵ ) ។ ដោយព្រោះព្យញ្ជនៈ guttural មិនអាចប្រើជាមួយសញ្ញា *dagesh forte* នោះគេបង្អូសសម្លេងរបស់ស្រៈ *hireq* ( ִ ) ឲ្យវែងជាង ទៅជា *tsere* ( ֵ ) ("compensatory lengthening")។ ឧ.៖
   - מֵאֶרֶץ מִצְרַיִם («ពីស្រុកអេស៊ីប»)
   - קַח אֶת־הַכּוֹס מֵעַל רֹאשִׁי («យកពែងចេញពីលើក្បាលខ្ញុំ»)

## 29.4 ធ្នាក់ផ្សេងទៀត

### ធ្នាក់ סָבִיב

ភាគច្រើនពាក្យ סָבִיב មានន័យថា "ជុំវិញ"។ ជួនកាល កម្មបទរបស់វាភ្ជាប់នឹងធ្នាក់ לְ ។ ឧ.៖

אַבְרָם הָלַךְ סָבִיב לַכִּסֵּא
"លោកអាប់រ៉ាមដើរជុំវិញកៅអី ។"

<u>កំណត់ចំណាំ</u>៖ នៅក្នុងករណីនេះ ជាភាសាខ្មែរ យើងអត់បកប្រែធ្នាក់ לְ ទេ។

### ធ្នាក់ עַד

ធ្នាក់ עַד មានន័យថា "ដល់" "រហូតដល់" "ឆ្ពោះទៅរក" ឬ "ខណៈពេល" ។ ដូចគ្នានឹងធ្នាក់ជាច្រើនទៀតក្នុងភាសាហេព្រើរ អាចមានអត្ថន័យច្រើន យោងទៅលើបរិបទរបស់វា។ នៅក្នុងមេរៀននេះ ធ្នាក់ עַד មានន័យថា "ដល់" ឬ "រហូតដល់" ។ ឧ.៖

הַסּוּס הָלַךְ עַד־הַבַּיִת׃
"សេះដើររហូតដល់ផ្ទះ"
מֵעַתָּה עַד־עוֹלָם
"ចាប់ពីឥឡូវរហូតដល់អស់កល្ប"

### ធ្នាក់ עִם־

យើងក៏រៀនធ្នាក់ עִם־ នៅក្នុងមេរៀននេះផងដែរ ដែលមានន័យថា "ជាមួយ" "ដោយ" "នៅក្បែរ" ឬ "នៅជិត" យោងទៅលើបរិបទ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 30 - បច្ច័យកម្មសិទ្ធ (“Possessive Suffixes”) ផ្នែកទី៣ - នាមពហុវចនៈភេទប្រុសដែលមានបច្ច័យ

នៅពេលដែលបច្ច័យកម្មសិទ្ធភ្ជាប់នឹងនាមពហុវចនៈ នោះវាមានលក្ខណៈផ្លែកពីធម្មតាបន្តិច។ ម៉្យាងទៀត ទម្រង់របស់បច្ច័យកម្មសិទ្ធមានការផ្លាស់ប្តូរពេលវាភ្ជាប់ជាមួយនឹងនាមពហុវចនៈភេទ<u>ប្រុស</u> ជាជាងនាមពហុវចនៈភេទ<u>ស្រី</u>។

យ៉ាងណាក៏ដោយ សូមកុំអស់សង្ឃឹមឡើយ! ពីព្រោះទម្រង់គ្រឹះរបស់វាគឺនៅតែដដែល។

នៅក្នុងមេរៀននេះ បានលើកយកនូវបច្ច័យកម្មសិទ្ធពេលវាភ្ជាប់ជាមួយនឹង<u>នាមពហុវចនៈភេទប្រុស</u>។ ចំណុចគន្លឹះក្នុងការសម្គាល់ថាបច្ច័យទាំងនេះ ភ្ជាប់នឹងនាមជា<u>ពហុវចនៈ</u> គឺដោយសារបច្ច័យដែលភ្ជាប់នឹងនាមពហុវចនៈតែងតែមានព្យញ្ជនៈ *yod* ’י។ តារាងនៅខាងនេះ បង្ហាញពីបច្ច័យដែលអាចភ្ជាប់ជាមួយនឹងនាមពហុវចនៈ៖

| | | | | |
|---|---|---|---|---|
| 3MS របស់គាត់[ប្រុស]🧔 | ָיו - | | 3MP (របស់ពួកគាត់[ប្រុស]) 🧔🧔 | ֵיהֶם - |
| 3FS របស់គាត់[ស្រី]👩 | ֶיהָ - | | 3FP (របស់ពួកគាត់[ស្រី])👩 👩 | ֵיהֶן - |
| 2MS របស់អ្នក[ប្រុស]🧔 | ֶיךָ - | | 2MP របស់អ្នករាល់គ្នា[ប្រុស] 🧔🧔 | ֵיכֶם - |
| 2FS របស់អ្នក[ស្រី]👩 | ַיִךְ - | | 2FP របស់អ្នករាល់គ្នា[ស្រី] 👩👩 | ֵיכֶן - |
| 1CS របស់ខ្ញុំ👩🧔 | ַי - | | 1CP របស់យើង 👩🧔 | ֵינוּ - |

<u>កំណត់ចំណាំ</u>៖ មានរឿងពីរយ៉ាង គឺ (១) តើ<u>បច្ច័យ</u>មានលក្ខណៈជាពហុវចនៈឬឯកវចនៈ និង (២) តើ<u>នាម</u>ដែលភ្ជាប់នឹងបច្ច័យ មានលក្ខណៈជាពហុវចនៈឬឯកវចនៈ។ ឥឡូវនេះ

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

យើងផ្តោតទៅលើ ចំណុចទី២។ សូមបញ្ជាក់ថា បច្ច័យពហុវចនៈនិង បច្ច័យឯកវចនៈ អាចភ្ជាប់នឹងនាមពហុវចនៈ។ ដូច្នេះ តារាងនៅខាងលើមានទាំងបច្ច័យពហុវចនៈនិងឯកវចនៈ តែទម្រង់ទាំងអស់នោះ គឺប្រើសម្រាប់ ភ្ជាប់ជាមួយនឹងនាមពហុវចនៈប៉ុណ្ណោះ។

យើងលើកឧទាហរ៍សម្រាប់បច្ច័យទាំងអស់នេះ នៅក្នុង មេរៀនជាវិដេអូទី៣០ ។ អ្នកក៏អាចអាន ឯកសារនេះ (Google Doc) ដែលមានសរសេរពាក្យទាំងអស់ ដែលយើងនិយាយក្នុងមេរៀនមួយនេះផងដែរ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 31 - លេខ 6-10

## 31.1 **លេខ** 6-10

នៅក្នុងមេរៀននេះ យើងរៀនពីលេខ 6-10 (ប្រសិនបើរំលឹកឡើងវិញពីលេខ 1-5, សូមមើល ផ្នែក 12.1)។ ចូរចាំថា លេខក៏មានភេទ មានវចនៈ ដូចជាគុណនាមឯទៀតដែរ។

ម្យ៉ាងទៀត ដូចជាអ្វីដែលយើងរៀននៅក្នុងមេរៀនទី១២ ពេលយើងរាប់ យើងប្រើទម្រង់ភេទស្រី។

| | ភេទប្រុស | ភេទស្រី |
|---|---|---|
| 6 ◦◦◦◦◦◦ | שִׁשָּׁה | שֵׁשׁ |
| 7 ◦◦◦◦◦◦◦ | שִׁבְעָה | שֶׁבַע |
| 8 ◦◦◦◦◦◦◦◦ | שְׁמֹנָה | שְׁמֹנֶה |
| 9 ◦◦◦◦◦◦◦◦◦ | תִּשְׁעָה | תֵּשַׁע |
| 10 ◦◦◦◦◦◦◦◦◦◦ | עֲשָׂרָה | עֶשֶׂר |

ក្នុងភាសាហេព្រើរ លេខអាចស្ថិតនៅខាងមុខ ឬ ខាងក្រោយនាម។ ប៉ុន្តែភាគច្រើន គេនិយាយលេខ១ (אֶחָד / אַחַת) នៅខាង<u>ក្រោយ</u>នាម ហើយលេខឯទៀត នៅខាងមុខនាម។

| | | |
|---|---|---|
| 🧍 | បុរសម្នាក់ | אִישׁ אֶחָד |
| 🧍 🧍 🧍 🧍 🧍 🧍 | មនុស្ស/បុរស ប្រាំមួយនាក់ | שִׁשָּׁה אֲנָשִׁים |
| 🧍 🧍 🧍 🧍 🧍 🧍 🧍 🧍 | មនុស្ស/បុរស ប្រាំបីនាក់ | שְׁמֹנָה אֲנָשִׁים |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ដូចជាអ្វីដែលយើងបាននិយាយរួចមកហើយ (សូមមើល ផ្នែក 12.1) ចំនួនលើខជាភាសាហេព្រើរមានការស្មុគស្មាញ ដោយព្រោះទម្រង់លេខភេទប្រុស គឺបញ្ចប់ដោយស្រៈ ה ָ- ដែលភាគច្រើនគេប្រើសម្រាប់នាមស្រី (ឧ. אֲנָשִׁים שִׁשָּׁה)។ ផ្ទុយទៅវិញ ទម្រង់លេខភេទស្រី គឺមិនបញ្ចប់ដោយស្រៈ ה ָ- ដែលធម្មតាជាលក្ខណៈរបស់ភេទប្រុស។

យើងលើកឧទាហរ៍សម្រាប់បច្ច័យទាំងអស់នេះ នៅក្នុង មេរៀនជាវិដេអូទី៣១ ។ អ្នកក៏អាចអាន ឯកសារនេះ (Google Doc) ដែលមានសរសេរពាក្យទាំងអស់ ដែលយើងនិយាយក្នុងមេរៀនមួយនេះផងដែរ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 32 - ពួកហោរា & កិរិយាសព្ទផ្សេងៗទៀត

## 32.1 កិរិយាសព្ទថ្មី

דִּבֵּר - គាត់បាននិយាយ
יָשַׁב - គាត់បានអង្គុយ ឬ រស់នៅ
קָם - គាត់បានក្រោកឡើង ឬ ឈរឡើង
רָאָה - គាត់បានឃើញ
קָרָא - គាត់បានហៅ

## 32.2 דִּבֵּר & Piel Stem

ពាក្យ דִּבֵּר មានស្រៈខុសគ្នាពីកិរិយាសព្ទផ្សេង ដែលយើងបានឃើញពីមុន។ មូលហេតុគឺកិរិយាសព្ទនេះប្រើជា *piel stem*។ សូមមើល [ផ្នែក 21.4] ដើម្បីរំលឹកពី *binyanim* (ភាសាអង់គ្លេស *stems*)។ មកដល់ពេលនេះ យើងឃើញមានកិរិយាសព្ទជាច្រើនដែលមាន *qal* stem ដែលភាសាហេព្រើរប្រើច្រើនជាងគេ (ប្រហែលជា 70% នៃកិរិយាសព្ទទាំងអស់ក្នុងព្រះគម្ពីរ)។

យ៉ាងណាក៏ដោយ ពាក្យ דִּבֵּר មាន *piel* stem។ យើងនឹងពន្យល់បន្ថែមទៀតពីលក្ខណៈនៃ *piel stem*នៅពេលក្រោយ។ សម្រាប់មេរៀននេះ យើងត្រូវរៀនចេះសម្គាល់ទម្រង់ពាក្យដែលមាន *piel* stem។ យើងអាចសម្គាល់វាបានដោយចំណុចទាំងពីរនេះ៖

1. *piel* stem មានសញ្ញា *dagesh forte* នៅក្នុងព្យញ្ជនៈទីពីរនៃឫសពាក្យរបស់វា ដែលមានន័យថា យើងត្រូវបញ្ចេញសម្លេងនៃព្យញ្ជនៈនោះពីរដង៖ דִּבֵּר
2. នៅពេលដែលគេប្រើ *piel* stem ជាទម្រង់ 3MS *perfective* (qatal) នោះវាភាគច្រើនគឺស្រៈគឺជា *hireq* ִ និង *tsere* ֵ (ជាភាសាអង់គ្លេស យើងនិយាយថាវាមាន "i/e vowel pattern")។

<u>កំណត់ចំណាំ</u>៖ ស្រៈរបស់កិរិយាសព្ទនឹងផ្លាស់ប្តូរអាស្រ័យទៅលើ ភេទ វចនៈ និងទម្រង់របស់វា។

## 32.3 רָאָה

នៅក្នុង [ផ្នែក 21.3] យើងបានណែនាំឲ្យស្គាល់កិរិយាសព្ទខ្សោយ។ យើងបានឃើញថាព្យញ្ជនៈ ה ខ្សោយដែរ។ ដូច្នេះហើយបានជា កិរិយាសព្ទ רָאָה («គាត់បានឃើញ») រាប់ជាកិរិយាសព្ទខ្សោយដែរ

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ហើយពេលដែលយើងបន្ថែមកន្ទុយពាក្យទៅវា នោះព្យញ្ជនៈ ה នឹងត្រូវយកចេញ។ ឧ. ពាក្យ רָאוּ )“ពួកគេបានឃើញ”( វាបានបាត់បង់នូវ ה។

ចំណុចវេយ្យាករណ៍នេះ មិនសំខាន់សម្រាប់ការនិយាយនៅក្នុងភាសាហេព្រើរ ប៉ុន្តែវាសំខាន់ប្រសិនបើយើងចង់ស្វែងរកពាក្យ רָאוּ នៅក្នុងវចនានុក្រម ដោយសារយើងត្រូវស្គាល់ឫសនៃពាក្យ (רָאָה) ដើម្បីស្វែងរកវា។

ឧទាហរណ៍ផ្សេងទៀតដែលមានលក្ខណៈខុសផ្លែកពីទម្រង់ធម្មតា គឺទម្រង់ 3FS רָאֲתָה (“គាត់[ស្រី]បានឃើញ”)។ ចូរកត់សម្គាល់ថា ព្យញ្ជនៈ ה ត្រូវបានបាត់បង់ ហើយវាជំនួសមកវិញដោយ ת ។ ឧទាហរណ៍មួយទៀត ទម្រង់ 1CS רָאִ֫יתִי (“I saw”) ה ក្លាយទៅជា י ។

# មេរៀនទី 33 - ពាក្យ אֶת־ ជាមួយកម្មបទផ្ទាល់

## 33.1 **ការរំលឹកអំពីភាពជាក់លាក់ ជាមួយឧទាហរណ៍**

នៅក្នុង មេរៀន 6.3 យើងបានណែនាំឲ្យស្គាល់រួចមកហើយ នូវពាក្យ[21] אֶת־ ដែលប្រើជាមួយនឹងកម្មបទផ្ទាល់ ។ រីឯមេរៀននេះ យើងពន្យល់បន្ថែមពីរបៀបនៃការប្រើប្រាស់ពាក្យ אֶת־ ហើយក៏លើកឧទាហរណ៍ខ្លះថែមទៀត។

នៅក្នុងភាសាហេព្រើរ នាមជាក់លាក់ (definite nouns) អាចជា៖

1. នាមដែលមានបុព្វបទ הָ/הַ មានន័យដូចភាសាអង់គ្លេស “the” (ឧ. הָאֶבֶן “the stone” ឬ «ថ្ម ហ្នឹង»)
2. នាមដែលជាកម្មសិទ្ធ (ឧ. עַבְדּוֹ “អ្នកបំរើរបស់គាត់”)។
3. នាមអសាធារណៈ (ឧ. מֹשֶׁה “លោកម៉ូសេ”)។

ពាក្យ אֶת־ អាចប្រើបាន តែជាមួយនាមជាក់លាក់ប៉ុណ្ណោះ។ នៅខាងក្រោមនេះ គឺជាឧទាហរណ៍ស្តីពី ប្រភេទនាមជាក់លាក់បីយ៉ាង ដែលប្រើជាមួយពាក្យ אֶת־ ៖

1. יִתְרוֹ נָתַן אֶת־הַבַּת לְמֹשֶׁה លោកយេត្រូបានឲ្យកូនស្រីទៅលោកម៉ូសេ

[21] យោងតាមលក្ខណៈវេយ្យាករណ៍ אֶת־ មិនមែនជាពាក្យទេ តែភាសាអង់គ្លេសហៅវាជា “particle” ។ យ៉ាងណាក៏ដោយ យើងហៅវាថាជាពាក្យនៅក្នុងមេរៀនជាភាសាខ្មែរនេះ ដើម្បីឲ្យងាយយល់។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

2. יִתְרוֹ נָתַן אֶת־בִּתּוֹ לְמֹשֶׁה
   លោកយេត្រូបានឲ្យកូនស្រីរបស់គាត់ទៅលោកម៉ូសេ
3. יִתְרוֹ נָתַן אֶת־צִפֹּרָה לְמֹשֶׁה
   លោកយេត្រូបានឲ្យនាងសេផូរ៉ាទៅលោកម៉ូសេ

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 34 - ការពិត ការកុហក ហើយនិងពាក្យបង្គាប់

## 34.1 «គាត់មិនមែនជា____ ខ្ញុំមិនមែនជា____ ប៉ុន្តែជា________!»

នៅផ្នែកដំបូងនៃមេរៀននេះ យើងរៀនពីរបៀបនៃការនិយាយថា “គាត់មិនមែនជា...” ឬក៏ “ខ្ញុំមិនមែនជា...”៖

אֵינֶנּוּ ← הוּא + אֵין “គាត់មិនមែនជា...”

אֵינֶנִּי ← אֲנִי + אֵין “ខ្ញុំមិនមែនជា...”

ដើម្បីបង្ហាញពីភាពផ្ទុយគ្នា (“តែជា...”) នោះយើងប្រើពាក្យ כִּי אִם ។
ឧទាហរណ៍ដើម្បីនិយាយថា “ខ្ញុំមិនមែនជាគោទេ! តែខ្ញុំជាស្ត្រី!”
នៅក្នុងភាសាហេព្រើរគេនិយាយបែបដូចនេះ៖

אֵינֶנִּי פָּרָה כִּי אִם־אִשָּׁה:

ការបកប្រែបែបម៉្យាងទៀត គឺថា៖ “ខ្ញុំមិនមែនជាគោទេ! ផ្ទុយទៅវិញខ្ញុំជាស្ត្រី!”។
សូមបញ្ជាក់ថា មានបរិបទមួយចំនួនដែលយើងមិនអាចប្រើពាក្យ כִּי אִם ជំនួសពាក្យខ្មែរ «ប៉ុន្តែ» នោះទេ។ អាចប្រើតែក្នុងបរិបទដែលយើងបដិសេធអ្វីដែលយើងនិយាយខាងដើម («ខ្ញុំមិនមែនជាគោទេ...») ហើយជំនួសមកវិញនូវការបញ្ជាក់ផ្សេង («...ផ្ទុយទៅវិញខ្ញុំជាស្ត្រី!»)។ ឧទាហរណ៍មួយទៀត៖

אֵינֶנּוּ חֲמוֹר כִּי אִם־גִּבּוֹר:
(“គាត់មិនមែនជាសត្វលាទេ ផ្ទុយទៅវិញគាត់ជាអ្នកចម្បាំង”)

## 34.2 ការពិត & ការកុហក

אֱמֶת = ការពិត

שֶׁקֶר = ការកុហក

אֱמֶת គឺជាលក្ខណៈគន្លឹះនៃព្រះ។ ពាក្យនេះមានអត្ថន័យទូលំទូលាយ។ នៅក្នុងមេរៀននេះ យើងផ្តោតទៅលើអត្ថន័យតែមួយប៉ុណ្ណោះទេ គឺ “ការពិត” ប៉ុន្តែវាអាចមានន័យថា «ភាពស្មោះត្រង់»។ រីឯពាក្យ שֶׁקֶר មានន័យថា ការកហុក ការបញ្ឆោត ភាពមិនពិត ឬ ការបោកប្រាស់។ ឧ.៖

- אֱמֶת הַדָּבָר “រឿងនេះជាការពិត”
- שֶׁקֶר הַדָּבָר “រឿងនេះជាការកហុក”

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

## 34.3 ទម្រង់ពាក្យបង្គាប់ ( imperative verbs )

קוּם

ជាបន្ទាប់ទៅនេះ យើងរៀនកិរិយាសព្ទមួយទៀត ដែលជាទម្រង់ពាក្យបង្គាប់ (imperative) **קוּם** ដែលមានន័យថា “ក្រោកឡើង!” ឬ “ឈរឡើងទៅ!” ទម្រង់ភេទប្រុស (ដែលយើងប្រើដើម្បីបង្គាប់មនុស្សប្រុស) គឺជា **קוּם** ហើយទម្រង់ភេទស្រីគឺជា קוּמִי។

שֵׁב

នៅពេលដែលយើងបង្គាប់នរណាម្នាក់ថា “អង្គុយចុះ!” យើងប្រើពាក្យ **שֵׁב** សម្រាប់មនុស្សប្រុសនិងពាក្យ שְׁבִי សម្រាប់មនុស្សស្រី។

*שְׁמַע* និង *דַּבֵּר*

នៅពេលដែលយើងបង្គាប់មនុស្សប្រុសម្នាក់ថា “ចូរស្តាប់!” យើងប្រើពាក្យ **שְׁמַע** ហើយដើម្បីបង្គាប់មនុស្សប្រុសម្នាក់ថា “ចូរនិយាយ!” នោះយើងប្រើពាក្យ **דַּבֵּר**។ ឧ. នៅពេលនាង Beth បង្គាប់លោកអាប់រ៉ាមឲ្យនិយាយ គាត់បានឆ្លើយតបដោយបញ្ចេញសម្លេងថា៖ “בָּבֶלְבָּבֵלְבָּבֶלְבָּבֶלְבָּבֶלְבָּבֶל” ដែលស្រដៀងគ្នានឹងភាសាខ្មែរ “ឡូ!ឡូ!ឡូ!ឡូ!” អត់មានអត្ថន័យទេ។

קְרָא

នៅពេលដែលយើងបង្គាប់មនុស្សប្រុសម្នាក់ថា “ហៅ!” (ឧ. ចោទ. 31:14) នោះយើងនិយាយថា **קְרָא!**។ តាមពិតពាក្យ “קְרָא” អាចមានន័យផ្សេងទៀតដូចជា “ស្រែកហៅ!/ប្រកាស់ហៅ!” (ឧ. ចៅ. 7:3) “ដាក់ឈ្មោះថា!” (ឧ. អេសាយ 8:3) ឬ “អានចុះ!” (ឧ. អេសាយ 29:11)។ យ៉ាងណាក៏ដោយ នៅក្នុងមេរៀនជាវិដេអូនេះយើងផ្តោតទៅលើអត្ថន័យតែមួយ គឺ “អាន” ឧ.៖

קְרָא בַּסֵּפֶר הַזֶּה: קַח אֶת־הַסֵּפֶר וּקְרָא בְּאָזְנַי:

“ចូរអានសៀវភៅ! យកសៀវភៅនេះ ហើយអានឲ្យត្រចៀកខ្ញុំលឺ” (ឬ តាមន័យពាក្យ៖ «...ហើយអានក្នុងត្រចៀកខ្ញុំ»)

<u>កំណត់ចំណាំ៖</u> ឥឡូវយើងរៀនតែទម្រង់ឯកវចនៈប៉ុណ្ណោះ យើងត្រូវប្រើទម្រង់ផ្សេង ពេលយើងបង្គាប់ទៅមនុស្សមួយក្រុម។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 35 - ផ្លែឈើ & ធ្នាក់ដែលមានបច្ច័យជាប់ជាមួយ

## 35.1 **ការភ្ជាប់បច្ច័យជាមួយធ្នាក់**

ដើម្បីភ្ជាប់បច្ច័យជាមួយធ្នាក់ យើងត្រូវធ្វើតាមតារាងនៅខាងក្រោម៖

3MS (បុរសទីបី ភេទប្រុស ឯកវចនៈ)៖

| | | |
|---|---|---|
| ទៅគាត់[ប្រុស] | לוֹ | לְ + הוּא |
| នៅក្នុងគាត់[ប្រុស] | בּוֹ | בְּ + הוּא |
| នៅលើគាត់[ប្រុស] | עָלָיו | עַל + הוּא |
| ទៅគាត់[ប្រុស] | אֵלָיו | אֶל + הוּא |
| នៅចំពោះមុខគាត់[ប្រុស] | לְפָנָיו | לִפְנֵי + הוּא |
| នៅក្រោយគាត់[ប្រុស] | אַחֲרָיו | אַחֲרֵי + הוּא |
| នៅក្រោមគាត់[ប្រុស] | תַּחְתָּיו | תַּחַת + הוּא |

3FS (បុរសទីបី ភេទស្រី ឯកវចនៈ)៖

| | | |
|---|---|---|
| នៅចំពោះមុខគាត់[ស្រី] | לְפָנֶיהָ | לִפְנֵי + הִיא |
| នៅក្រោយគាត់[ស្រី] | אַחֲרֶיהָ | אַחֲרֵי + הִיא |
| នៅក្រោមគាត់[ស្រី] | תַּחְתֶּיהָ | תַּחַת + הִיא |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | |
|---|---|---|
| នៅលើគាត់[ស្រី ] | עָלֶיהָ | עַל + הִיא |
| ទៅគាត់[ស្រី] | אֵלֶיהָ | אֶל + הִיא |

3MP (បុរសទីបី ភេទប្រុស ពហុវចនៈ)៖

| | | |
|---|---|---|
| នៅក្រោយពួកគាត់[ប្រុស] | אַחֲרֵיהֶם | אַחֲרֵי + הֵם |
| នៅក្រោមពួកគាត់[ប្រុស] | תַּחְתֵּיהֶם | תַּ֫חַת + הֵם |
| នៅលើពួកគាត់[ប្រុស] | עֲלֵיהֶם | עַל + הֵם |

2MS (បុរសទីពីរ ភេទប្រុស ឯកវចនៈ)៖

| | | |
|---|---|---|
| នៅចំពោះមុខអ្នក [ប្រុស] | לְפָנֶיךָ | לִפְנֵי + אַתָּה |
| នៅក្រោយអ្នក[ ប្រុស] | אַחֲרֶיךָ | אַחֲרֵי + אַתָּה |
| នៅក្រោមអ្នក[ប្រុស] | תַּחְתֶּיךָ | תַּ֫חַת + אַתָּה |
| នៅលើអ្នក[ប្រុស ] | עָלֶיךָ | עַל + אַתָּה |

1CS (បុរសទីមួយ អាចជាភេទទាំងពីរ ឯកវចនៈ)៖

| | | |
|---|---|---|
| នៅលើខ្ញុំ | עָלַי | עַל + אֲנִי |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | |
|---|---|---|
| ទៅខ្ញុំ | אֵלַי | אֶל + אֲנִי |
| នៅចំពោះមុខខ្ញុំ | לְפָנַי | לִפְנֵי + אֲנִי |
| នៅក្រោយខ្ញុំ | אַחֲרַי | אַחֲרֵי + אֲנִי |
| នៅក្រោមខ្ញុំ | תַּחְתַּי | תַּחַת + אֲנִי |

### 35.2 מַעֲשֶׂה

នៅក្នុងមេរៀននេះ យើងរៀនពីពាក្យ מַעֲשֶׂה ដែលជានាមមានន័យថា កិច្ចការ ការងារ ឬក៏ស្នាដៃ។ នៅពេលយើងពិនិត្យមើលពាក្យនេះ យើងឃើញច្បាស់ថា ពាក្យ מַעֲשֶׂה មកពីឫសពាក្យ עשׂה ដែលមានន័យថា ធ្វើ ឬ បង្កើត។ កំណត់ចំណាំ៖ ជាញឹកញាប់ យើងបង្កើតនាមចេញពីកិរិយាសព្ទដោយបន្ថែមបុព្វបទ מ ទៅលើឫសពាក្យនៃកិរិយាសព្ទនោះ។

## មេរៀនទី 36 - សាច់និងឈាម អាសនានិងការចាក់ប្រេងតាំង

### 36.1 វគ្គសព្ទថ្មី

ភាគច្រើននៃមេរៀននេះផ្តោតទៅលើការបង្រៀនពាក្យថ្មី៖

- בָּשָׂר - សាច់ ឬ សាច់ឈាម
- דָּם - ឈាម
- דָּמִים - ឈាមដែលត្រូវបានខ្ចាយ (កំណត់ចំណាំ៖ ពាក្យនេះគ្រាន់តែជាទម្រង់ពហុវចនៈនៃពាក្យ דָּם ប៉ុន្តែវាសំដៅទៅលើឈាមដែលចេញពីរាងកាយ ដោយសារភាពឃោរឃៅ)។
- זֶבַח - យញ្ញបូជា
- מָשַׁח – គាត់បានចាក់ប្រេងតាំង

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 37 - ស្លាប់ & រស់

## 37.1 בָּנָה - "សង់"

ពាក្យ בָּנָה ជាកិរិយាសព្ទដែលមានន័យថា "គាត់សង់"។ ឧ.៖ אַבְרָם בָּנָה מִזְבֵּחַ ("លោកអាប់រ៉ាមបានសង់អាសនា"។

## 37.2 ស្លាប់ & រស់

នៅក្នុងមេរៀននេះ យើងណែនាំឲ្យស្គាល់ពាក្យ מֵת («ស្លាប់») חַי («រស់»)។ នៅក្នុងភាសាខ្មែរ ប្រើជាកិរិយាសព្ទ ប៉ុន្តែនៅក្នុងភាសាហេព្រើរប្រើជាគុណនាម។ ទម្រង់ទាំងពីរនោះ បន្ថែមន័យឲ្យនាមភេទប្រុស រីឯនាមភេទស្រី ត្រូវប្រើជាមួយ מֵתָה និង חַיָּה។ ចំណែកឯទម្រង់ពហុវចនៈយើងប្រើ חַיִּים និង מֵתִים វិញ។ ឧ. និក្ខមនំ 14:30៖

וַיַּרְא יִשְׂרָאֵל אֶת־מִצְרַיִם מֵת עַל־שְׂפַת הַיָּם
"ហើយអ៊ីស្រាអែលបានឃើញពួកអេស៊ីបស្លាប់នៅក្បែរមាត់សមុទ្រ"

ពាក្យដើមដំបូងគឺ וַיַּרְא ដែលមានទម្រង់ជា *vayyiqtol* នៃឫសពាក្យ רָאָה ហើយមានន័យថា "ហើយគាត់បានឃើញ"។

<u>កំណត់ចំណាំ</u>៖ នៅទីនេះ ពាក្យ יִשְׂרָאֵל
ជាទម្រង់ឯកវចនៈហើយសំដៅទៅលើសាសន៍អ៊ីស្រាអែលជាក្រុម
ដូច្នេះកិរិយាសព្ទត្រូវប្រើជាឯកវចនៈដែរ
ទោះបីវានិយាយអំពីចំនួនមនុស្សជាច្រើនក៏ដោយ។

## 37.3 וַיֵּרַע

សូមមើល មេរៀន 11.3
ដើម្បីរំលឹកពីរបៀបដែលភាសាហេព្រើរពិពណ៌នាអ្វីមួយដែលជាការល្អឬអាក្រក់នៅចំពោះភ្នែកនរណាម្នាក់។

សូមបញ្ជាក់ថា ពាក្យខាងក្រោមងាយស្រួលធ្វើឲ្យយើងយល់ច្រឡំ៖

| | | |
|---|---|---|
| וַיֵּרַע | ទម្រង់ *vayyiqtol* នៃឫសពាក្យ רָעַע | «ហើយគាត់/វាអាក្រក់» |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | |
|---|---|---|
| וַיַּרְא | ទម្រង់ *vayyiqtol* នៃឫសពាក្យ רָאָה | «ហើយគាត់/វាបាន ឃើញ» |

យើងបានរៀនរួចមកហើយ នូវនាម רַע ដែលមានន័យថា “ការអាក្រក់/អំពើអាក្រក់” ឬ អាចជា “សេចក្តីអន្តរាយ” (ឧ. យ៉ូស្វេ 23:15)។ នៅក្នុងមេរៀននេះ យើងនឹងរៀនពីពាក្យ רָעַע ជាទម្រង់កិរិយាសព្ទដែលមកពីឫសពាក្យតែមួយ។

ដោយសារកិរិយាសព្ទ רָעַע មានព្យញ្ជនៈពីរដែលដូចគ្នា (ע)
នោះគេហៅកិរិយាសព្ទបែបនេះថាជា
«កិរិយាសព្ទដែលមានព្យញ្ជនៈត្រួតគ្នា» (“*geminate* verb”)។
ពេលយើងប្រើកិរិយាសព្ទបែបនេះ នៅក្នុងទម្រង់ផ្សេង
ភាគច្រើនវានឹងបាត់បង់ព្យញ្ជនៈមួយក្នុងពាក្យនោះ។ ដូច្នេះហើយបានជា យើងឃើញពាក្យ וַיֵּרַע ដែលមានព្យញ្ជនៈ ע តែមួយ ដោយព្រោះវាបានបាត់បង់ព្យញ្ជនៈ ע មួយទៀត
នៅខាង
ចុង។ ឧ. 2 សាំយូអែល 11:27b៖

וַיֵּרַע הַדָּבָר אֲשֶׁר־עָשָׂה דָוִד בְּעֵינֵי יהוה׃
”ហើយរឿងដែលស្តេចដាវីឌបានធ្វើ វាអាក្រក់នៅចំពោះព្រះនេត្រព្រះយេហូវ៉ា“

## 37.4 יִהְיֶה - «គាត់នឹងក្លាយទៅជា...»

នៅក្នុង មេរៀន 21.2 យើងបានរៀនពី *imperfective aspect* ។ យើងបានឃើញហើយថា ជួនកាលគេ ហៅកិរិយាសព្ទបែបនេះ ថាជាទម្រង់កិរិយាសព្ទ *imperfect* ឧ. *vav-consecutive-imperfect* (ដែលគេក៏ហៅជា “*vayyiqtol*”)។

នៅក្នុងមេរៀននេះ យើងនឹងរៀនពី יִהְיֶה ដែលជាទម្រង់កិរិយាសព្ទ *imperfect* (*yiqtol*) មួយ។ ពាក្យ יִהְיֶה មានឫសពាក្យមកពី הָיָה (សូមមើល មេរៀន 26.1)។

ដូចដែលយើងបាននិយាយពីមុន ជួនកាល ទម្រង់កិរិយាសព្ទ *imperfect* (*yiqtol*)
មិនមែនសំដៅទៅលើអ្វីដែលនឹងកើតឡើងនៅពេលអនាគតទេ តែនៅក្នុងមេរៀននេះ
យើងប្រើវាសំដៅទៅលើពេលអនាគត
ដោយព្រោះព្រះគម្ពីរភាសាហេព្រើរជាធម្មតាប្រើតាមរបៀបនេះ។

នៅក្នុងមេរៀនជាវិដេអូ យើងលើកឡើងឧទាហរណ៍នេះ៖

אַבְרָם יִהְיֶה אִישׁ זָקֵן
“លោកអាប់រ៉ាមនឹងក្លាយទៅជាមនុស្សចាស់”



Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

យើងក៏លើកឧទាហរណ៍ចេញពី ១សាំយូអែល 17:37b ផងដែរ៖

וַיֹּ֨אמֶר שָׁא֤וּל אֶל־דָּוִד֙ לֵ֔ךְ וַיהוָ֖ה יִהְיֶ֥ה עִמָּֽךְ׃
“ហើយស្ដេចសូលនិយាយទៅកាន់ដាវីឌថា ‘ទៅចុះ
ហើយព្រះយេហូវ៉ានឹងគង់នៅជាមួយឯង’”

សូមពិនិត្យមើលកិរិយាសព្ទពីរនេះ ដែលប្រើជាទម្រង់ *perfective aspect* (perf.) នឹង *imperfective* aspect (impf.)៖

**impf ← perf**

יִהְיֶה ← הָיָה

יִבְנֶה ← בָּנָה

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 38 - សាសន៍អ៊ីស្រាអែលចង់បានស្តេច

មេរៀននេះ មិនមានណែនាំស្គាល់ពីចំណុចវេយ្យាករណ៍ថ្មីទេ
តែយើងនឹងផ្តល់ការបកប្រែរឿងនេះ ជាស្រេចហើយ ទៅតាមន័យពាក្យ។

וַיְהִי כִּי־זָקֵן שְׁמוּאֵל וְלֹא־הָלְכוּ בָנָיו בִּדְרָכָיו׃



ហើយសាំយូអែលចាស់ហើយ
ហើយកូនគាត់មិនដើរតាមផ្លូវរបស់គាត់ទេ។

וַיָּבֹאוּ כֹּל זִקְנֵי יִשְׂרָאֵל
אֶל־שְׁמוּאֵל וַיֹּאמְרוּ אֵלָיו הִנֵּה
אַתָּה זָקַנְתָּ וּבָנֶיךָ לֹא הָלְכוּ
בִּדְרָכֶיךָ עַתָּה שִׂים־לָנוּ מֶלֶךְ׃



ហើយពួកចាស់ទុំនៃ[សាសន៍]អ៊ីស្រាអែលបានមក[ជួប]សាំយូអែល
ហើយពួកគេនិយាយទៅគាត់ថា “មើល អ្នកចាស់ហើយ
ហើយកូនរបស់អ្នកមិនដើរតាមផ្លូវរបស់អ្នកហើយ។ ឥឡូវចូរតាំងស្តេចឲ្យយើង

וַיֵּרַע הַדָּבָר בְּעֵינֵי שְׁמוּאֵל׃ וַיֹּאמֶר יהוה אֶל־שְׁמוּאֵל שְׁמַע בְּקוֹל הָעָם׃

ហើយរឿងនេះ អាក្រក់នៅចំពោះភ្នែករបស់សាំយូអែល
ហើយព្រះយេហូវ៉ាមានបន្ទូលទៅសាំយូអែលថា “ចូរស្តាប់តាមសំលេង[22]បណ្តាជន”។

וַיֹּאמֶר שְׁמוּאֵל אֶל־הָעָם הַמֶּלֶךְ יִקָּח אֶת־בְּנֵיכֶם וְאֶת־בְּנוֹתֵיכֶם
וְאֶת־שְׂדוֹתֵיכֶם וְאֶת־עַבְדֵיכֶם וְאֶת־שִׁפְחוֹתֵיכֶם׃



ហើយសាំយូអែលបាននិយាយទៅបណ្តាជនថា
“ស្តេចនឹងយកកូនប្រុសរបស់ឯងរាល់គ្នា កូនស្រីរបស់ឯងរាល់គ្នា
វាលស្រែរបស់ឯងរាល់គ្នា អ្នកបម្រើប្រុសរបស់ឯងរាល់គ្នា
ហើយនិងអ្នកបម្រើស្រីរបស់ឯងរាល់គ្នា”

וְלֹא שָׁמַע הָעָם בְּקוֹל שְׁמוּאֵל וַיֹּאמְרוּ לֹּא כִּי אִם־מֶלֶךְ יִהְיֶה עָלֵינוּ׃

[22] តាមន័យពាក្យ គឺ «សម្លេង» ដែល មានន័យថា «សំដី»។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ប៉ុន្តែបណ្តាជនមិនបានស្តាប់[តាម]សំដីសាំយូអែលទេ ហើយពួកគេនិយាយថា “ទេ ត្រូវតែមានស្តេច លើយើង” ។[23]

וַיִּשְׁמַע שְׁמוּאֵל אֵת דִּבְרֵי הָעָם וַיְדַבֵּר אֶת־דִּבְרֵיהֶם בְּאָזְנֵי יהוה׃

ហើយសាំយូអែលស្តាប់[តាម]សំដីបណ្តាជន
ហើយប្រាប់សំដីរបស់ពួកគេទៅត្រចៀកព្រះយេហូវ៉ា។[24]

וַיֹּאמֶר יהוה אֶל־שְׁמוּאֵל שְׁמַע בְּקוֹלָם׃

ហើយព្រះយេហូវ៉ាមានព្រះបន្ទូលទៅសាំយូអែលថា “ចូរស្តាប់[តាម]សម្លេងរបស់ពួកគេ”។

וַיֹּאמֶר שְׁמוּאֵל אֶל־אַנְשֵׁי יִשְׂרָאֵל לְכוּ אִישׁ לְעִירוֹ׃

ហើយសាំយូអែលបាននិយាយទៅកាន់ពួកបុរសនៃសាសន៍អ៊ីស្រាអែលថា “ទៅចុះ បុរសម្នាក់ៗ ទៅក្រុងរៀងៗខ្លួន” ។

וַיְהִי־אִישׁ מִבִּנְיָמִין וּשְׁמוֹ שָׁאוּל׃ וַיָּבֹא שָׁאוּל אֶל־עִיר שְׁמוּאֵל׃



ហើយមានបុរសម្នាក់មកពី[កុលសម្ព័ន្ធ]បេនយ៉ាមីន
ហើយឈ្មោះគាត់ សូល។
ហើយសូលបានមកក្រុងរបស់សាំយូអែល។

וּשְׁמוּאֵל רָאָה אֶת־שָׁאוּל ויהוה אָמַר־לוֹ הָאִישׁ הַזֶּה יִהְיֶה מֶלֶךְ עַל־עַמִּי׃

ហើយសាំយូអែលបានឃើញសូល ហើយព្រះយេហូវ៉ាមានបន្ទូលទៅគាត់ (សាំយូអែល) ថា “បុរស[ម្នាក់]នេះនឹងធ្វើជាស្តេចលើបណ្តាជនរបស់អញ” ។

וַיִּמְשַׁח שְׁמוּאֵל אֶת־שָׁאוּל לְמֶלֶךְ׃



ហើយសាំយូអែលបានចាក់ប្រេងតាំងសូលជាស្តេច។

וַתְּהִי עָלָיו רוּחַ אֱלֹהִים וַיְהִי שָׁאוּל מֶלֶךְ עַל־יִשְׂרָאֵל׃



[23] ការ HOV ដែលសរសេរថា “ទេ ត្រូវតែមានស្តេចលើយើងរាល់គ្នាវិញ” (១សាំ. 8:19)។
សូមប ... יְהִי) ជាទម្រង់ imperfect ដែលអាចសំដៅទៅលើពេលអនាគត ឬ
អ្វីដែលយើងចង់បាន ទាមទា ឬ ត្រូវការ។

[24] មានន័យថា «រួចទៅទូលដល់ព្រះយេហូវ៉ាវិញ» (KHOV)។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ហើយព្រះវិញ្ញាណនៃព្រះបាន[មកសណ្ឋិត]លើគាត់ ហើយសូលធ្វើជាស្ដេច[លើ]អ៊ីស្រាអែល។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 39 - កំឡាំង & ប្រាជ្ញា៖ ការប្រៀបធៀប

## 39.1 វគ្គសព្ទថ្មី

חָזָק - ខ្លាំង

כֹּחַ - កំឡាំង

חָכָם - ឆ្លាត ពូកែ ស្ទាត់ជំនាញ មានប្រាជ្ញា

חָכְמָה - ភាពឆ្លាតវៃ ជំនាញ ប្រាជ្ញា

אֲרוֹן הַבְּרִית - ហឹបសញ្ញានៃព្រះ

צָבָא - កងទ័ព សង្គ្រាម (ពហុ.៖ צְבָאוֹת)

## 39.2 ការប្រៀបធៀបដោយប្រើពាក្យ מִן

ជួនកាលគេប្រើធ្នាក់ מִן សម្រាប់ប្រៀបធៀបកម្មវត្ថុពីរ។ ជាភាសាខ្មែរ យើងប្រើពាក្យ «ជាង» សម្រាប់ប្រៀបធៀបរបស់មួយទៅនឹងរបស់មួយទៀត ឧ. «ខ្លាំងជាង» (ខ្លាំង+ជាង)។ រីឯភាសាហេព្រើរវិញ គេប្រើពាក្យ מִן ឧ.៖

הַסּוּס הַזֶּה גָּדוֹל מִן־הַסּוּס הַהוּא
"សេះនេះធំជាងសេះនោះ"

<u>កំណត់ចំណាំ</u>៖ ពេលពាក្យ מִן ប្រើជាបុព្វបទភ្ជាប់ជាមួយនឹងនាម នោះវាបាត់បង់អក្សរ ן (assimilates) ហើយវានៅសល់តែព្យញ្ជនៈ מ និងស្រៈ *hiriq* (מִ) ឬ *tsere* (מֵ)។ ឧ.៖

רָחֵל יָפָה מִלֵּאָה אֲחֹתָהּ
រ៉ាជែល ស្អាតជាង ឡេអា ជាបងស្រីរបស់គាត់

ធ្នាក់ מִן អាចផ្សំជាមួយនឹងសព្វនាមក្លាយទៅជាទម្រង់ពាក្យថ្មី ដែលមានន័យដូចគ្នានឹងន័យដើម។
ទម្រង់នេះស្រដៀងគ្នានឹងអ្វីដែលយើងបានរៀនអំពីពាក្យ אֵין អញ្ចឹងដែរ ឧ. ពេលផ្សំជាមួយនឹងសព្វនាម הוּא វាក្លាយទៅជា אֵינֶנּוּ («គាត់/វាមិនមែន...") ។

នៅខាងក្រោមនេះ ជាឧទាហរណ៍ស្តីពីទម្រង់បែបនេះ៖

מִמֶּנּוּ ← הוּא + מִן («ពីគាត់/វា» ឬ «ជាងគាត់/វា»)

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

מִמֶּנִּי ← אֲנִי + מִן («ពីខ្ញុំ» ឬ «ជាងខ្ញុំ»)

מִמְּךָ = אַתָּה + מִן («ពីអ្នក[ភេទប្រុស]» ឬ «ជាងអ្នក[ភេទប្រុស]»)

מִמֵּךְ = אַתְּ + מִן («ពីអ្នក[ភេទស្រី]» ឬ «ជាងអ្នក[ភេទស្រី]»)

ដូច្នេះពេលលោកអាប់រ៉ាមនិយាយថា “ឱនាង Beth អើយ ខ្ញុំខ្លាំងជាងអ្នក” ជាភាសាហេព្រើរគឺ៖

בֵּת, אֲנִי חָזָק מִמֵּךְ

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 40 - លោកុប្បត្តិ & ទូកធំ៖ ប្រភេទនៃរបស់ដែលព្រះបានបង្កើតឡើង

## 40.1 ប្រភេទនៃរបស់ដែលព្រះបានបង្កើតឡើង

ជនជាតិហេព្រើរបុរាណមិនបានបែងចែកសត្វជាប្រភេទដូចជាបច្ចុប្បន្ននេះទេ។ ឧ. ភាសាហេព្រើរមិនមែនពាក្យ «សត្វលូន» នោះទេ តែគេមានពាក្យ רֶמֶשׂ ដែលអាចរាប់បញ្ចូលសត្វលូន តែគេប្រើពាក្យនេះដើម្បីសំដៅទៅលើសត្វតូចៗទាំងអស់ដែលលូនវានៅលើដី ឧ. កណ្ដុរនិងសត្វល្អិត (ឧ. លោក. 1:26; លេវ. 11:46)។

אָדָם - មនុស្សជាតិ; មនុស្ស

בְּהֵמָה – សត្វធំៗ; សត្វគោ

רֶמֶשׂ - សត្វតូចៗ ដែលលូនវានៅលើដី

חַיָּה - អ្វីដែលមានជីវិត; សត្វ; សត្វព្រៃ (កំណត់ចំណាំ៖ សូមកុំច្រឡំនាមនេះជាមួយនឹងកិរិយាសព្ទ חָיָה ដែលគ្មានសញ្ញា dagesh ហើយមានន័យថា “រស់”)

אֱלֹהִים - វិញ្ញាណដែលមានអំណាច។ ទោះបីជាពាក្យនេះជួនកាលពាក្យនេះអាចសំដៅទៅលើព្រះក៏ដោយ តែវាក៏ប្រើសម្រាប់វិញ្ញាណផ្សេងដែលមានអំណាចដែរ ដូចជាចេរូប៊ីមឬទេវតា។ វិញ្ញាណទាំងអស់នេះស្ថិតនៅក្នុងប្រភេទតែមួយដែលគ្មាន בָּשָׂר (= “រូបសាច់ឈាម”)។ (សូមមើល [វីដេអូនេះ]() បង្កើតដោយក្រុម Bible Project ដែលពន្យល់ពីវិញ្ញាណនៅក្នុងព្រះគម្ពីរ)។

អ្វីៗទាំងអស់ដែលមិនមែនជា אֱלֹהִים គឺរាប់ជា בָּשָׂר (“សាច់ឈាម”) ឬ חַיָּה נֶפֶשׁ (“អ្វីដែលមានជីវិត/ព្រលឹង” ឧ. លោក. 9:12, 15, 16) ឬ חַיָּה (“អ្វីដែលមានជីវិត”)។ លោកអ័ដាំក្លាយទៅជា חַיָּה נֶפֶשׁ នៅពេលដែលព្រះជាម្ចាស់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូល (លោក. 2:7; KHOV: “...ត្រឡប់ជាមានព្រលឹងរស់ឡើង”) ហើយសត្វក៏អញ្ចឹងដែរ (លោក. 7:21-23)។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.




<u>កំណត់ចំណាំទីមួយ</u>៖ ពាក្យ נֶפֶשׁ חַיָּה ជាទម្រង់ឯកវចនៈ ប៉ុន្តែអាចប្រើសំដៅទៅលើសត្វឬមនុស្ស ពហុវចនៈបាន។

<u>កំណត់ចំណាំទីពីរ</u>៖ ពេលភាសាហេព្រើរបញ្ជាក់ពីប្រភេទលក្ខណៈចម្បងៗ នៃរបស់ណាមួយ ជាញឹកញាប់គេប្រើទម្រង់ "...בֶּן־" )«កូនរបស់...»)។ សូមមើលឧទាហរណ៍ខាងក្រោម៖

- בֶּן־אָדָם - មនុស្ស (តាមន័យពាក្យ «កូនរបស់មនុស្ស» ទម្រង់ឯកវចនៈ)
- בְּנֵי אָדָם - មនុស្ស (តាមន័យពាក្យ «កូនរបស់មនុស្ស» ទម្រង់ពហុវចនៈ)
- בְּנֵי אֱלֹהִים - វិញ្ញាណដែលមានអំណាច (តាមន័យពាក្យ «កូនរបស់ព្រះ») ឧ. យ៉ូប 1:6; ចោទ. 32:8។

## 40.2 វគ្គសព្ទថ្មី

- תֵּבָה - ទូកធំ ឬ ប្រអប់
- רוּחַ חַיִּים - ខ្យល់ដង្ហើមជីវិត
- עֲצֵי־גֹפֶר – KHOV: ដើមឈើម៉ៃសាក់ (ភាសាអង់គ្លេស៖ gopher wood)
- מַבּוּל - ទឹកជំនន់ ឬ ព្យុះកំបុតត្បូងធំ
- רָעָה – (គុណនាម) អាក្រក់; (នាម) សេចក្ដីអាក្រក់ ឬ សេចក្ដីអន្តរាយ

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 41 - כְּ & ភាពស្រដៀងគ្នា

## 41.1 វគ្គសព្ទថ្មី

- יָשָׁר - ត្រង់ ត្រឹមត្រូវ ឬ ប្រកាន់ភាពត្រឹមត្រូវ (គុណនាម)
- כְּ - ដូចនឹង ឬ ស្រដៀងគ្នានឹង
- כַּאֲשֶׁר - តាម (ឧ. «ខ្ញុំធ្វើតាមអ្វីដែលអ្នកប្រាប់ខ្ញុំ») ដូចនឹង ឬ ស្រដៀងគ្នានឹង

## 41.2 ធ្នាក់ כְּ

ជាធម្មតាធ្នាក់ כְּ ប្រើសម្រាប់ប្រៀបធៀបរបស់ដែលមានលក្ខណៈស្រដៀងគ្នា។

ពាក្យនេះជាបុព្វបទធ្នាក់ដែលនៅជាប់នឹងនាម (inseparable preposition) ដូចគ្នានឹង ធ្នាក់ בְּ ឬ לְ ។ ដូចនឹងអ្វីដែលយើងរៀនអំពីធ្នាក់បែបនេះ នៅពេលដែលធ្នាក់ כְּ ភ្ជាប់ជាមួយនឹងពាក្យដែលមាន article ជាក់លាក់ (definite article הַ) នោះព្យញ្ជនៈ ה ត្រូវយកចេញ (assimilated) ដោយធ្នាក់ ប៉ុន្តែនៅសល់តែស្រៈរបស់ article ជាក់លាក់ (הַ) ប៉ុណ្ណោះ។

כְּ + הַ ← כַּ

ឧ. នាង Beth បាននិយាយថា “លោកអាប់រ៉ាមដើរ ដូចជា បុរសសាសន៍អេស៊ីប”៖

אַבְרָם הָלַךְ כְּאִישׁ מִצְרִי׃

ជួនកាល ព្យញ្ជនៈបន្ទាប់អាចបណ្ដាលឲ្យសម្លេងនៃស្រៈមួយនោះ បង្អូសឲ្យវែង ហើយក្លាយជាស្រៈ *qamets*៖

כְּ + הָ ← כָּ

ឧ. នៅក្នុងមេរៀននេះ នាង Beth បាននិយាយថា “ខ្ញុំដូចស្ត្រីតូចម្នាក់ហ្នឹង”៖

אָנֹכִי כָּאִשָּׁה הַקְּטַנָּה

## 41.3 כַּאֲשֶׁר

នៅខាងលើ យើងបាននិយាយថា ជាធម្មតាធ្នាក់ כְּ
ប្រើសម្រាប់ប្រៀបធៀបរបស់ពីរដែលដូចគ្នា រីឯពាក្យ כַּאֲשֶׁר វិញ

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

ប្រើសម្រាប់ប្រៀបធៀបកិច្ចការពីយ៉ាងដែលដូចគ្នា។ ជាភាសាខ្មែរ យើងអាចប្រែថា "ស្របគ្នានឹង" ឬ "តាម" ឬ "ដូចនឹង" ។ ឧ. នាំង Beth បាននិយាយថា៖

אַבְרָם עָשָׂה כַּאֲשֶׁר דִּבַּרְתִּי׃

"លោកអាប់រ៉ាមធ្វើដូចនឹងខ្ញុំនិយាយ"

# មេរៀនទី 42 - ពន្លឺ & ភាពងងឹត; ព្រឹក & ល្ងាច

## 42.1 វគ្គសព្ទថ្មី

- אוֹר - ពន្លឺ
- חֹשֶׁךְ - ភាពងងឹត
- בֹּקֶר - ព្រឹក
- עֶרֶב - ល្ងាច
- רֵאשִׁית – ដើមដំបូង
- קֵץ – (នាម) ទីបញ្ចប់ ឬ ចុងបំផុត (ឧ. អេសេគាល 7:6)
- רִאשׁוֹן – ដំបូង ទីមួយ ច្បង មេ

# មេរៀនទី 43 - ការបង្កើតពិភពលោក

មេរៀននេះ គ្មានទម្រង់វេយ្យាករណ៍ថ្មីទេ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 44 - ចេញទៅ & លើកឡើង

## 44.1 វគ្គសព្ទថ្មី

- יָצָא - គាត់បានចេញទៅ (ទម្រង់ *vayyiqtol* នៃឫសពាក្យនេះ គឺជា וַיֵּצֵא "ហើយគាត់បានចេញទៅ")
- נָשָׂא - គាត់បានលើកឡើង (ទម្រង់ *vayyiqtol* នៃឫសពាក្យនេះ គឺជា וַיִּשָּׂא "ហើយគាត់បានលើកឡើង"។
    - <u>កំណត់ចំណាំ</u>៖ នៅក្នុងពាក្យ וַיִּשָּׂא ព្យញ្ជនៈ נ ត្រូវបានដកចេញ (assimilated) ដោយព្រោះព្យញ្ជនៈ נ គឺជាព្យញ្ជនៈខ្សោយ។ យើងដឹងថា נ ត្រូវបានដកចេញ (assimilated) ដោយសារសញ្ញា *dagesh* (ជាចំណុចនៅកណ្តាលព្យញ្ជនៈ שּׂ)។

## 44.2 ទម្រង់ផ្សេងទៀតនៃឫសពាក្យ רָאָה

នៅក្នុងមេរៀននេះ យើងរៀនពីទម្រង់ផ្សេងនៃកិរិយាសព្ទខ្សោយ (*weak verb*)។ សម្រាប់ពាក្យ רָאָה យើងឃើញថាព្យញ្ជនៈខ្សោយគឺ ה (ព្យញ្ជនៈទីបី)។ ដោយព្រោះព្យញ្ជនៈ ה វាខ្សោយ ដូច្នេះវាងាយនឹងត្រូវបាត់បង់ពេលដែលប្រើវាក្នុងទម្រង់ផ្សេងទៀត។

ដូច្នេះ ពេលយើងប្រើឫសពាក្យ רָאָה នៅក្នុងទម្រង់ *vayyiqtol* וַיַּרְא ("ហើយគាត់បានឃើញ") នោះយើងអាចពិបាកក្នុងការសម្គាល់ឫសពាក្យដោយព្រោះតែវាបាត់ព្យញ្ជនៈ ה ។

យ៉ាងណាក៏ដោយ ពត៌មានលំអិតបែបនេះ<u>មិនសូវជួយយើងឲ្យចេះភាសាហេព្រើរស្ទាត់</u>ប៉ុន្មាននោះឡើយ ។ ពេលយើងអានភាសាហេព្រើរ យើងមិនគួរគិតវិភាគច្រើនពេកទាក់ទងនឹងពត៌មានស៊ីជម្រៅពេកខាងវេយ្យាករណ៍ នោះឡើយ។ របៀបដែលនាំឲ្យយើងនិយាយ អាន និងស្តាប់ភាសាហេព្រើរបានរលូន គឺផ្តោតទៅលើទម្រង់ជាក់ស្តែងនៃពាក្យ ជាជាងស្វែងយល់ពីការផ្លាស់ប្តូរពីទម្រង់មួយទៅទម្រង់មួយទៀត។ យើងគ្រាន់តែពន្យល់ពីចំណុចលំអិតទាំងនេះដល់សិស្សដែលមានចម្ងល់ប៉ុណ្ណោះ ។

## 44.3 ធ្នាក់ אֵת "ជាមួយ"

មានចំណុចសំខាន់មួយ ដែលយើងត្រូវចេះវែកញែករវាងបុព្វបទ אֵת ដែលបញ្ជាក់ពីពាក្យបន្ទាប់ជាកម្មបទផ្ទាល់ នឹងធ្នាក់ אֵת ដែលមានន័យថា "ជាមួយ"។ ប្រសិនបើពាក្យនេះ មានបច្ច័យជាសព្វនាមដែលនៅជាប់ជាមួយវា

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

នោះយើងអាចសម្គាល់វាបាន (សូមមើលមេរៀន 46.1)។ បើអត់មានទេ យើងអាចសម្គាល់តាមរយៈបរិបទនៃឃ្លា ក្រៅពីហ្នឹងគឺយើងមិនអាចដឹងនោះឡើយ។

នៅក្នុងមេរៀនជាវិដេអូនាង Beth ពន្យល់ថា ភាសាហេព្រើរមានធ្នាក់ពីរដែលមានន័យថា “ជាមួយ” ដូចគ្នា៖ אֵת និង עִם។
ពេលយើងបន្ថែមបច្ច័យជាសព្វនាមភ្ជាប់ជាមួយធ្នាក់ពីរនេះ នោះវានឹងក្លាយទៅជា៖

| | | |
|---|---|---|
| אֵת | עִם | ជាមួយ |
| אִתִּי | עִמִּי | ជាមួយខ្ញុំ |
| אִתּוֹ | עִמּוֹ | ជាមួយគាត់ [ប្រុស] |
| אִתְּךָ | עִמְּךָ | ជាមួយអ្នក[ប្រុស] |

## 44.4 សញ្ញា Sof Pasuq ( : )



סוֹף פָּסוּק

សញ្ញា *sof pasuq* (סוֹף פָּסוּק) គឺជាសញ្ញាដែលគេដាក់ចុងខគម្ពីរនិមួយៗ នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ចាប់តាំងពីពួកម៉ាសូរ៉េត (the Masoretes)។ ជាដើមដំបូង គេដាក់សញ្ញា *sof pasuq* ដើម្បីឲ្យអ្នកអានដឹងថា ត្រូវបង្អង់សម្លេង ដូចជាការដកឃ្លាជាភាសាខ្មែរអញ្ចឹងដែរ។ ដោយសារសញ្ញានេះនាំឲ្យអ្នកអានបង្អង់សម្លេង នោះពាក្យខាងចុងមុខសញ្ញា *sof pasuq* អាចមានការផ្លាស់ប្តូរស្រៈ។ ក្នុងករណីនេះ គេហៅទម្រង់ថ្មីនេះថា *pausal forms* (ទម្រង់ដែលកើតចេញមកពីការបង្អង់សម្លេង)។

នៅក្នុងវិដេអូនេះ នាង Beth បានឲ្យឧទាហរណ៍ស្តីពីរបៀបដែលស្រៈត្រូវបានផ្លាស់ប្តូរ ដោយព្រោះសញ្ញា *sof pasuq*។ ទម្រង់ពាក្យ *pausal forms* ជាពណ៌ក្រហម៖

- לְךָ ក្លាយទៅជា לָךְ នៅខាងមុខសញ្ញា *sof pasuq*។
- עִמְּךָ ក្លាយទៅជា עִמָּךְ នៅខាងមុខសញ្ញា *sof pasuq*។
- אִתְּךָ ក្លាយទៅជា אִתָּךְ នៅខាងមុខសញ្ញា *sof pasuq*។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 45 - កិរិយាសព្ទបន្តបន្ទាប់គ្នា ( Verb Sequences )៖ ទម្រង់ Vayyiqtol ( ផ្នែកទី១ )

## 45.1 **ទម្រង់ Vayyiqtol**

នៅក្នុង មេរៀន 22.3 យើងបានរៀនពីទម្រង់ *vayyiqtol* ដែលគេប្រើក្នុងការនិទានរឿងជាពិសេសនៅពេលដែលគេពិពណ៌នាពីហេតុការណ៍ផ្សេងៗ ដោយប្រើកិរិយាសព្ទដែលបន្តបន្ទាប់គ្នា ។ នៅក្នុងមេរៀននេះ យើងនឹងរៀនបន្ថែមពីទម្រង់ *vayyiqtol* នេះ។

## 45.2 **Qamets Hatuf**

ពាក្យ וַיָּקָם មានការបញ្ចេញសម្លេងដូចទៅនឹង «*vayyaq**o**m*» ជាជាងដូច «*vayyaq**a**m*» ដោយព្រោះច្បាប់វេយ្យាករណ៍ *qamets hatuf* ៖ នៅពេលណាស្រៈ *qamets* ( ָ ) ជាព្យាង្គដែលបិទ ( “closed” ) ហើយគ្មានការសង្កត់សម្លេង ( “unaccented” ) នោះគេបញ្ចេញ [o] ជាជាង [a]។ ប៉ុន្តែគួរឲ្យស្តាយ អ្នកនឹងឃើញមានករណីលើកលែងជាច្រើនដែលគេប្រើក្នុងទម្រង់បែបនេះ។ យ៉ាងណាក៏ដោយ វាមានប្រយោជន៍ដល់យើងប្រសិនបើយើងស្គាល់ច្បាប់វេយ្យាករណ៍នេះ។

## 45.3 **ការរំលឹក៖ កិរិយាសព្ទខ្សោយ**

សូមរំលឹកសារឡើងវិញនៅក្នុង មេរៀន 27.1 ដែលពន្យល់ពីកិរិយាសព្ទខ្សោយ נָתַן ។ ការពន្យល់នេះនឹងជួយឲ្យអ្នកបានយល់ពីមូលហេតុដែលវាក្លាយទៅជា וַיִּתֵּן («ហើយគាត់បានឲ្យ») ពេលវាជាទម្រង់ *vayyiqtol* ។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 46 - ចាត់ អ្នកនាំសារ & សព្វនាមជាកម្មបទ

## 46.1 ការពន្យល់បន្ថែមពីពាក្យ אֵת (បុព្វបទដែលបញ្ជាក់ពីកម្មបទ) និង אֵת (ធ្នាក់)

ដូចជាអ្វីដែលយើងបានពន្យល់នៅក្នុងមេរៀន 44.3
ភាសាហេព្រើរមានពាក្យពីរដែលសរសេរដូចគ្នា តែមានអត្ថន័យខុសគ្នា៖ បុព្វបទ אֵת
ដែលបញ្ជាក់ពីពាក្យបន្ទាប់ជាកម្មបទផ្ទាល់ នឹងធ្នាក់ אֵת ដែលមានន័យថា "ជាមួយ"។
ប្រសិនបើពាក្យនេះ មានបច្ច័យជាសព្វនាមដែលនៅជាប់ជាមួយវា
នោះយើងអាចសម្គាល់វាបាន។ តារាងនៅខាងក្រោមនេះ
បង្ហាញពីភាពខុសគ្នារវាងទម្រង់នៃពាក្យទាំងពីរនេះ
ពេលវាមានបច្ច័យជាសព្វនាមដែលនៅជាប់ជាមួយវា។

| אֵת (ជាធ្នាក់ "ជាមួយ" ) | אֵת (ជាបុព្វបទ) |
|---|---|
| אִתִּי "ជាមួយខ្ញុំ" | אֹתִי "______ ខ្ញុំ" |
| אִתְּךָ "ជាមួយអ្នក" (ប្រុស) | אֹתְךָ "______ អ្នក" (ប្រុស) |
| אִתָּךְ "ជាមួយអ្នក" (ស្រី) | אֹתָךְ "______ អ្នក" (ស្រី) |
| אִתּוֹ "ជាមួយគាត់" (ប្រុស)<br><br> | אֹתוֹ "______គាត់" (ប្រុស) |
| אִתָּהּ "ជាមួយគាត់" (ស្រី) | אֹתָהּ "______ គាត់" (ស្រី) |
| אִתָּנוּ "ជាមួយយើង" | אֹתָנוּ "______យើង" |
| אִתְּכֶם "ជាមួយអ្នករាល់គ្នា" (ប្រុស) | אֶתְכֶם "______អ្នករាល់គ្នា" (ប្រុស) |
| אִתָּם "ជាមួយពួកគាត់" (ប្រុស) | אֹתָם "______ ពួកគាត់" (ប្រុស) |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

សូមកត់ចំណាំថា ចំណុចមួយដែលខុសគ្នារវាងពាក្យទាំងពីរនេះ
គឺនៅពេលពាក្យនេះមានបច្ច័យជាសព្វនាមដែលនៅជាប់ជាមួយវា នោះពាក្យ אֵת (ជាធ្នាក់)
មានសញ្ញា *dagesh* រីឯពាក្យ אֵת(ជាបុព្វបទ) គ្មានសញ្ញា *dagesh* ទេ។







## 46.2 វគ្គសព្ទថ្មី

- שָׁלַח – គាត់[ប្រុស] បានចាត់ (ទម្រង់ *vayyiqtol*៖ וַיִּשְׁלַח)
- מַלְאָךְ – អ្នកនាំសារ
- מַאֲכֶלֶת – កាំបិត


Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# មេរៀនទី 47 - ម្ហូបអាហារ & ភេសជ្ជៈ




## 47.1 វគ្គសព្ទថ្មី




- יַיִן – ស្រាទំពាំងបាយជូរ
- חָלָב – ទឹកដោះគោ
- דְּבַשׁ – ទឹកឃ្មុំ
- תְּאֵנָה – ផ្លែល្វា
- זַיִת – ផ្លែអូលីវ
- עֵנָב – ទំពាំងបាយជូរ
- אֹכֶל ឬ מַאֲכָל – ម្ហូប
- אָכַל – គាត់បានញ៉ាំ
- שָׁתָה – គាត់បានផឹក















Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

# អត្ថបទបន្ថែម ទី១ – ឈ្មោះកណ្ឌគម្ពីរជាភាសាហេព្រើរ

នៅក្នុងមេរៀនជាវិដេអូ យើងបានណែនាំឲ្យស្គាល់ពីបទគម្ពីរ ដោយប្រើឈ្មោះកណ្ឌគម្ពីរជាភាសាហេព្រើរ។ តារាងនៅខាងក្រោមនេះ ជួយអ្នកឲ្យបានស្គាល់ពីឈ្មោះកណ្ឌគម្ពីរទាំងអស់។ សូមកត់ចំណាំថា ជូនកាលឈ្មោះទាំងនេះ មានអត្ថន័យដែលមិនដូចនឹងឈ្មោះខ្មែរឬអង់គ្លេសនោះឡើយ ដោយព្រោះឈ្មោះខ្មែរនិងអង់គ្លេស ចេញមកពីព្រះគម្ពីរសញ្ញាចាស់ជាភាសាក្រិក (ព្រះគម្ពីរសិបធូជីន; Septuagint)។ លំដាប់លំដោយនៃមាតិការនៅក្នុងព្រះគម្ពីរជូនកាលក៏មានភាពខុសគ្នាដែរនៅក្នុងភាសាហេព្រើរ។

សូមបញ្ជាក់ថាឈ្មោះខ្លះនៃព្រះគម្ពីរជាភាសាហេព្រើរដកស្រង់ចេញពីពាក្យដំបូងនៃគម្ពីរនោះឯង (ឧ. លោកុប្បត្តិ)។ ក្នុងករណីដែលកណ្ឌគម្ពីរមានការបែងចែកជាពីរ (ឧ. ១ និង ២ពង្ស.) នោះ គេប្រើអក្សរ א និង ב ជំនួសវិញ។ ឧទាហរណ៍ ១ពង្សាវតាក្សត្រ គឺជា מְלָכִים א។

| ខ្មែរ | English | ហេព្រើរ |
|---|---|---|
| លោកុប្បត្តិ | Genesis | בְּרֵאשִׁית |
| និក្ខមនំ | Exodus | שְׁמוֹת |
| លេវីវិន័យ | Leviticus | וַיִּקְרָא |
| ជនគណនា | Numbers | בְּמִדְבַּר |
| ចោទិយកថា | Deuteronomy | דְּבָרִים |
| យ៉ូស្វេ | Joshua | יְהוֹשֻׁעַ |
| ពួកចៅហ្វាយ | Judges | שֹׁפְטִים |
| សាំយូអែល | Samuel | שְׁמוּאֵל |
| ពង្សាវតារក្សត្រ | Kings | מְלָכִים |
| អេសាយ | Isaiah | יְשַׁעְיָהוּ |
| យេរេមា | Jeremiah | יִרְמְיָהוּ |
| អេសេគាល | Ezekiel | יְחֶזְקֵאל |
| ហូសេ | Hosea | הוֹשֵׁעַ |
| យ៉ូអែល | Joel | יוֹאֵל |
| អេម៉ុស | Amos | עָמוֹס |
| អូបាឌា | Obadiah | עֹבַדְיָה |
| យ៉ូណាស | Jonah | יוֹנָה |
| មីកា | Micah | מִיכָה |
| ណាហ៊ុម | Nahum | נַחוּם |
| ហាបាគុក | Habakkuk | חֲבַקּוּק |
| សេផានា | Zephaniah | צְפַנְיָה |
| ហាកាយ | Haggai | חַגַּי |
| សាការី | Zechariah | זְכַרְיָה |
| ម៉ាឡាគី | Malachi | מַלְאָכִי |
| ទំនុកដំកើង | Psalms | תְּהִלִּים |
| សុភាសិត | Proverbs | מִשְׁלֵי |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | |
|---|---|---|
| យ៉ូប | Job | אִיּוֹב |
| នាងរស់ | Ruth | רוּת |
| បទចំរៀងសាឡូម៉ូន | Song of Songs | שִׁיר הַשִּׁירִים |
| សាស្តា | Ecclesiastes | קֹהֶלֶת |
| បរិទេវ | Lamentations | אֵיכָה |
| នាងអេសធើរ | Esther | אֶסְתֵּר |

| | | |
|---|---|---|
| ដានីយ៉ែល | Daniel | דָּנִיֵּאל |
| អែសរ៉ា | Ezra | עֶזְרָא |
| នេហេមា | Nehemiah | נְחֶמְיָה |
| របាក្សត្រ | Chronicles | דִּבְרֵי הַיָּמִים |

# អត្ថបទបន្ថែម ទី២ – ពាក្យវេយ្យាករណ៍និងពាក្យផ្សេងៗជាភាសាហេព្រើរ

ដើមដំបូងឡើយភាសាហេព្រើរអត់មានពាក្យវេយ្យាករណ៍ច្រើនទេ ប៉ុន្តែចាប់តាំងពីសម័យព្រះគម្ពីរមក ជនជាតិហេព្រើរក៏បានបង្កើតពាក្យផ្សេងៗ ដើម្បីពន្យល់ពីវេយ្យាករណ៍ហេព្រើរ។ ក្នុងចំណោមពាក្យវេយ្យាករណ៍ទាំងនោះ ពាក្យខ្លះពិពណ៌នាពីភាសាហេព្រើរសម័យបុរាណ ខ្លះទៀតពិពណ៌នាពីភាសាហេព្រើរសម័យទំនើប។ តារាងនៅខាងក្រោមនេះ[25] បង្ហាញពីពាក្យវេយ្យាករណ៍ជា៖

1. ភាសាហេព្រើរសម័យទំនើប
2. ភាសាហេព្រើរបែបបុរាណ (រួមទាំងភាសាហេព្រើរដែលយើងឃើញនៅក្នុងសៀវភៅ Mishnah ដែលគេហៅថា «Mishnaic Hebrew»)
3. ភាសាអង់គ្លេស
4. ភាសាខ្មែរ

| ភាសាហេព្រើរ | ភាសាហេព្រើរបុរាណ | ភាសាអង់គ្លេស<br>אנגלית | ភាសាខ្មែរ |
|---|---|---|---|

[25] តារាងនេះត្រូវបានចងក្រងជាភាសាអង់គ្លេសដោយលោក Cameron Hamm នៅឆ្នាំ 2021 ហើយត្រូវបានបកបកប្រែជាភាសាខ្មែរនៅឆ្នាំ 2023 ដោយលោក Ryan Quey និងលោកគ្រូសមលាង។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| សម័យទំនើប עברית מודרנית | עִבְרִית מִקְרָאִית יְהוּדִית | | |
|---|---|---|---|
| תנ"ך | מִקְרָא | Hebrew Bible | ព្រះគម្ពីរជាភាសាហេព្រើរ |
| פרק | פֶּרֶק | chapter | ជំពូក |
| פסוק | פָּסוּק | verse | ខ |
| משפט | מִשְׁפָּט | sentence | ប្រយោគ |
| מילה | דָּבָר | thing, word | ពាក្យ |
| שם עצם | שֵׁם עֶצֶם | noun | នាម |
| פועל | פּוֹעַל | verb | កិរិយាសព្ទ |
| שם תואר | שֵׁם תֹּאַר | adjective | គុណនាម |
| תואר הפועל | תֹּאַר הַפּוֹעַל | adverb | គុណកិរិយា |
| שם פועל | מָקוֹר | infinitive | ទម្រង់ infinitive |
| מקור נטוי | מָקוֹר נָטוּי | infinitive construct | ទម្រង់ infinitive construct |
| מקור מוחלט | מָקוֹר מוּחְלָט | infinitive absolute | ទម្រង់ infinitive absolute |
| עתיד | יִקְטֹל[26] | yiqtol/imperfect/imperfective/prefix conjugation | ទម្រង់ yiqtol |
| עבר | קָטַל | qatal/perfect/perfective/suffix conjugation | ទម្រង់ qatal |
| זרוז | אֶקְטְלָה | cohortative (wish/desire – 1st person) | ទម្រង់ cohortative |

[26] វេយ្យាករណ៍ភាសាហេព្រើរបុរាណនិងភាសាហេព្រើរសម័យទំនើបមានចំណុចខុសគ្នាមួយចំនួន ដូច្នេះហើយបានជាយើងមិនប្រើពាក្យវេយ្យាករណ៍ភាសាហេព្រើរទំនើបសម្រាប់កិរិយាសព្ទអតីតកាល (**עבר**) បច្ចុប្បន្នកាល (**הווה**) និងអនាគតកាល (**עתיד**) នោះទេ តែយើងប្រើពាក្យដែលចេញមកពីទម្រង់នៃកិរិយាសព្ទនោះវិញគឺ **קָטַל** និង **יִקְטֹל**។

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | | |
|---|---|---|---|
| צווי | צִוּוּי | imperative (direct command – $2^{nd}$ person) | ពាក្យបង្គាប់ (បុរសទី២) |
| פיקוד (יוסיבי) | יַקְטֵל | jussive (indirect wish/desire – $3^{rd}$ person) | ទម្រង់ jussive |
| שורש | שֹׁרֶשׁ | root | ឫសពាក្យ |
| בניין | בִּנְיָן | verbal stem | |
| גיזרה | גִּזְרָה | weak pattern | ពាក្យ ឬ ព្យញ្ជនៈខ្សោយ |
| גרוני | גְּרוֹנִי | gutteral | ព្យញ្ជនៈដែលមានសម្លេងត្រង់បំពុងក |
| צורת הפסק | צוּרַת הֶפְסֵק<br>צוּרַת מֻנַּחָה | pausal form | ទម្រង់ដែលកើតចេញមកពីការបង្អង់សម្លេង |
| הווה | בֵּינוֹנִי | participle | ទម្រង់ participle |
| יחיד | יָחִיד | singular | ឯកវចនៈ |
| רבים | רַבִּים | plural | ពហុវចនៈ |
| זכר | זָכָר | masculine | ភេទប្រុស |
| נקבה | נְקֵבָה | feminine | ភេទស្រី |
| ה" הידיעה | הֵא-הַיְדִיעָה | article | Article ជាក់លាក់ |
| סמיכות | סְמִיכוּת | construct | ទម្រង់ផ្សារភ្ជាប់ |
| מילת יחס | מִילַּת יַחַס | preposition | ធ្នាក់ |
| פשר | פֵּשֶׁר | meaning | អត្ថន័យ |

# ពាក្យសំណួរសំខាន់ៗ៖

| | | |
|---|---|---|
| מַה | what? | អ្វី? |
| בַּמֶּה בַּמָּה | with what/by what means? | ដោយអ្វី? |
| מִי | who? | អ្នកណា? |
| לְמִי | to/for whom? | ដល់/សម្រាប់អ្នកណា? |
| מָתַי | when? | នៅពេលណា? |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.

| | | |
|---|---|---|
| עַד מָתַי | until when? | រហូតដល់ពេលណា? |
| לָמָּה  מַדּוּעַ | why? | ហេតុអ្វី? |
| אֵיפֹה  אַיֵּה  אֵי | where / what location? | នៅឯ(កន្លែង)ណា? |
| מֵאַיִן | from where? | មកពីណា? |
| אָנָה | to where? | ទៅណា? |
| אֵיךְ  אֵיכָה | how? | យ៉ាងម៉េច? |
| כַּמָּה | how many? | ប៉ុន្មាន? |

Draft copy. This work is Public Domain. You may share, adapt, and redistribute it without permission.